**សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale Droit et des Science Economiques

Royal  university of law and economics

## សារណាបញ្ចប់ការសិក្សា

# បទល្មើសហិង្សាដោយចេតនា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ   លោក **លាង ឆាយហួត**

លោក **ឡា ដារី**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **លាង នាយហួត** និង **ឡា ដារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ក្រុម ( L4A6 ) ជំនាន់ទី ២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០២០ ។

**សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ដឹងគុណ និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ ៖**

លោក **ឪពុក អ្នកម្តាយ** ទាំងពីរដែលលោកមានគុណយ៉ាងធំធេងចំពោះកូន ដែលពុំអាចកាត់ថ្លៃបាន ព្រោះលោកទាំងពីរបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សារូបកូនតាំងពីនៅក្នុងផ្ទៃ រហូតរូបកូនចម្រើនវ័យពេញរូបរាងដឹងក្តី លោកទាំងពីរបានទូន្មានអប់រំប្រៀនប្រដៅជាស់តឿន ឱ្យកូនប្រព្រឹត្តតែសេចក្តីល្អ ចេះយកអាសារ មនុស្សជុំវិញខ្លួន មិត្តភក្តិ បងប្អូន ញាតិមិត្ត ម្យ៉ាងវិញទៀតលោកទាំងពីរបានខិតខំធ្វើការទាំងថ្ងៃក្តៅត្រជាក់វេរាសព្វបែបយ៉ាង ដើម្បីកសាងគ្រួសារដោយសេចក្តីសុខសុភមង្គល និងសេចក្តីថ្លៃថ្នូរ ហើយលោកបានជួយទំនុកបម្រុងផ្តល់ឱ្យកូនបានទៅសិក្សា ដើម្បីទទួលយកចំណេះដឹង និងការអប់រំបន្ថែមដើម្បីឱ្យកូនក្លាយខ្លួនជាពលរដ្ឋល្អ យុវជនល្អ និងជាកូនល្អ នាថ្ងៃអនាគត។ ទាំងនេះគឺជាការផ្តល់ក្តីស្រឡាញ់ដោយស្មោះត្រង់ចេញអំពីសណ្តានចិត្ត ការថ្នាក់ថ្នម សណ្តោសប្រណី ធ្វើឱ្យកូនមានភាពកក់ក្តៅ និងរស់នៅដោយសេចក្តីថ្លៃថ្នូរ ចំពោះកូនគុណរបស់លោកទាំងពីរ គឺជាមហាគុណដ៏ធំធេងដែលកូនមិនអាចសងគុណលោកទាំងពីរអស់ឡើយ និងមិនមានថ្ងៃដែលអាចបំភ្លេចក្នុងមួយជីវិតរបស់កូនបានឡើយ ។

ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធិបុរសរង ប្រធានការិយាល័យស្រាវជ្រាវ និងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្នុងកំឡុងរយៈពេល ៤ឆ្នាំកន្លងមកនេះ យើងខ្ញុំបានទទួលនូវការអប់រំ ណែនាំ បង្ហាត់បង្រៀន និងការផ្តល់នូវចំណេះដឹងជាច្រើន ជាពិសេសនោះគឺលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យមិនខ្លាចការនឿយហត់ គឺមានតែខំជាស់តឿនស្មារតី និស្សិតឱ្យខិតខំសិក្សាដើម្បីពង្រឹងសមត្ថភាពឱ្យពេញលេញតាមសង្គមជាតិ ត្រូវការ និងការស្រាវជ្រាវថ្មីៗ ដើម្បីជួយដល់ការសិក្សាឱ្យកាន់តែមានភាពរីកចម្រើន។ ទាំងនេះគឺជា គុណដែលលោកគ្រូ អ្នកគ្រូស្ត្រាចារ្យបានផ្តល់នូវពុទ្ធិ បទពិសោធន៍ការសិក្សា ការងារ និងការរស់នៅផងដែរ។

ជាពិសេសជាងនេះទៅទៀតខ្ញុំបាទទាំងពីរនាក់ សូមថ្លែងនូវគារវកិច្ច និងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោកគ្រូសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលជាសាស្ត្រាចារ្យណែនាំខ្ញុំបាទទាំងពីរនាក់ ដែលលោកតែងតែផ្តល់នៅ មតិ អនុសាសន៍ ទ្រឹស្តី និងការអនុវត្តក្នុងការស្វែងយល់លើប្រធានបទខ្ញុំបាទយ៉ាងយកចិត្តទុកដាក់ ដើម្បីឈានទៅដល់ការទទួលបានភាពជោគជ័យ បើទោះបីជាលោកជាប់រវល់ការងារក្តី ឬពុំសូវស្រួលខ្លួនយ៉ាងណាក៏លោកនូវតែជួយជ្រោមជ្រែងផ្តល់នូវគំនិតយោបល់ និងឯកសារនានាដែលទាក់ទងនឹងប្រធានបទមួយនេះ

លោកបានផ្តល់នូវបទពិសោធន៍ល្អៗ សម្រាប់យើងខ្ញុំទាំងពីរនាក់ ។ លោកគ្រូតែងតែសប្បាយចិត្តនៅពេលដែលឃើញសិស្សខិតខំសិក្សា ស្នាមញញឹមនេះហើយ គឺជាកម្លាំងចិត្តជម្រុញឱ្យសម្រេចបាននូវកិច្ចការស្រាវជ្រាវមួយនេះ ។

ជាចុងបញ្ចប់ ខ្ញុំបាទទាំងពីរនាក់សូមគោរពជូនពរដល់លោក **ឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធិបុរសរង លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យ និងមិត្តនិស្សិត** មានសុខភាពល្អ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ**កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សូមស្វាគមន៍ មិត្តៗ និស្សិត ប្រិយមិត្តអ្នកដែលចូលចិត្តអានសៀវភៅ អ្នកស្រាវជ្រាវឯកសារទាំងឡាយជាទីរាប់អាន យើងខ្ញុំជានិស្សិតរៀននៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ ជំនាន់ទី២០។ យើងខ្ញុំមានសេចក្តីសប្បាយរីករាយណាស់ដែលមានកិត្តិយសបានស្រាវជ្រាវ និងរៀបចំសារណាមួយនេះឡើង។ រយៈពេល ៤ ឆ្នាំកន្លងមក ដែលយើងខ្ញុំបានសិក្សានៅទីនេះ និងទទួលបាននូវចំណេះដឹងយ៉ាងច្រើនតាមរយៈការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ នឹងជាពេលវេលាមួយដ៏មានតម្លៃនៃការស្រូបយកចំណេះដឹងពីវិស័យច្បាប់នេះ។ សង្គមមួយអាចអភិវឌ្ឍន៍ទៅបានអាស្រ័យទៅលើប្រជាជនមានចំណេះដឹង និងសម្បូរទៅដោយ ធនធានមនុស្ស ជាពិសេសគឺ យុវជន។

ដោយផ្អែកតាមកម្មវិធីសិក្សារបស់ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចតម្រូវឱ្យយើងខ្ញុំជា និស្សិត និងជាបេក្ខជន សរសេរសារណាបញ្ចប់ការសិក្សា ក្នុងឱកាសនេះយើងខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលវាជា ឱកាសនៃការស្រាវជ្រាវបង្កើតនូវអ្វីដែលថ្មី និងជាគុណប្រយោជន៍សម្រាប់អ្នកសិក្សា សិស្ស និស្សិត អ្នកស្រាវជ្រាវ សម្រាប់ពេលបច្ចុប្បន្ន នឹងនាថ្ងៃអនាគត។

គោលបំណងនៃការសរសេរប្រធានបទមួយនេះ គឺដើម្បីធ្វើការចែករំលែកចំណេះដឹងដែលបានសិក្សាកន្លងមក ជាងនេះទៅទៀតដើម្បីបង្ហាញអំពី បញ្ហាចោទនានាដែលទាក់ទងនឹងប្រធានបទ **បទល្មើសហិង្សាដោយចេតនា** ដែលសុទ្ធសឹងតែជាបញ្ហាយ៉ាងសំខាន់ដែលកើតមានឡើងនៅក្នុងសង្គមជារៀយៗ ហើយវាក៏ជាឧបសគ្គក្នុងការកសាងសង្គម និងសន្តិភាពផងដែរ។ ដោយសារបទល្មើសនេះជា បញ្ហាចម្បងនៃសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ទើបយើងខ្ញុំជ្រើសរើសនូវប្រធានបទនេះឡើង ដើម្បីធ្វើការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ហើយប្រធានបទមួយនេះពិតជាផ្តល់នូវចំណេះដឹង និងអ្វីដែលថ្មីមួយផ្អែកដល់អ្នកសិក្សាគ្រប់រូបអំពីបទល្មើសខាងលើ ។

ជាទីបញ្ចប់យើងខ្ញុំ សូមធ្វើការអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គងទាំងឡាយណាដែលកើតឡើងដោយអចេតនា តាមរយៈកំហុសអក្ខរាវិរុទ្ធ ការបកស្រាយ ពាក្យពេចន៍ វគ្គ ឃ្លា វេយ្យាករណ៍ ឬជាការខ្វះខាតនៅអត្ថន័យក្តី។ យើងខ្ញុំសូមទទួលមតិរិះគន់ ដើម្បីស្តាបនាពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ដើម្បីធ្វើការកែលម្អឱ្យមានភាពកាន់តែប្រសើរឡើង។ ជាពិសេសយើងខ្ញុំសូមសង្ឃឹមថា ទទួលបានការយោគយល់ និងអធ្យាស្រ័យ ពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងសិស្សនិស្សិតទាំងអស់ដោយសេចក្តីអនុគ្រោះ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃបទបទល្មើសព្រហ្មទណ្ឌ

**កថាខណ្ឌទី១៖ សញ្ញាណទូទៅនៃបទល្មើស** ........ ៥

**១.១. និយមន័យនៃបទល្មើសព្រហ្មទណ្ឌ** ........ ៥

**១.២. ធាតុផ្សំនៃបទល្មើស** ........ ៦

១.២.១. ធាតុនីត្យានុកូល ឬធាតុច្បាប់ ........ ៦

១.២.២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ ........ ៧

១.២.៣. ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ ........ ៧

**១.៣. ចំណាត់ថ្នាក់នៃបទល្មើស** ........ ៧

១.៣.១. បទល្មើសជាបទឧក្រិដ្ឋ ........ ៧

១.៣.២. បទល្មើសជាបទមជ្ឈិម ........ ៨

១.៣.៣. បទល្មើសជាបទលហុ ........ ៨

**កថាខណ្ឌទី២៖ ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ៨

**១.៤. ការទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ៨

១.៤.១. រូបវន្តបុគ្គល ........ ៩

១.៤.២. នីតិបុគ្គល ........ ១៣

**១.៥. ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ១៨

១.៥.១. វិបល្លាសស្មារតី ........ ១៨

១.៥.២. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ........ ១៨

១.៥.៣. ការការពារស្របច្បាប់ ........ ២០

១.៥.៤. ស្ថានភាពចាំបាច់ ........ ២០

១.៥.៥. អានុភាពនៃកម្លាំង ឬការចាប់បង្ខំ ........ ២១

**១.៦. ប្រភេទនៃទោសដែលត្រូវអនុវត្ត** ........ ២២

១.៦.១. មូលទោស ........ ២២

១.៦.២. ទោសបន្ថែម ..... ២២
១.៦.៣. ទោសជំនួស ..... ២៣

## ជំពូកទី២

## បទល្មើសហិង្សាដោយចេតនា

**កថាខណ្ឌទី១៖ បទល្មើសហិង្សាដោយចេតនា** ..... ២៥
**២.១. និយមន័យនៃបទហិង្សាដោយចេតនា** ..... ២៥
២.១.១. លក្ខខណ្ឌ ..... ២៥
២.១.២. ធាតុផ្សំនៃបទល្មើស ..... ២៥
ក. ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់ ..... ២៥
ខ. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ ..... ២៦
គ. ធាតុផ្សំអត្តនោម័ត ..... ២៧
២.១.៣. បទល្មើសហិង្សា និងការទប់ស្កាត់ ..... ២៨
ក. លក្ខណៈនៃការទប់ស្កាត់អំពើហិង្សា ..... ២៨
ខ. វិធានការទប់ស្កាត់ ..... ៣០
គ. ការការពារជនរងគ្រោះ ..... ៣១
**កថាខណ្ឌទី២៖ ការផ្តន្ទាទោសចំពោះបទល្មើសហិង្សាដោយចេតនា** ..... ៣៣
**២.២.ករណីបទល្មើសគ្មានស្ថានទម្ងន់ទោស** ..... ៣៣
២.២.១. លក្ខខណ្ឌ ..... ៣៣
ក. ករណីគ្មានស្ថានទម្ងន់ទោស ..... ៣៣
ខ. ការប្រើប្រាស់សារជាតិពុល ..... ៣៣
គ. ការផ្តល់អាហារដែលមានសារជាតិពុល ..... ៣៤
ឃ. ការបញ្ចូលសារជាតិពុលក្នុងប្រភពទឹក ..... ៣៤
ង. ហិង្សាស្រាល ..... ៣៤
២.២.២. ទោសដែលត្រូវអនុវត្តចំពោះបទល្មើសហិង្សាដោយចេតនា ..... ៣៥
**២.៣. ករណីមានស្ថានទម្ងន់ទោស** ..... ៣៥
២.៣.១. លក្ខខណ្ឌ ..... ៣៥
ក. ហិង្សាដែលចាត់ទុកជាបទល្មើសមានស្ថានទម្ងន់ទោស ..... ៣៥

ខ. ស្ថានទម្ងន់ទោសទាក់ទង នឹងជនរងគ្រោះ ......................................................................... ៣៧
គ. ស្ថានទម្ងន់ទោសដោយមានគោលដៅ ............................................................................... ៣៩
ឃ. ស្ថានទម្ងន់ទោសទាក់ទង នឹងជនជនល្មើស ....................................................................... ៤១
ង. អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន .......................................................... ៤១
២.៣.២. ទោសដែលត្រូវអនុវត្តចំពោះបទហិង្សាស្ថានទម្ងន់ទោស........................................................ ៤៣
**២.៤. ករណីបទល្មើសជាប្រភេទបទឧក្រិដ្ឋ**............................................................................. ៤៣
២.៤.១. លក្ខខណ្ឌ......................................................................................................... ៤៣
ក. ករណីការប្រើអំពើហិង្សាដោយកាត់អវៈយវៈជនរងគ្រោះ ...................................................... ៤៣
ខ. ស្ថានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ ................................................................ ៤៤
២.៤.២. ទោសដែលត្រូវអនុវត្តចំពោះហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស .................................... ៤៤
**២.៥. ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល**.......................................................................... ៤៥
**២.៦. ទោសបន្ថែម ប្រភេទ និងរយៈពេល** .............................................................................. ៤៦

## ជំពូកទី៣

## ករណីសិក្សាទាក់ទង និងប្រធានបទ

**កថាខណ្ឌទី៖១ ករណីស្ថិតក្នុងបទល្មើសហិង្សាក្នុងគ្រួសារ** ............................................................. ៤៨
**កថាខណ្ឌទី៖២ ករណីស្ថិតក្នុងបទល្មើសហិង្សាមានស្ថានទម្ងន់ទោស** ............................................... ៥១
**សេចក្តីសន្និដ្ឋាន**.................................................................................................................. ៥៥
**អនុសាសន៍**......................................................................................................................... ៥៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅគ្រប់ប្រទេសនៅលើសកលលោកយើងនេះ ចាប់តាំងពីសម័យបុរាណរហូតមកដល់ពេលបច្ចុប្បន្ន នេះមនុស្សតែងមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ជាពិសេសនោះគឺមានទំនាក់ទំនងយ៉ាងជិតស្និត ជាមួយ នឹងសង្គមរស់នៅ ដើម្បីឱ្យសង្គមមួយមានការអភិវឌ្ឍពីមួយដំណាក់កាលទៅមួយដំណាក់កាល នោះគេ សង្កេតឃើញថាមានបញ្ហា និងលទ្ធភាពក្នុងការដោះស្រាយបញ្ហាសម្រាប់សង្គមនីមួយៗ ជាងនេះទៅទៀតនៅ ក្នុងសង្គមមួយដែលមានភាពជឿនលឿនខ្លាំង ក៏ឃើញការកើតមានបទល្មើសថ្មីៗបានកើតឡើងជាបន្តបន្ទាប់ ផងដែរ។ ដូច្នេះហើយទើបគេចងក្រងនូវក្បួនច្បាប់ឡើង នៅពេលដែលមានអំពើដែលជា ផលប៉ះពាល់ដល់ សង្គមកើតឡើង ។

ជាការពិតណាស់សព្វថ្ងៃនេះប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងអភិវឌ្ឍ និងរីកចម្រើនស្ទើរគ្រប់វិស័យ ផងដែរ។ ទន្ទឹមនឹងការអភិវឌ្ឍនេះ ក៏មានអំពើខុសច្បាប់ថ្មីៗកើតមានឡើង ដែលជាហេតុនាំឱ្យមានផលប៉ះពាល់ ទៅដល់សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយនៅក្នុងសង្គម និងប៉ះពាល់ដល់ទ្រព្យសម្បត្តិ កិត្តិយស សេចក្តី ថ្លៃថ្នូរ នឹងជាពិសេសនោះ គឺបានប៉ះពាល់ដល់អាយុជីវិតមនុស្សដែលកំពុងរស់នៅក្នុងសង្គមថែមទៀតផង។ នៅ គ្រប់ទីកន្លែងសុទ្ធសឹងតែអាចកើតមាននូវបទល្មើស មិនថានៅតំបន់ដាច់ស្រយាល ទីជនបទ ទីប្រជុំជន ទីកន្លែង ឯកជន ឬទីកន្លែងសាធារណៈ ឬនៅក្នុងទីក្រុងនោះទេ គឺគ្រាន់តែចំនួននៃបទល្មើសខុសគ្នានៅតាម ទីកន្លែង ប៉ុណ្ណោះ ។

បើសង្កេតដោយយកចិត្តទុកដាក់នោះ យើងនឹងឃើញនូវផលវិបាក និងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាព រស់នៅរបស់ប្រជាជនចំពោះបទល្មើសមួយចំនួនដែលជារើយៗ តែងតែមកយាយីដល់សេចក្តីសុខសុភមង្គលរបស់ មនុស្សជាតិ នឹងនាំឱ្យមានការប៉ះពាល់ដល់ទំនាក់ទំនងរបស់មនុស្ស។ ហេតុដូច្នេះហើយទើបប្រទេសកម្ពុជា និង បណ្តាប្រទេសនៅលើសកលលោក បានតាក់តែងបង្កើតឡើងនូវច្បាប់ និងមានការដាក់ទណ្ឌកម្មទៅលើជន ដែលបានប្រព្រឹត្តបទល្មើស ដោយបានកំណត់អំពីទំនាក់ទំនងហេតុ និងផលហើយកម្រិតទំហំនៃបទល្មើសទៅ តាមចរិតលក្ខណៈនៃបទល្មើសនោះ។ ច្បាប់បង្កើតឡើងសម្រាប់គ្រប់គ្រងនូវបទល្មើស និងបង្កើតឱ្យមានទោស ទណ្ឌ សម្រាប់ដាក់ទោសទៅលើជនល្មើសដែលបានប្រព្រឹត្តទង្វើដែលច្បាប់បានចែងថាជា "បទល្មើស" ។

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយធ្វើការបែងចែកជាប្រាំមួយ គន្ថី ក្នុងគន្ថីទាំងអស់ មានគន្ថីចំនួន៣ ដែលបានកំណត់ពីបទល្មើស។ បទល្មើសដែលបានចែងនៅក្នុងក្រម ព្រហ្មទណ្ឌត្រូវបានបែងចែកជា៣ គឺបទល្មើសប្រឆាំងនឹងបុគ្គល បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងបទល្មើស ប្រឆាំងនឹងជាតិ នៅក្នុងចំណោមបទល្មើសទាំងបីនេះ គឺសុទ្ធតែមានសារៈសំខាន់ទាំងអស់ដែលត្រូវយល់ដឹង ។

ដោយឡែក យើងខ្ញុំសូមលើកយកគន្លឹទី២ ដែលនៅក្នុងនោះមានចំណុចសំខាន់ជាច្រើន គឺដែលមានចែងអំពីបទល្មើសប្រឆាំងនឹងបុគ្គល ដែលបទល្មើសនេះ បង្កឱ្យមានផលប៉ះពាល់ដល់បុគ្គលយ៉ាងធ្ងន់ធ្ងរ គឺបទបទហិង្សាដោយចេតនា។ ដោយហេតុថាបទល្មើសមួយនេះ បានកើតឡើងជាញឹកញាប់ ទើបក្រមព្រហ្មទណ្ឌបានចែង និងកំណត់ពីទោសទណ្ឌយ៉ាងច្បាស់។

នៅក្នុងសារណានេះ យើងខ្ញុំបានលើកយកនូវចំណុចសំខាន់ៗ ទាក់ទងនឹងបទល្មើសហិង្សាដោយចេតនាមកធ្វើការបកស្រាយព្រោះតែជារឿយៗបទល្មើសមួយនេះ តែងតែបង្កឱ្យមានភាពអសន្តិសុខសណ្តាប់ធ្នាប់សង្គម និងជាពិសេសចំពោះជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដូច្នេះយើងខ្ញុំនឹងធ្វើការបកស្រាយនៅក្នុងសារណាមួយនេះ ដែលប្រធានបទនៃសារណានេះគឺ " **បទល្មើសហិង្សាដោយចេតនា** " ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាអំពើហិង្សាតែងកើតមានជារឿយៗ នៅគ្រប់ទីកន្លែងដែលនាំឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គម សកម្មភាពនៃការប្រព្រឹត្តបទល្មើសនេះបានបង្កជាចលាចលដល់ការរស់នៅជាពិសេសសេចក្តីសុខសុភមង្គលក្នុងគ្រួសារនីមួយៗ ហេតុដូច្នេះហើយទើបមានសំនួរចោទឡើងថាតើជនល្មើសដែលបានប្រព្រឹត្តអំពើហិង្សាទៅលើអ្នកដទៃត្រូវបានទទួលទោសទណ្ឌយ៉ាងដូចម្តេចខ្លះ ?

## ៣. កម្មវត្ថុនៃការស្រាវជ្រាវ

កម្មវត្ថុនៃការស្រាវជ្រាវរួមមានដូចខាងក្រោមនេះ ៖

- ស្វែងយល់អំពីសញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌ
- ស្វែងយល់អំពីលក្ខណៈនៃអំពើហិង្សា និងការទប់ស្កាត់ ដែលបញ្ញត្តិក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនឹងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥
- ស្វែងយល់អំពីលក្ខណៈនៃបទល្មើសហិង្សាដោយចេតនាដែលបានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩
- ស្វែងយល់អំពី សកម្មភាពដែលចាត់ទុកថាជាបទល្មើសហិង្សា និងទណ្ឌកម្មដែលត្រូវផ្តន្ទាទោសទៅលើជនល្មើស
- ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍ ដើម្បីចូលរួមកែលម្អ

## ៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការបកស្រាយទៅលើប្រធានបទមួយនេះ យើងខ្ញុំសូមលើកយកតែសញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌ លក្ខណៈនៃបទល្មើសហិង្សាមកបកស្រាយតែប៉ុណ្ណោះ។ លក្ខណៈនៃបទល្មើសហិង្សា គឺបកស្រាយដោយសង្កត់ធ្ងន់ទៅលើនិយមន័យ ធាតុផ្សំនៃបទល្មើសនីមួយៗ និងទោសដែលត្រូវអនុវត្តទៅលើបទល្មើសនោះ។ បន្ទាប់មកយើងខ្ញុំ នឹងធ្វើការលើកយកករណីសិក្សាមួយចំនួនមកធ្វើការបកស្រាយ។ យើងខ្ញុំនឹងមិនធ្វើ

ការបកស្រាយទៅលើចំណុចផ្សេងទៀតដែលមិនពាក់ព័ន្ធឡើយ ដូចជា ការរំលត់ទោស........ ចំពោះបទល្មើសនេះទេ។

## ៥. គម្រោងនៃការស្រាវជ្រាវ

គម្រោងនៃការស្រាវជ្រាវនេះ បានបែងចែកដូចខាងក្រោម ៖

- ចំណុចដំបូង ស្វែងយល់អំពីសញ្ញាណទូទៅនៃបទល្មើសតាមរយៈការសិក្សា ស្រាវជ្រាវទៅលើឯកសារដែលធ្លាប់បានសិក្សាកន្លងមក និងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

- ចំណុចបន្ទាប់ ធ្វើការស្វែងយល់អំពីអំពើហិង្សា និងការទប់ស្កាត់ ដែលបញ្ញត្តិក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

- ស្វែងយល់អំពីលក្ខណៈនៃបទល្មើសហិង្សាដោយចេតនា ដែលបានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

- ចំណុចបញ្ចប់ គឺធ្វើការវិភាគទៅលើការបកស្រាយ ចំពោះករណីសិក្សាពីបទហិង្សាដោយចេតនាហើយស្វែងយល់ពីការចោទប្រកាន់ទៅលើបទល្មើស រួចធ្វើសេចក្តីសន្និដ្ឋាន និងការផ្តល់ជាអនុសាសន៍ ដើម្បីរួមចំណែកនៅក្នុងការកែលម្អទៅលើបទល្មើស និងការផ្តល់យោបល់ខ្លះៗ ចំពោះការសិក្សាទៅលើបទល្មើសហិង្សាដោយចេតនាក្នុងពេលបច្ចុប្បន្ន។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីជំរុញឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានភាពជោគជ័យ គឺចាំបាច់ទាមទារនូវការសិក្សាស្រាវជ្រាវទៅលើឯកសារដែលពាក់ព័ន្ធជាច្រើន និងការប្រមូលព័ត៌មានដែលពាក់ព័ន្ធ សម្រាប់ធ្វើជាមូលដ្ឋាននៃការស្រាវជ្រាវប្រធានបទខាងលើ។ ហេតុដូច្នេះការសិក្សាស្រាវជ្រាវនេះត្រូវបានប្រមូលពីប្រភពឯកសារពីរប្រភេទគឺ ឯកសារចម្បង និងឯកសារបន្ទាប់បន្សំ។ តាមលទ្ធភាពនៃការសិក្សាស្រាវជ្រាវជាក់ស្តែង យើងមានវិធីប្រមូលព័ត៌មានដូចខាងក្រោម ៖

- **ឯកសារចំបង**

- ឯកសារ ដែលបានមកពី រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

- ឯកសារ ដែលបានមកពីច្បាប់ដែលពាក់ព័ន្ធសំខាន់ៗដូចជា ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី

- ច្បាប់ស្តីអំពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

- **ឯកសារបន្ទាប់បន្សំ**

- ឯកសារដែលបានមកពី មេរៀនដែលធ្លាប់បានសិក្សាកន្លងមក

- ឯកសារដែលបានមកពី សៀវភៅច្បាប់នានា

- ឯកសារដែលបានមកពី សៀវភៅនីតិព្រហ្មទណ្ឌទូទៅ
- ឯកសារដែលបានមកពី សៀវភៅនីតិព្រហ្មទណ្ឌពិសេស
- ឯកសារដែលបានមកពី សៀវភៅដែលបានមកពីការណែនាំរបស់សាស្ត្រាចារ្យដឹកនាំ
- ឯកសារដែលបានមកពី បណ្ណាល័យច្បាប់
- ឯកសារដែលបានមកពី ការណែនាំរបស់សិស្សច្បង
- ឯកសារដែលបានមកពី ការស្រាវជ្រាវតាមប្រព័ន្ធអ៊ិនធឺណេត
- ឯកសារដែលបានមកពី ការពិភាក្សាពីមិត្តរួមជំនាន់

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវចែកចេញជា ៣ ជំពូកដូចជា៖

- សេចក្តីផ្តើម
- ជំពូកទី១ សញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌ
- ជំពូកទី២ បទល្មើសហិង្សាដោយចេតនា
- ជំពូកទី៣ ស្វែងយល់ពីករណីសិក្សា និងការចោទប្រកាន់បទល្មើស
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូកទី១
# សញ្ញាណទូទៅនៃបទល្មើស
# ព្រហ្មទណ្ឌ

# ជំពូកទី១ សញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌ

## កថាខណ្ឌទី១៖ សញ្ញាណទូទៅនៃបទល្មើស

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះទើបអាចត្រូវផ្តន្ទានទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះទើបអាចត្រូវប្រកាសទោសបាន ។

### ១.១. និយមន័យនៃបទល្មើសព្រហ្មទណ្ឌ

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ហើយជាកំហុសរបស់ចារីផ្ទាល់។ ផ្ទុយទៅវិញប្រសិនបើច្បាប់ព្រហ្មទណ្ឌមិនចាត់ទុកថាអំពើណាមួយជាបទល្មើសទេ អំពើនោះមិនអាចចាត់ទុកថាជាបទល្មើសបានឡើយ ដោយអនុលោមតាម គោលការណ៍នីត្យានុកូលភាព[1]។ម្យ៉ាងវិញទៀតបទល្មើសជាអំពើប្រព្រឹត្តដោយចេតនាក្តី ឬអចេតនាក្តីដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ហើយត្រូវផ្តន្ទាទោសតាមការកំណត់ទុកជាស្រាច់នៃក្រមព្រហ្មទណ្ឌ។

ជាទូទៅគេអាចចាត់ទុកអំពើមួយថាជាបទល្មើសបាន លុះត្រាតែអំពើនោះបានបង្ហាញនូវគ្រោះថ្នាក់ដល់សង្គមដែលច្បាប់បានការពារ បទល្មើសក៏អាចត្រូវបានចាត់ទុកថាជាបាតុភូតអសកម្មក្នុងជីវភាពរស់នៅផងដែរ ព្រោះថាបទល្មើសជះឥទ្ធិពលអាក្រក់ដល់សណ្តាប់ធ្នាប់សង្គម ដល់សេរីភាពរបស់រដ្ឋ។ តាមពិតទៅនៅក្នុងសង្គមមនុស្ស មានអំពើជាច្រើនដែលត្រូវបានចាត់ទុកថាជាអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គម ហើយដែលច្បាប់ត្រូវចាត់វិធានការដោះស្រាយក្នុងគោលដៅដើម្បីរក្សាស្ថិរភាពនៃទំនាក់ទំនងបុគ្គល។ ក្រៅពីបទល្មើសព្រហ្មទណ្ឌដែលជាអំពើបង្កគ្រោះថ្នាក់ខ្លាំងក្លាជាងគេ គេឃើញមានអំពើល្មើសផ្នែករដ្ឋប្បវេណីដែលមានប្រភពមកពីបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលកំណត់ពីអំពើអនីត្យានុកូល[2] បុគ្គលដែលបានបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬអចេតនាត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ។ លើសពីនេះទៅទៀតក៏មានអំពើល្មើសផ្នែកវិន័យដែលជាអំពើធ្វើឱ្យប៉ះពាល់ ដល់ផលប្រយោជន៍សមូហភាពនៃក្រុមសង្គមណាមួយ ដូចជា ពេទ្យ មេធាវី សាការី យោធិន និស្សិតជាដើម ដោយអំពើទាំងនោះមិនត្រូវបានកំណត់ឱ្យច្បាស់លាស់ជាទូទៅទេ ដែលសុទ្ធសឹងតែជាអំពើបង្ហាញពីចរិតគ្រោះថ្នាក់ដល់សង្គមផងដែរ ដូចច្នេះមិនមែនមានតែបទល្មើសព្រហ្មទណ្ឌនោះទេ ដែលបង្កឱ្យមានផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់បុគ្គល និងសណ្តាប់ធ្នាប់របស់សង្គមទេ គឺនៅមានអំពើមួយចំនួនទៀត ដែលបង្កឱ្យមាន

[1] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[2] មាត្រា ៧៤៣ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ព្យសនកម្មផងដែរ តែមិនត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌឡើយ។

ដើម្បីកំណត់ថាអំពើមួយជាបទល្មើសបានត្រូវមានធាតុផ្សំនៃបទល្មើសចំនួនបីគឺ ៖

- ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់ ៖ ច្បាប់ដែលបានចាត់ទុកថាអំពើណាមួយជាបទល្មើស។
- ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ ៖ សកម្មភាព ឬអសកម្មភាពប្រព្រឹត្តដោយជនល្មើស។
- ធាតុផ្សំអត្តនោម័ត ឬធាតុចិត្តសាស្ត្រ ៖ កំហុសចេតនា ឬអចេតនារបស់ជនល្មើស។

### **១.២. ធាតុផ្សំនៃបទល្មើស**

ជាគោលការណ៍នៃការចោទប្រកាន់ និងការផ្តន្ទាទោសជនណា ឬបុគ្គលណាមួយបាន គឺលុះត្រាតែតុលាការបានរកឃើញ និងប្រកាសពីពិរុទ្ធភាពភាពដាក់បន្ទុកលើជននោះជាមុនសិន[3]។ ការប្រកាសពិរុទ្ធភាពលើជនណាម្នាក់ ឬលើបុគ្គលណាមួយអាចអនុវត្តបាន គឺលុះត្រាតែអំពើដែលប្រព្រឹត្តនោះមានធាតុផ្សំគ្រប់គ្រាន់ដែលតុលាការអាចប្រកាស លើជននោះ ឬបុគ្គលនោះបាន។ ផ្ទុយទៅវិញ ប្រសិនបើអំពើដែលប្រព្រឹត្តនោះពុំមានធាតុផ្សំគ្រប់គ្រាន់ ឬពុំមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ឬបុគ្គលណាមួយនោះទេ តាមគោលការណ៍តុលាការមិនអាចប្រកាសផ្តន្ទាទោសលើជននោះ ឬបុគ្គលនោះបានទេ។ ដោយហេតុថាជននោះ ឬបុគ្គលដែលត្រូវចោទប្រកាន់តាមផ្លូវតុលាការនោះ ត្រូវបានរួចផុតពីបទចោទប្រកាន់តាមផ្លូវច្បាប់[4]។

#### **១.២.១. ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់**

ធាតុផ្សំនីត្យានុកូល សំដៅទៅលើអត្ថបទច្បាប់ដែលប្បញ្ញត្តិអំពើណាមួយដែលចាត់ទុកថាជាបទល្មើស និងកំណត់អំពីទោសដែលត្រូវទទួលរង។ ដូច្នេះមានតែអំពើដែលបង្កើតជាបទល្មើសនៅពេលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន[5] មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចត្រូវប្រកាសបាន[6]។ គោលការណ៍នីត្យានុកូលភាពត្រូវបានទទួលស្គាល់ដោយ **លិខិតតុបករណ៍អន្តរជាតិ**[7] ដែលមានតម្លៃក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[8]។

[3] មាត្រា ២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[4] មាត្រា ៣៥០ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[5] ហ៊ាង ឡេង, នីតិព្រហ្មទណ្ឌ, (ភ្នំពេញ,២០១០)

[6] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[7] លិខិតតុបករណ៍អន្តរជាតិ គឺជាលិខិតបទដ្ឋានអន្តរជាតិ ដែលបង្កើតឡើងរវាងរដ្ឋ និងរដ្ឋ ឬរវាងរដ្ឋ និងអង្គការអន្តរជាតិ

[8] មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

#### ១.២.២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ

ធាតុសត្យានុម័ត អាចហៅម៉្យាងទៀតថាធាតុផ្សំសម្ភារៈ គឺជាការប្រព្រឹត្តអំពើល្មើសនឹងច្បាប់ និងមានផលវិបាក ឬលទ្ធផលដែលកើតឡើងពីអំពើល្មើសនោះពិតប្រាកដ។ មានន័យថាសកម្មភាព ឬកាយវិការរបស់ជនល្មើសដែលស្តែងឡើងក្រោមរូបភាពសកម្មក្តី ឬអសកម្មក្តី ហើយដើម្បីប្រព្រឹត្តអំពើល្មើស ជនល្មើសអាចប្រើប្រាស់មធ្យោបាយមួយចំនួនដូចជា៖ ការប្រើប្រាស់ឧបករណ៍ផ្សេងៗ ឬប្រើកលល្បិចបោកបញ្ឆោត ឬធ្វើសកម្មភាពពួនស្ទាក់ជាដើម ។

#### ១.២.៣. ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ

ធាតុអត្តនោម័ត គឺជាចិត្តគំនិតខាងក្នុងរបស់ជនល្មើស ដែលវាស្តែងមកខាងក្រៅតាមរយៈ ធាតុសត្យា-នុម័តដូចជា កាយវិការ ឬអំពើប្រព្រឹត្តរបស់ជនល្មើស។ ធាតុអត្តនោម័តស្តែងឡើងក្រោមរូបភាពដូចជា៖ កំហុស, មូលហេតុ និងកត្តាផ្សេងៗ ដែលជំរុញឱ្យប្រព្រឹត្តបទល្មើស។

### ១.៣. ចំណាត់ថ្នាក់នៃបទល្មើស

ជាក់ស្តែង ចំណាត់ថ្នាក់នៃបទល្មើសដែលសំខាន់ជាងគេ ហើយនឹងត្រូវបានស្គាល់ច្រើនជាងគេបំផុត គឺការបែងចែករវាង បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ[9] ទៅតាមទម្ងន់នៃបទល្មើស ទាំងនេះគឺជាចំណាត់ថ្នាក់នៃបទល្មើសដែលត្រូវបានប្បញ្ញត្តិយ៉ាងជាក់លាក់។

ដូច្នេះ ការបែងចែកបទល្មើសជាបីប្រភេទតាមលក្ខណៈធ្ងន់ធ្ងរនៃបទល្មើស គឺពិតជាមានសារៈសំខាន់ណាស់នៅក្នុងនីតិព្រហ្មទណ្ឌ ពីព្រោះថាការធ្វើចំណាត់ថ្នាក់ដូចខាងលើនេះ នាំមកនូវផលប្រយោជន៍ទាក់ទងនឹងរបបគតិយុត្ត ដែលច្បាប់រមែងចងភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបទល្មើស។ ដើម្បីអាចដឹងពីប្រភេទនៃបទល្មើសគេត្រូវពិនិត្យបច្ច័យទៅលើអតិបរមានៃទោសដាក់ពន្ធនាគារ ដែលច្បាប់បានចែងទុកក្នុងបទល្មើសនីមួយៗសម្រាប់កំណត់ថាបទល្មើសនោះស្ថិតក្នុងចំណាត់ថ្នាក់មួយណា។

#### ១.៣.១. បទល្មើសជាបទឧក្រិដ្ឋ

នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារត្រូវរងនូវការផ្តន្ទាទោសដូចខាងក្រោម៖

- ទោសដាក់ពន្ធនាគារអស់មួយជីវិត ។
- ទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ឆ្នាំ [10]។

ដូចនៅក្នុងករណីដែលបុគ្គលម្នាក់បានប្រព្រឹត្ត បទឃាតកម្មគិតទុកជាមុន ទៅលើជនរងគ្រោះការផ្តន្ទាទោស

[9] មាត្រា ២ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[10] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

នៅក្នុងបទល្មើស ឃាតកម្មគិតទុកជាមុន ច្បាប់បានកំណត់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអតិបរមា អស់មួយជីវិត ដូចនេះ បទឃាតកម្មគិតទុកជាមុន[11] គឺជាបទល្មើសមួយដែលស្ថិតក្នុងចំណាត់ថ្នាក់ជាប្រភេទនៃបទឧក្រិដ្ឋ។

### ១.៣.២. បទល្មើសជាបទមជ្ឈិម

បទល្មើសជាប្រភេទបទមជ្ឈិម គឺនៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវទទួលរង នោះមានរយៈពេលលើសពី ៦ថ្ងៃ និងក្រោម ឬស្មើនឹង ៥ឆ្នាំ[12] ។

ដូចនៅក្នុងករណីដែលបុរសម្នាក់បានប្រព្រឹត្តបទល្មើស ធ្វើឱ្យខូចខាតដោយចេតនា[13] ជាដើម។

### ១.៣.៣. បទល្មើសជាបទលហុ

នៅក្នុងករណីដែលអតិបរមា នៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើ ៦ថ្ងៃ ឬក៏ជាបទល្មើសតម្រូវឱ្យផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ដែលជាប្រភេទបទល្មើសលហុ[14]។ ដូចករណីដែលនារីម្នាក់បានប្រព្រឹត្តបទល្មើសជេរប្រមាថជាសាធារណៈ[15] ទៅលើនារីម្នាក់ទៀតជាដើម។

## កថាខណ្ឌទី២ ៖ ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

### ១.៤. ការទទួលខុសត្រូវព្រហ្មទណ្ឌ

ជាគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះតែអំពើរបស់ខ្លួនតែប៉ុណ្ណោះ[16]។ មានន័យថា នៅពេលដែលមានបទល្មើសមួយបានកើតឡើង ជនដែលប្រព្រឹត្តបទល្មើសត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន បើទោះបីជាស្ថិតនៅក្នុងឋានៈ ជាចារី ឬជាសហចារី ឬជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិតក៏ដោយ។ ក៏ប៉ុន្តែច្បាប់ក៏អាចអនុញ្ញាតឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីបានផងដែរ ចំពោះអំពើរបស់អ្នកដទៃដូចជា ការទទួលខុសត្រូវរបស់ឪពុកម្តាយ ចំពោះអំពើរបស់កូនជាអនីតិជន ឬការទទួលខុសត្រូវរបស់និយោជកចំពោះអំពើរបស់និយោជិតជាដើម[17]។ កាលណាបើមានធាតុផ្សំគ្រប់គ្រាន់ហើយបុគ្គលដែលបានប្រព្រឹត្តបទល្មើស ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមច្បាប់កំណត់ បើទោះបីជារូបវន្តបុគ្គលក្តី និងជានីតិបុគ្គលក្តី។

---

[11] មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[12] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[13] មាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[14] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[15] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[16] មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[17] មាត្រា ៧៤៦ និងមាត្រា៧៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**១.៤.១. រូបវន្តបុគ្គល**

រូបវន្តបុគ្គល គឺជាមនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល[18]។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល គឺជាការទទួលទោសតាមរូបភាពណាមួយ ដោយសារការប្រព្រឹត្តអំពើខុសច្បាប់របស់មនុស្សម្នាក់បណ្តាលឱ្យមានការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ សុខភាព អាយុជីវិត និងទ្រព្យសម្បត្តិរបស់អ្នកដទៃដែលច្បាប់បានការពារ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល គឺជាអំពើប្រព្រឹត្តផ្ទាល់របស់បុគ្គលណាមួយហើយបុគ្គលនោះនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្តនោះ។ ជារឿងដែលអយុត្តិធម៌ណាស់ប្រសិនបើឱ្យជនដែលមិនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមកទទួលខុសត្រូវនោះ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌចាំបាច់ត្រូវផ្ទៀងផ្ទាត់តួនាទីឱ្យត្រឹមត្រូវរបស់អ្នកចូលរួមប្រព្រឹត្តបទល្មើសនីមួយៗ។

អាស្រ័យទៅលើធាតុទាំងឡាយនៃសំណុំរឿងរបស់អ្នកចូលរួមទាំងនោះ គឺអាចត្រូវបានកំណត់ប្រភេទគតិយុត្តជាចារី ឬសហចារី ឬអ្នកផ្តើមគំនិត ឬអ្នកសមគំនិត។ ម៉្យាងទៀតប្រសិនបើបទល្មើសបានទៅដល់គោលបំណងដែលជនល្មើសចង់បានហើយនោះ គេនិយាយថាបទល្មើសនេះបានសម្រេច។

**ក. រូបវន្តបុគ្គលជានីតិជន**

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន គឺមានន័យថាជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ជននោះនឹងត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត នៅចំពោះមុខច្បាប់ដោយគ្មានការយោគយល់ និងការលើកលែងឡើយ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជនស្តែងឡើងតាមរូបភាពដូចខាងក្រោម ៖

**ក.១. ចារី**

ចារី ជាជនដែលបានប្រព្រឹត្តផ្ទាល់ ឬជាជនដៃដល់ ឬជាអ្នកប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ។ ចារី គឺជាបុគ្គលដែលអាចត្រូវដាក់ទោសដោយសារការប្រព្រឹត្តបទល្មើសមួយ មានតែអំពើរបស់ចារីទេទើបមានលក្ខណៈធាតុផ្សំបទល្មើសគ្រប់គ្រាន់។ ចារីប្រភេទនេះត្រូវបានគេចាត់ទុកថាជាអ្នកមានតួនាទីសំខាន់ ប្រសិនបើគ្មានអំពើល្មើសរបស់ចារីនោះទេ ក៏គ្មានបទល្មើសកើតឡើងដែរ។ នេះបញ្ជាក់ឱ្យឃើញពីសញ្ញាណនៃចារី គឺជាបុគ្គលដែលសម្រេចបំណងរបស់ខ្លួន ដោយការប្រព្រឹត្តបទល្មើសមួយបានសម្រេច ព្រមទាំងបុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទល្មើស។ ចារីនៃការប៉ុនប៉ង ត្រូវបានគេប្រដូចទៅនឹងចារីនៃបទល្មើសបានសម្រេចផងដែរ។ ប៉ុន្តែសម្រាប់ចារីនៃការប៉ុនប៉ងក្នុងបទមជ្ឈិម គឺទាល់តែមានច្បាប់ចែងយ៉ាងជាក់លាក់ ទើបអាចផ្តន្ទាទោសដូចទៅនឹងចារីនៃបទមជ្ឈិមបានសម្រេចដែរ[19]។ ករណីដូចជា បុរសម្នាក់បានចាក់សម្លាប់បុរសម្នាក់ទៀត ឱ្យស្លាប់ដោយសារទំនាស់ពាក្យ

[18] លេខរៀងទី ១២៧ នៃសន្ធានុក្រមនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[19] មាត្រា ២៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

សម្ដីនៅកន្លែងរាំកម្សាន្ត ដូចនេះ គាត់ជាចារីនៃបទល្មើស។

**ក.២. សហចារី**

សហចារី គឺជនដែលបានចូលរួមប្រព្រឹត្តបទល្មើសជាមួយជនដទៃទៀតដោយចូលរួមផ្ទាល់ វាមានលក្ខណៈផ្ទុយពីអ្នកសមគំនិត បានសេចក្ដីថាដើម្បីអាចចាត់ទុកថាជាសហចារីបានលុះត្រាជនទាំងនោះមានសកម្មភាពជាមួយគ្នាហើយមានវត្តមាននៅកន្លែងកើតហេតុទៀតផង[20]។ សញ្ញាណនៃសហចារីនេះ គឺយោងទៅដល់ការចូលអន្តរាគមន៍របស់រូបវន្តបុគ្គលជាច្រើនរូប នៅក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តបទល្មើស ដោយបុគ្គលទាំងនោះបានចូលរួមអន្តរាគមន៍ជាមួយនឹងកម្រិតនៃការទទួលខុសត្រូវដូចគ្នានៅក្នុងសកម្មភាព។ ក្រៅពីចារី និងសហចារី បុគ្គលផ្សេងទៀតអាចចូលរួមក្នុងការប្រព្រឹត្តបទល្មើសផងដែរ។ ដូចជាករណីលោក **ក** លោក **ខ** និងលោក **គ** បានរួមគ្នាវាយលោក **ឃ** ឱ្យរបួសធ្ងន់ធ្ងរ។ ដោយលោក **ក** ធាក់ជាច្រើនជើង លោក **ខ** វាយជាច្រើនដៃ និងលោក **គ** ជាអ្នកធាក់ឱ្យដួល ដូចនេះច្បាប់បានចាត់ទុក លោក **ក** លោក **ខ** និងលោក **គ** ជាសហចារី។

**ក.៣. អ្នកផ្ដើមគំនិត**

ជាធម្មតា អ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ។ តាមអត្ថន័យដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ត្រូវចាត់ទុកជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែល ៖

- ជម្រុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះតាមការណែនាំ ឬការបញ្ជា។
- បង្កឱ្យមានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្ដល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។ ទាល់តែបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលចារីបានប្រព្រឹត្តបានសម្រេច ឬបានប៉ុនប៉ងទើបអ្នកផ្ដើមគំនិតត្រូវបានផ្ដន្ទាទោសដូចទៅនឹងចារីប្រព្រឹត្តបទល្មើស[21]។

ហេតុដូចនេះ ដើម្បីឱ្យអ្នកផ្ដើមគំនិតមានទោសលុះត្រាតែ ៖

- **អំពើចម្បងមានទោស ៖** បទឧក្រិដ្ឋ ឬបទមជ្ឈិមបានសម្រេច ឬត្រូវបានប៉ុនប៉ង។
- **ធាតុផ្សំសត្យានុម័តនៃការផ្ដើមគំនិត ៖** គឺចង់សំដៅលើការជម្រុញតាមការណែនាំ ឬបញ្ជា ការផ្ដល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។
- **ធាតុផ្សំអត្តនោម័តនៃការផ្ដើមគំនិត ៖** អ្នកផ្ដើមគំនិត ត្រូវមានបំណងប្រព្រឹត្តអំពើផ្ដើមគំនិត មានន័យថាអ្នកផ្ដើមគំនិតបានដឹងថា អំពើរបស់ចារីជាបទល្មើសព្រហ្មទណ្ឌ ហើយខ្លួននូវតែមានចេតនាផ្ដើមគំនិតចង់ឱ្យបទ-

[20] មាត្រា ២៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[21] មាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ល្មើសនេះកើតបានទៀត។ ដូចករណីដែលលោក **ក** បានបញ្ជាឱ្យលោក **ខ** ទៅសម្លាប់លោក **គ**។ តែបើសិនលោក **ខ** ពុំបានទៅសម្លាប់លោក **គ** ទេនោះមានន័យថា អំពើចម្បងនេះពុំមានទោសទេ ព្រោះពុំមាន បទល្មើសកើតឡើង។ ហេតុនេះ អ្នកផ្ដើមគំនិតក៏ពុំមានទោសដែរ។ ក្នុងករណីនេះ អំពើរបស់លោក **ក** មិនមែនជាអ្នកផ្ដើមគំនិតដែលអាចត្រូវផ្ដន្ទាទោសបានទេ តែអំពើនេះអាចត្រូវផ្ដន្ទាទោសក្រោមបទល្មើសមួយផ្សេងទៀត ពោលគឺបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ដែលជាបទល្មើសដាច់ដោយឡែក[22]។

**ក.៤. អ្នកសមគំនិត**

សំដៅទៅលើបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្ដល់ជំនួយ ឬដោយការឧបត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិតក៏មានសញ្ញាណដូចគ្នានឹងអ្នកផ្ដើមគំនិតដែរ មានន័យថា ទាល់តែចារីបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមបានសម្រេច ឬប៉ុនប៉ង[23]។ ក្នុងលក្ខណៈប្រហាក់ប្រហែលនឹងការផ្ដើមគំនិតដែរ ការសមគំនិតនេះត្រូវបំពេញលក្ខខណ្ឌបីយ៉ាងដើម្បីឱ្យមានទោសគឺ ៖

- **អំពើចម្បងមានទោស ៖** បទឧក្រិដ្ឋ ឬបទមជ្ឈិមបានសម្រេច ឬត្រូវបានប៉ុនប៉ង។
- **ធាតុផ្សំសត្យានុម័ត ៖** ការផ្ដល់ជំនួយ ឬការឧបត្ថម្ភ។
- **ធាតុផ្សំអត្តនោម័ត ៖** អ្នកសមគំនិតដឹងថា អំពើរបស់ចារីប្រព្រឹត្តជាបទល្មើសហើយខ្លួននៅតែមានចេតនាផ្ដល់ជំនួយ ឬឧបត្ថម្ភទៀត។ ករណីដូចជាលោក **ក** បានផ្ដល់ម៉ូតូឱ្យចារីយកទៅប្រើប្រាស់ជាមធ្យោបាយក្នុងការប្រព្រឹត្តអំពើលួច ជាដើម។

**ខ. រូបវន្តបុគ្គលជាអនីតិជន**

ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ប្រសិនបើក្មេងមានអាយុ៤ឆ្នាំម្នាក់ បានគប់ដុំថ្មត្រូវក្បាលក្មេងម្នាក់ទៀតបែកក្បាលរងរបួសធ្ងន់ ហើយក្មេងដែលបានប្រព្រឹត្តអំពើល្មើសនោះ គឺមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ពីព្រោះដោយសារក្មេងម្នាក់នោះមានអាយុ ៤ឆ្នាំ គឺមិនអាចមានសមត្ថភាពដឹងខុសត្រូវ ចំពោះអំពើរបស់ខ្លួនឡើយ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី ១៨ឆ្នាំ ឡើងទៅ[24]។ មានន័យថាអនីតិជនដែលមានអាយុតិចជាង ១៨ឆ្នាំ គឺមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។ បើទោះបីជាអនីតិជនដែលបានប្រព្រឹត្តបទល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងណាក៏ដោយ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌតម្រូវឱ្យមានវិធានការដែលជាកម្មវត្ថុ ក្នុងការតាមដានវិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ហើយមិនត្រឹមតែប៉ុណ្ណោះទេ តុលាការអាចប្រកាស

[22] មាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[23] មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[24] មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[25]។

### ខ.១. វិធានការអនុវត្តចំពោះអនីតិជនក្រៅអំពីទោស

ក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទល្មើស គឺត្រូវស្ថិតនៅក្រោមការការពាររបស់តុលាការគឺតុលាការចាត់តាំងបុគ្គលមួយរូបឱ្យទទួលភារៈធ្វើការតាមដានអនីតិជនរូបនេះ។ បុគ្គលរូបនោះត្រូវធ្វើរបាយការណ៍ ស្តីពីកិរិយាមាយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនោះត្រូវផ្តល់ព័ត៌មានទាំងអស់ក្នុងរយៈពេលនៃការតាមដានរបស់ខ្លួនទៅព្រះរាជអាជ្ញា។ ដើម្បីអាចកែតម្រូវនូវវិធានការខ្លះ ចំពោះបុគ្គលិកលក្ខណៈរបស់អនីតិជននោះ[26]។ ប្រភេទនៃវិធានការតាមដាន វិធាការការពារ និងវិធានការឧបត្ថម្ភ [27] រួមមានដូចតទៅ ៖

- ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬបុគ្គលដែលអាចថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។
- ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួល។
- ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។
- ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

តុលាការជាស្ថាប័នមានសមត្ថកិច្ច ក្នុងការចាត់វិធានការ[28] ប៉ុន្តែក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ គឺពុំបានចែងលម្អិតអំពីនីតិវិធីពិសេសសម្រាប់ការចាត់វិធានការទាំងអស់នេះឱ្យមានប្រសិទ្ធិភាពនោះទេ។

### ខ.២. ទណ្ឌកម្មព្រហ្មទណ្ឌចំពោះអនីតិជន

សម្រាប់អនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ គឺតុលាការអាចប្រកាសទណ្ឌកម្មបាន។ ទណ្ឌកម្មព្រហ្ម-ទណ្ឌដែលក្រមព្រហ្មទណ្ឌសំដៅនោះគឺទោស។ ការកំណត់អាយុ ១៤ឆ្នាំ សម្រាប់លទ្ធភាពនៃការប្រកាសទណ្ឌកម្ម ស្របតាមប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឱ្យមានការឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទជាបណ្តោះអាសន្ន [29]។

ចំណែកឯអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ វិញ គឺមិនអាចទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ ទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ ក៏អនីតិជននោះមិនអាចឃុំខ្លួនបណ្តោះ

---

[25] មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[26] មាត្រា ៤១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[27] មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[28] មាត្រា៤០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[29] មាត្រា ២១៣ និងមាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អាសន្នបានទេ ក៏ប៉ុន្តែចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះទៅឱ្យឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្នរង់ចាំសេចក្ដីសម្រេចរបស់តុលាការ[30]។

ក៏ប៉ុន្តែតុលាការអាចចាត់វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបតម្ភ ចំពោះអនីតិជន[31]។

ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដូចជា ៖ បទឃាតកម្មជាដើម កាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនេះអាចជាមូលហេតុនាំឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនបាន។ ដូចករណីដែលកុមារម្នាក់មានអាយុ ១៤ឆ្នាំ បានលួចកង់របស់គេ។ តើក្នុងករណីមួយនេះតម្រូវឱ្យតុលាការប្រកាសទោសលើអនីតិជននេះដែរឬទេ ? ក្នុងករណីនេះ ការដែលតុលាការត្រូវប្រកាសដាក់ទណ្ឌកម្មលើអនីតិជននោះ ត្រូវបន្ថយក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- អតិបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល។
- ប្រសិនអតិបរមានៃទោសដាក់ពន្ធនាគារ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ឆ្នាំ។
- អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្ដាលប្រសិនបើ អប្បបរមានេះលើសពី ១ថ្ងៃ។
- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្ដាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ មានអនុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលត្រូវចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល[32]។

### ១.៤.២. នីតិបុគ្គល

នីតិបុគ្គលជាក្រុមមនុស្ស ឬជាមូលនិធិដែលមានបុគ្គលភាពគតិយុត្តហើយជាម្ចាស់ នៃសិទ្ធិនិងកាតព្វកិច្ច[33]។ ជាទូទៅនីតិបុគ្គលមានពីរប្រភេទគឺ នីតិបុគ្គលសាជីវកម្ម និងនីតិបុគ្គលមូលនិធិ។ នីតិបុគ្គលសាជីវកម្ម ជាក្រុមដែលមានសមាជិកហើយត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ[34]។ រីឯនីតិបុគ្គលមូលនីធិ ជាចំណែកទ្រព្យសម្បត្តិភាគទានដែលត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ

[30] មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[31] មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[32] មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[33] លេខរៀងទី ៧១ នៃសន្ទានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧

[34] មាត្រា ៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

និងកាតព្វកិច្ចដោយឯករាជ្យ។ នីតិបុគ្គលលើកលែងតែរដ្ឋចេញ ដែលត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ មិនត្រឹមតែក្រមព្រហ្មទណ្ឌទេ ដែលមានកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ក៏មានការកំណត់អំពីការទទួលខុសត្រូវនៅក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀតផងដែរ[35]។ នីតិបុគ្គល គឺមិនត្រឹមតែទទួលទណ្ឌកម្មដូចដែលមានចែង ក្នុងក្រមព្រហ្មទណ្ឌនោះទេ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ក៏បានចែងពីការដាក់ទោសនីតិបុគ្គលដែរ។ នៅពេលក្រុមហ៊ុនមួយ ផ្តល់សិទ្ធិឱ្យតំណាងរបស់ខ្លួន ឬបុគ្គលដឹកជញ្ជូននូវទំនិញដែលជាផលប្រយោជន៍របស់ខ្លួន ហើយបុគ្គលជាអ្នកបើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន មិនគោរពច្បាប់ បណ្តាលឱ្យអ្នកដទៃរបួស ឬអសមត្ថភាពប្រកបការងារ ឬបណ្តាលឱ្យស្លាប់ ក៏ត្រូវទទួលទោសទណ្ឌកម្មដែរ [36]។ នីតិបុគ្គលត្រូវផ្តន្ទាទោសជាប្រាក់ ហើយព្រមទាំងបន្ថែមទោសមួយ ឬច្រើនដូចខាងក្រោមនេះទៀត ៖

- ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល[37]។
- ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ[38]។
- ការហាមឃាត់ចំពោះការធ្វើសកម្មភាព[39]។
- ការបិទគ្រឹះស្ថានប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស[40]។
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្ម លើគ្រឹះស្ថាន ដែលបើកជំហរដល់សាធារណជន ឬដែលប្រើប្រាស់ដល់សាធារណជន[41]។
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស[42]។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍[43]។

កាលបើលក្ខខណ្ឌដែលកំណត់ដោយច្បាប់មានគ្រប់គ្រាន់ហើយ នីតិបុគ្គលនឹងត្រូវប្រកាសថាត្រូវទទួល

[35] មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[36] មាត្រា៨៥ និងមាត្រា ៨៦ នៃច្បាប់ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៥
[37] មាត្រា ១៧០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[38] មាត្រា ១៧១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[39] មាត្រា ១៧២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[40] មាត្រា ១៧៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[41] មាត្រា ១៧៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[42] មាត្រា ១៨០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[43] មាត្រា ១៨១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ទោសព្រហ្មទណ្ឌបានហើយ នឹងត្រូវទទួលទណ្ឌកម្មដូចដែលមានចែងនៅក្នុងច្បាប់។ បើមានបទប្បញ្ញត្តិពិសេសចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលក្តី ក៏ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយយោងទៅតាមទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល[44]។

ជាធម្មតា គេរមែងគិតថាការទទួលខុសត្រូវព្រហ្មទណ្ឌអាចមានសម្រាប់តែរូបវន្តបុគ្គលតែប៉ុណ្ណោះ ឬនិយាយមួយបែបទៀតថាមនុស្សទើបអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន ក៏ប៉ុន្តែតាមការពិត ក្រមព្រហ្មទណ្ឌក៏បានប្បញ្ញត្តិអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលផងដែរ។

### ក. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

ក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលមិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ[45]។

ដូច្នេះយើងអាចកំណត់បានថា នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌកាលបើមានលក្ខខណ្ឌដូចខាងក្រោម ៖

#### ក.១. ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត

នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌកាលបើច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានចែងយ៉ាងច្បាស់ថា នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ បទល្មើសណាមួយជាកំណត់[46]។ ចំពោះបទល្មើសដែលជា បទឃាតកម្ម នៃក្រមព្រហ្មទណ្ឌអំពី បទឃាតកម្ម ក្រមព្រហ្មទណ្ឌពុំបានចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលទេ មានន័យថានីតិបុគ្គលមិនអាចត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌពីបទឃាតកម្មឡើយ។ ដូចនៅក្នុងករណីដែល ប្រធានក្រុមហ៊ុន **ក** បានទៅសម្លាប់ ប្រធានក្រុមហ៊ុន **ខ** ដោយសារតែការប្រកួតប្រជែងគ្នាផ្នែកពាណិជ្ជកម្ម។ តាមសម្មតិកម្មនេះ តុលាការត្រូវផ្តន្ទាទោសប្រធានក្រុមហ៊ុន **ក** ពីបទឃាតកម្ម ក្នុងនាមជារូបវន្តបុគ្គល ប៉ុន្តែតុលាការមិនអាចផ្តន្ទាទោសក្រុមហ៊ុន **ក** ពីបទឃាតកម្មឡើយ ពីព្រោះថា ពុំមានច្បាប់អនុញ្ញាតឱ្យធ្វើដូច្នេះ ។

---

[44] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[45] មាត្រា ៤២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[46] មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ផ្ទុយទៅវិញ ទាក់ទងនឹងបទមនុស្សឃាតដោយអចេតនា បានចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ចំពោះបទល្មើសប្រភេទនេះ ជាការពិតការចែងយ៉ាងដូច្នេះមានន័យថា នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទមនុស្សឃាតដោយអចេតនាបាន។

**ក.២. បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងនីតិបុគ្គល**

ជាក់ស្តែង នៅក្នុងក្របខ័ណ្ឌនៃនីតិបុគ្គល គេរមែងសង្កេតឃើញថាមានអង្គការតំណាងនីតិបុគ្គលក្រោមរូបភាពជាក្រុមប្រឹក្សា ឬអ្នកតំណាងណាម្នាក់នៃនីតិបុគ្គល។ អង្គភាពតំណាង ឬអ្នកតំណាងនៃនីតិបុគ្គល គឺជាជនដែលច្បាប់ ឬលក្ខន្តិកៈផ្តល់នូវមុខងារជាអ្នកដឹកនាំគ្រប់គ្រង ហើយមាននីតិសម្បទាគ្រប់គ្រាន់ ក្នុងការសម្រេចសេចក្តីដែលអាចឱ្យនីតិបុគ្គលទទួលខុសត្រូវបាន ឬនិយាយម្យ៉ាងទៀតថាជាអង្គភាព ឬអ្នកតំណាងដែលមានសមត្ថភាពក្នុងការប្រព្រឹត្តអំពើណាមួយក្នុងនាមនីតិបុគ្គល។

អ្នកតំណាងដែលមានសមត្ថភាពក្នុងការប្រព្រឹត្តអំពើណាមួយក្នុងនាមនីតិបុគ្គលមាន ៖ ក្រុមប្រឹក្សាភិបាល ឬសន្និបាតរបស់ក្រុមហ៊ុនណាមួយ ក្រុមប្រឹក្សាឃុំសង្កាត់ ប្រធានសមាគម បណ្ណាធិការ អភិបាល ( អ្នកគ្រប់គ្រងក្រុមហ៊ុន ) មេឃុំ ចៅសង្កាត់ គឺជាអង្គភាពតំណាងរបស់ សមាគម ក្រុមហ៊ុន ឃុំសង្កាត់ ដែលជានីតិបុគ្គល។

**ក.៣. ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល**

លក្ខខណ្ឌនេះមានន័យថា មានតែការប្រព្រឹត្តបទល្មើស ក្នុងបំណងផ្តល់ជាប្រយោជន៍ដល់នីតិបុគ្គលតែប៉ុណ្ណោះ ដែលជាកត្តាធ្វើឱ្យនីតិបុគ្គលនោះទទួលខុសត្រូវព្រហ្មទណ្ឌបាន។ ករណីដូចជាអភិបាលរបស់ក្រុមហ៊ុនមួយមិនបានចាត់វិធានការសន្តិសុខគ្រប់គ្រាន់តាមច្បាប់ ដើម្បីធានាសុវត្ថិភាពដល់កម្មករនិយោជិតរបស់ក្រុមហ៊ុនទេ ព្រោះតែមិនចង់ឱ្យក្រុមហ៊ុនចំណាយប្រាក់ច្រើនក្នុងការចាត់វិធានការសន្តិសុខបែបនេះ។ ម្យ៉ាងទៀត អំពើនេះបានធ្វើឡើងដើម្បីជាប្រយោជន៍របស់នីតិបុគ្គល ដូច្នេះនីតិបុគ្គលត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ។

យ៉ាងណាមិញ បទល្មើសដែលបានប្រព្រឹត្តដោយអ្នកតំណាងនីតិបុគ្គល ប៉ុន្តែក្នុងប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកតំណាងសុទ្ធសាធ ក្នុងករណីនេះ គឺមិនអាចឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ ដូចក្នុងករណី ក្រុមហ៊ុនមួយ ត្រូវបានបង្កើតឡើងដោយមានកម្មវត្ថុដើម្បីបើកផ្តល់សេវាម៉ាស្សា ។ ដោយឡែកនៅក្នុងការគ្រប់គ្រងនេះ អ្នកគ្រប់គ្រងហាងម៉ាស្សា បានផ្តល់លទ្ធភាពអនុគ្រោះសម្រាប់ឱ្យមានការប្រកបរបរពេស្យាចារនៅក្នុងហាង ហើយបានកាត់យកប្រាក់ពីនារីពេស្យាដើម្បីទុកជាប្រយោជន៍របស់ខ្លួនផ្ទាល់។ ទង្វើបែបនេះជាបទល្មើសយល់ព្រមឱ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន និងសញ្ជារកម្ម តែអំពើនេះបានធ្វើឡើងដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកគ្រប់គ្រង ព្រោះថាប្រាក់កម្រៃដែលបានកាត់យកពីនារីពេស្យា ត្រូវអ្នកគ្រប់គ្រងនោះរក្សាទុកសម្រាប់ខ្លួនឯង។ ក្នុងករណីនេះច្បាប់មិនចាប់បង្ខំឱ្យនីតិបុគ្គល ទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ ពោលគឺ អ្នកគ្រប់គ្រងខ្លួនឯង ដែលជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។

ការកំណត់នូវទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល[47] រួមមាន ៖

- ទោសពិន័យក្នុងឋានៈជាមូលទោស ។
- ទោសបន្ថែម ។

**ខ. ទោសបន្ថែមសម្រាប់អនុវត្តចំពោះនីតិបុគ្គល**

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ដូចជា ៖

- ការរំលាយ
- ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ
- ការហាមឃាត់ធ្វើសកម្មភាពណាមួយ ឬច្រើន
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ
- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ
- ការហាមឃាត់ចំពោះឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ឬដែលកំណត់ដោយធនាគារ
- ការហាមឃាត់ចំពោះការប្រើប័ណ្ណទូទាត់
- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់ ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស
- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលកើតចេញពីបទល្មើស
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុក្នុងទីកន្លែង ដែលបទល្មើសបានប្រព្រឹត្ត
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមទូរគមនាគមន៍សោតទស្សន៍។

[47] មាត្រា ១៦៧ និងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

## ១.៥. ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

មានមូលហេតុមួយចំនួន ទោះបីបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្ត ហើយគេបានរកឃើញជនដែលត្រូវទទួលខុសត្រូវចំពោះបទល្មើសក៏ដោយ ក៏ការទទួលខុសត្រូវនេះលែងមានទៅវិញ ក្នុងករណីដែលច្បាប់បានចែងយ៉ាងច្បាស់លាស់ ព្រោះការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ បណ្តាលមកពីមូលហេតុណាមួយដែលច្បាប់ព្រហ្មទណ្ឌចាត់ទុកថា ជាមូលហេតុត្រឹមត្រូវ។ ដោយហេតុថា អ្នកប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺមានអាយុតិចជាងការកំណត់របស់ច្បាប់ ឬមានបញ្ហាវិបល្លាសស្មារតីជាដើម។

### ១.៥.១. វិបល្លាសស្មារតី

វិបល្លាសស្មារតី គឺចង់សំដៅលើវិបត្តិដែលធ្វើឱ្យមានភាពរីករាលដល់ សកម្មភាពសសៃប្រសាទរបស់មនុស្សដែលធ្វើឱ្យមនុស្សបាត់បង់ការដឹងខុសត្រូវលើរាល់សកម្មភាពរបស់ខ្លួន។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ដោយសារតែប្រព័ន្ធសរសៃប្រសាទមានសកម្មភាពមិនប្រក្រតី ចារីបានបាត់បង់លទ្ធភាពយល់ដឹងពីពិភពខាងក្រៅជុំវិញខ្លួន ហើយពុំអាចត្រួតពិនិត្យសកម្មភាពរបស់ខ្លួនបាន។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវ គេត្រូវតែរកភស្តុតាងមកបញ្ជាក់ពីអត្ថិភាពនៃវិបល្លាសស្មារតីដែលបានកើតមានចំពោះចារីនៅពេលដែលចារីបានប្រព្រឹត្តអំពើល្មើស។ ជាទូទៅភស្តុតាងនៃវិបល្លាសស្មារតីត្រូវបញ្ជាក់ដោយវេជ្ជបណ្ឌិតជំនាញ ក៏ប៉ុន្តែយោបល់ទាំងនោះ គឺពុំមានអានុភាពចងជាកាតព្វកិច្ចឱ្យចៅក្រមត្រូវតែជឿជាក់តាមនោះទេ ពោលគឺចៅក្រមអាចជឿក៏បាន មិនជឿក៏បាន។ ដូចក្នុងករណីដែល ជនវិកលចរិតម្នាក់មិនអាចឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តឡើយ កាលបើមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់យ៉ាងច្បាស់លាស់ពីវិបល្លាសស្មារតីរបស់ជននេះ។

ផ្ទុយទៅវិញប្រសិនបើជនណាម្នាក់បានប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដោយសារ ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ឬសារធាតុដែលច្បាប់បានហាមឃាត់ គឺមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ[48]។

### ១.៥.២. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

អាជ្ញាធរស្របច្បាប់ គឺសំដៅដល់អាជ្ញាធរសារធារណៈ ដែលជាអាជ្ញាធររដ្ឋបាល ឬអាជ្ញាធរតុលាការ ឬអាជ្ញាធរយោធា ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឱ្យអនុវត្តច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ។ យ៉ាងណាមិញ ការបញ្ជាពីនិយោជក ឬឪពុកម្តាយ គឺមិនមែនជាការបញ្ជាពីអាជ្ញាធរស្របច្បាប់នោះទេ។

[48] មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានប្បញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់បុគ្គលនោះ គឺមិនប្រព្រឹត្តបទល្មើសទេ។ ហេតុដូច្នេះហើយ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះ គឺមិនប្រព្រឹត្តបទល្មើសនោះទេ លើកលែងតែអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់[49] ។

- **ការអនុញ្ញាតដោយច្បាប់ ៖** ក្នុងករណីនេះច្បាប់ប្បញ្ញត្តិ ឬអនុញ្ញាតឱ្យប្រព្រឹត្តអំពើណាមួយ ហើយច្បាប់មិនអនុញ្ញាតឱ្យផ្តន្ទាទោស លើអំពើដែលកើតចេញពីការបំពេញកាតព្វកិច្ចតម្រូវដោយច្បាប់ឡើយ។
- **ការអនុញ្ញាតដោយអាជ្ញាធរ ៖** បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់បុគ្គលនោះ គឺមិនត្រូវចាត់ទុកថាប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនោះជាអំពើខុសច្បាប់។
- **បញ្ជាស្របច្បាប់ ៖** ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឱ្យជនដែលប្រព្រឹត្តបទល្មើស តាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើនោះជាអំពើខុសច្បាប់។

ដូចនៅក្នុងករណីដែល ៖

- ការចាប់ខ្លួនជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដោយប្រជាពលរដ្ឋ [50]

- មន្ត្រីនគរបាលយុត្តិធម៌ (OPJ) ដែលច្បាប់អនុញ្ញាតឱ្យឃាត់ខ្លួន ជនល្មើសណាមួយនោះមិនត្រូវមានកំហុសថាជាការរំលោភបំពានលើរូបរាងកាយជនល្មើសនោះទេ

- ការវះកាត់ដោយគ្រូពេទ្យជំនាញទៅលើអ្នកជម្ងឺ មិនត្រូវមានទោសពីការបង្ករបួសស្នាមក្នុងពេលវះកាត់អ្នកជម្ងឺឡើយ។

- **ការបញ្ជាមានលក្ខណៈអនីត្យានុកូល ៖** ប្រសិនបើការបញ្ជាមានលក្ខណៈខុសច្បាប់យ៉ាងជាក់ច្បាស់ តម្រូវឱ្យអ្នកដែលទទួលបញ្ជាអនីត្យានុកូល ត្រូវទទួលទោសតាមប្បញ្ញត្តិច្បាប់[51]។ លើសពីនេះទៅទៀត នៅក្នុងការវាយតម្លៃកំណត់ថាការបញ្ជាណាមាន លក្ខណៈជាអនីត្យានុកូល គឺអាស្រ័យទៅលើសមត្ថភាព បទពិសោធន៍ និងឋានៈរបស់អ្នកទទួលបញ្ជានោះ។

ដូចទៅនឹងអំពើដែល មន្ត្រីនគរបាលម្នាក់បានបញ្ជាឱ្យមន្ត្រីក្រោមឱវាទរបស់ខ្លួន វាយលើជនដែលមានទំនាស់ពាក្យសម្តីជាមួយគាត់ នៅក្នុងគ្រោះថ្នាក់ចរាចរណ៍។ ទង្វើបែបនេះគឺជាការបញ្ជារមួយមានលក្ខណៈអនីត្យានុកូលយ៉ាងជាក់ច្បាស់ ។

ដោយឡែក ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបី

[49] មាត្រា ៣២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[50] មាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[51] មាត្រា ៣២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ ៖

- ជនល្មើសនោះបានប្រព្រឹត្តអំពើដែលប្បញ្ញត្តិអនុញ្ញាត ឬមិនហាមឃាត់ ដោយច្បាប់ជាធរមាន។
- បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់។

ដូចក្នុងករណីដែល ច្បាប់ជាធរមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអនុញ្ញាតឱ្យ មានការសម្លាប់មនុស្សដូចសម័យកាលនោះក្ដី ក៏ជនទាំងឡាយដែលធ្វើតាមការអនុញ្ញាតដោយច្បាប់នេះ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន ដោយសំអាងពីការអនុញ្ញាតដោយច្បាប់បានឡើយ។

### ១.៥.៣. ការការពារស្របច្បាប់

ជាការពិតនៅក្នុងគ្រប់ស្ថានភាពនៃអំពើនៃការបង្ខិតបង្ខំ ការគំរាមគំហែង ឬជាអំពើដែលបានដាក់សម្ពាធទៅលើបុគ្គលណាម្នាក់ ច្បាស់ណាស់បុគ្គលនោះនឹងបញ្ចេញកម្លាំង ក្នុងការតបតវិញនៅក្នុងស្ថានភាពនៃការការពារខ្លួន។ បុគ្គលណាដែលបានប្រព្រឹត្តបទល្មើស ក្នុងស្ថានភាពនៃការការពារស្របច្បាប់ គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ[52]។ តាមច្បាប់ លក្ខខណ្ឌនៃការការពារស្របច្បាប់រួមមានដូចខាងក្រោម ៖

- បទល្មើសត្រូវចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយ ដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា។
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។

ទាក់ទងទៅនឹងការចាត់ទុកចំពោះសកម្មភាពមួយចំនួនដែលមិនមែនជាការការពារស្របច្បាប់ និងអំពើដែលចាត់ទុកថាជាការការពារស្របច្បាប់ ក្នុងករណីម្ចាស់ផ្ទះបានបាញ់សម្លាប់ចោរដែលចូលផ្ទះរបស់គាត់ នៅក្នុងពេលដែលចោរនោះបានដាក់កាំភ្លើងចុះ ឬបានព្យាយាមរត់គេច។ អំពើនេះមិនមែនជាការការពារខ្លួនស្របច្បាប់ទេ គឺជាបទឃាតកម្ម។

ផ្ទុយទៅវិញ ប្រសិនបើចោរមានបំណងសម្លាប់ម្ចាស់ផ្ទះ ដោយបានបាញ់ និងដើរសំដៅមករកម្ចាស់ផ្ទះជាមុន ហើយម្ចាស់ផ្ទះ ក៏បានសម្រេចចិត្តបាញ់តបតទៅវិញក្នុងពេលភ្លាមៗនោះ ដើម្បីអាចរក្សាជីវិតរបស់ខ្លួនត្រង់ចំណុចនេះ គឺអាចចាត់ទុកថាជាការការពារស្របច្បាប់បាន ។

### ១.៥.៤. ស្ថានភាពចំបាច់

ស្ថានភាពចាំបាច់ គឺជាស្ថានភាពរបស់បុគ្គលម្នាក់ ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយ ដោយសារតែចារីមានបំណង ចង់ជួយស្ដារនូវផលប្រយោជន៍ណាមួយផ្សេងទៀត ដែលត្រូវបានគំរាមគំហែង

[52] មាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ដោយគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលហៀបនឹងកើតឡើង។

ដូចច្នេះស្ថានភាពចាំបាច់ ចារីមានជម្រើសពីរយ៉ាងគឺៈ

- ទទួលយកការខូចខាតដែលនឹងត្រូវកើតមានឡើង ដោយសុខចិត្តបដិសេធមិនព្រមប្រព្រឹត្តបទល្មើស។
- ត្រូវតែប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត។

ស្ថានភាពចាំបាច់ត្រូវបានចាត់ទុកថាជាយុត្តិកម្មនៃបទល្មើស តាមក្រមព្រហ្មទណ្ឌបានចែងថា បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវប្រព្រឹត្តបទល្មើស នឹងមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ[53]។ ស្ថានភាពចាំបាច់ត្រូវមានលក្ខណៈ ដូចខាងក្រោម ៖

- បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ ដើម្បីការពារខ្លួន ការពាអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងទៅនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។ គ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន ជនដែលប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ ត្រូវរកភស្តុតាងអំពីគ្រោះថ្នាក់ដែលជម្រុញឱ្យប្រព្រឹត្តបទល្មើស។
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។ ចារីត្រូវរកភស្តុតាងមកបង្ហាញឱ្យឃើញច្បាស់ថា បទល្មើសដែលខ្លួនបានប្រព្រឹត្តមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់។ ផលវិបាកនៃបទល្មើសត្រូវតែមានតម្លៃតិចជាង ឬស្មើនឹងតម្លៃដែលចារីមានបំណងចង់ជួយស្រោចស្រង់នឹងសង្គ្រោះ។

ដូចក្នុងករណីដែល ដើម្បីកុំឱ្យកូនអត់អាហារស្លាប់ នារីជាស្ត្រីមេម៉ាយបានសុខចិត្តលួចប៉ះផ្លែដូងគេមួយផ្លែដើម្បីឱ្យកូនហូប ឬក្នុងស្ថានភាពមួយដើម្បីបញ្ចៀសកុំឱ្យភ្លើងឆេះផ្ទះរបស់ខ្លួនអស់ បុរសម្នាក់បានរត់ទៅយកបំពង់ពន្លត់អគ្គីភ័យរបស់អ្នកជិតខាងដោយគ្មានការអនុញ្ញាត ដើម្បីយកមកពន្លត់ភ្លើងដែលកំពុងឆេះផ្ទះរបស់គាត់។

### ១.៥.៥. អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលបុគ្គលនោះមិនអាចទប់ទល់បាន បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ កម្លាំង និងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់បុគ្គលតែប៉ុណ្ណោះ ហើយកម្លាំង និងការបង្ខំនេះគឺមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបានទេ[54]។ កាលបើមានភស្តុតាងថា មានកម្លាំងអ្វីមួយបានបង្ខំជនណាម្នាក់ឱ្យប្រព្រឹត្តបទល្មើសអ្វីមួយ ហើយជននោះកាលបើ មិនអាចទប់ទល់នឹងកម្លាំងនោះបានទេ ក៏ប្រព្រឹត្តបទល្មើសនោះទៅ ជនដែលប្រព្រឹត្តបទល្មើសនេះមិនត្រូវឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឡើយ។ ដូចក្នុងករណីដែលមានកម្លាំង

[53] មាត្រា ៣៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[54] មាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ធម្មជាតិរន្ធះបាញ់បានបាញ់កង់រថយន្ត បណ្តាលឱ្យអ្នកបើកបររថយន្តម្នាក់ ពុំអាចទប់ចង្កូតរថយន្តបាន ហើយក៏បានជ្រុលរថយន្តទៅបុកអ្នកថ្មើរជើងម្នាក់ស្លាប់បាត់បង់ជីវិត។

## ១.៦. ប្រភេទនៃទោសដែលត្រូវអនុវត្ត

តាមច្បាប់ជាធរមាន ទោសគឺជាទណ្ឌកម្មសម្រាប់ផ្តន្ទាទៅលើជនទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ព្រមជាមួយគ្នានេះ ទោសត្រូវបានកំណត់ឡើងនៅក្នុងគោលដៅ ដើម្បីការពារផលប្រយោជន៍សាធារណៈ ដែលជាផលប្រយោជន៍របស់សង្គមទាំងមូល។ ផ្អែកតាមបទប្បញ្ញតិនៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ទោសមានចំនួនបីប្រភេទគឺ ៖ មូលទោស ទោសបន្ថែម និងទោសជំនួស។

### ១.៦.១. មូលទោស

តាមគោលការណ៍ គ្រប់បទល្មើសទាំងអស់សុទ្ធតែត្រូវផ្តន្ទាទោស យ៉ាងហោចណាស់ជាមូលទោសមួយ។ ជាក់ស្តែងមូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ចំណែកឯទោសប្រហារជីវិតត្រូវបានលុបចោល[55]។ ជាទូទៅ ទោសដាក់ពន្ធនាគារជាទោសដែលបំបាត់ចោលស្ទើរតែទាំងស្រុងនូវសេរីភាពជាមូលដ្ឋាន ដោយមានកាលកំណត់ជាក់លាក់ ដែលច្បាប់តែងតែកំណត់នូវអប្បបរមា និងអតិបរមានៃទោស។ ក៏ប៉ុន្តែយោងតាមក្រមព្រហ្មទណ្ឌ ទោសដាក់ពន្ធនាគារក៏អាចជាទោសដាក់ពន្ធនាគារអស់មួយជីវិតផងដែរ។ នៅក្នុងករណីដែលជាទោសដាក់ពន្ធនាគារមានកាលកំណត់នោះអតិបរមាខ្ពស់បំផុត គឺមានចំនួន ៣០ឆ្នាំ[56]។

ចំណែកឯទោសពិន័យជាប្រាក់វិញ គឺជាទោសដែលតម្រូវអោយទណ្ឌិតបង់ចំនួនប្រាក់ តាមការកំណត់ដោយច្បាប់។ ចំពោះទឹកប្រាក់នេះ ត្រូវកំណត់ជាប្រាក់រៀល។ សូមបញ្ជាក់ថា ប្រាក់ដែលជាផលនៃការពិន័យត្រូវទុកជាប្រាក់ចំណូលសម្រាប់ថវិការជាតិ ដោយត្រូវយកទៅរក្សាទុកនៅក្នុរតនាគារជាតិ។

### ១.៦.២. ទោសបន្ថែម

ជាគោលការណ៍ ទោសបន្ថែមគឺជាទោសដែលតុលាការប្រកាសបន្ថែមទៅលើមូលទោស។ ប៉ុន្តែទោសបន្ថែមនិងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយ ជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិមឬបទលហុដែលត្រូវចោទប្រកាន់ តាមបទប្បញ្ញត្តិនីមួយៗ។ ម្យ៉ាងទៀត ក្នុងករណីដែលច្បាប់កំណត់ថាទោសបន្ថែមត្រូវតែប្រកាសជាកាតព្វកិច្ចនោះ បានសេចក្តីថាតុលាការត្រូវតែប្រកាសទោសបន្ថែមជាដាច់ខាត[57]។ ដូចក្នុងករណីច្បាប់ បានតម្រូវឱ្យត្រូវតែរឹបអូសយកនូវរាល់វត្ថុតាងនៃបទល្មើសជលផល[58] ។

---

[55] មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

[56] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[57] មាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[58] មាត្រា ៨៩ នៃច្បាប់ស្តីពីជលផល ឆ្នាំ២០០៦

ស្របជាមួយគ្នានេះ ចៅក្រមអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន មានអត្ថន័យថាចៅក្រមអាចប្រកាសទោសបន្ថែមជំនួសឱ្យមូលទោសបាន ដោយមិនចាំបាច់ប្រកាសមូលទោសទេ កាលបើលក្ខខណ្ឌដែលច្បាប់តម្រូវត្រូវបានបំពេញយ៉ាងច្បាស់លាស់[59]។

ដូចគ្នានេះដែរ ចំពោះបទបរិហារកេរ្តិ៍ជាសាធារណៈ តុលាការអាចប្រកាសឱ្យផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ដែលជាទោសបន្ថែម ជំនួសឱ្យការផ្ដន្ទាទោសជាប្រាក់ ក៏បានដែរ។

**១.៦.៣. ទោសជំនួស**

យ៉ាងណាមិញទោសជំនួសអាចត្រូវតុលាការយកមកប្រើប្រាស់ ជំនួសមូលទោសចំពោះការប្រព្រឹត្តបទល្មើសណាមួយ។ ក្នុងករណីនេះ តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ[60] ទោសជំនួសមានចំនួនពីរប្រភេទ ពោលគឺការងារសហគមន៍ និងការស្ដីបន្ទោស។

**ក. ការងារសហគមន៍**

អនុលោមតាមក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសទោសការងារសហគមន៍បាន កាលណាជនជាប់ចោទទទួលនូវការផ្ដន្ទាទោសដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬស្មើនឹង ៣ឆ្នាំ។ ការងារសហគមន៍ គឺជាកាតព្វកិច្ចដែលត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ម៉ោង ទៅ ២០០ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ (ឃុំ ឬសង្កាត់) ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល។ ការងារសហគមន៍ពុំអាចបំពេញជាផលប្រយោជន៍នៃរូបវន្តបុគ្គលនោះទេ។ ភ្ជាប់ជាមួយករណីដែលបុរសម្នាក់ បានលួចមាន់របស់អ្នកជិតខាងហើយត្រូវបានឃាត់ខ្លួន។ ហេតុដូច្នេះ តុលាការអាចប្រកាសឱ្យគាត់ ធ្វើការងារសហគមន៍ដោយឱ្យគាត់ ធ្វើការងារបោះសំអាតទីស្នាក់ការឃុំដែលគាត់រស់នៅសម្រាប់រយៈពេល ៥០ម៉ោង។ ក្នុងករណីនេះ តុលាការមិនសម្រេចផ្ដន្ទាទោសឱ្យគាត់ជាប់ពន្ធនាគារឡើយ ដោយសម្រេចយកតែទោសការងារសហគមន៍ដែលជាទោសជំនួសមកអនុវត្តសម្រាប់គាត់វិញ។

**ខ. ការស្ដីបន្ទោស**

តុលាការអាចនឹងប្រកាសទោសជំនួស គឺការស្ដីបន្ទោសបាន កាលបើជនជាប់ចោទទទួលរងនូវការផ្ដន្ទាទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ឆ្នាំ ហើយប្រសិនបើបានបំពេញលក្ខខណ្ឌបីយ៉ាងពោលគឺ[61] ៖

- ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈបង្កដោយបទល្មើសត្រូវបានបញ្ចប់។

[59] មាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[60] មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[61] មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

- ការខូចខាតត្រូវបានជួសជុលហើយនិង
- ជនជាប់ចោទបង្ហាញការជានាក្នុងការចូលទៅរួមរស់ក្នុងសង្គមវិញ។

ដូចក្នុងករណី បុរសម្នាក់ បានចូលបរិភោគអាហារនៅក្នុងភោជនីយដ្ឋានមួយ ដោយដឹងថាខ្លួនមិនមានប្រាក់គ្រប់គ្រាន់សម្រាប់បង់ទេ។ អំពើបែបនេះគឺជាបទបន្លំ ដូចច្នេះ ជំនួសឱ្យការប្រកាសទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ តុលាការអាចសម្រេចប្រកាសការស្តីបន្ទោសទៅលើបុរសម្នាក់នោះ បន្ទាប់ពីគាត់បានយល់ព្រមទទួលស្គាល់កំហុសរបស់ខ្លួន ហើយក្រុមគ្រួសាររបស់គាត់ បានបង់ប្រាក់ថ្លៃអាហារឱ្យម្ចាស់ភោជនីយដ្ឋានរួចហើយដែរ។

# ជំពូកទី ២
# បទល្មើសហិង្សាដោយចេតនា

# ជំពូកទី២
# បទល្មើសហិង្សាដោយចេតនា

## កថាខណ្ឌទី១ ៖ បទល្មើសហិង្សាដោយចេតនា

### ២.១. និយមន័យនៃបទល្មើសហិង្សាដោយចេតនា

គួររំលឹកថា អំពើដែលបង្កឱ្យអ្នកដទៃមានរបួសដោយចេតនា ក្នុងក្រមព្រហ្មទណ្ឌចាស់ ឆ្នាំ១៩៦៤ បាន កំណត់ឈ្មោះបទល្មើសនេះថាជាបទ វិហិង្សាដោយចេតនា (មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌចាស់)។ ក្រោយមកបទល្មើសនេះ ត្រូវបានឱ្យឈ្មោះទៅជាបទ បង្ករបួសស្នាមដោយចេតនា (មាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល)។ ដោយឡែក ក្រមព្រហ្មទណ្ឌបានកំណត់ឈ្មោះបទល្មើសនេះថាជាបទ ហិង្សាដោយចេតនា វិញ។

បទល្មើសហិង្សាដោយចេតនា គឺជាអំពើដែលបណ្តាលឱ្យមានផលប៉ះពាល់ជាច្រើនដល់លើបូរណភាពរូបកាយ ផ្លូវចិត្ត សេដ្ឋកិច្ច និងការឈ្លានពានខាងផ្លូវភេទដែលប្រព្រឹត្តដោយ រូបវន្តបុគ្គល សហព័ទ្ធ ឬអនីតិសង្វាសជន ឬនីតិបុគ្គល ទៅលើជនរងគ្រោះ ជាដើម។

#### ២.១.១. លក្ខខណ្ឌ

តាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[62] បានកំណត់ថា បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះតែអំពើផ្ទាល់របស់ខ្លួនប៉ុណ្ណោះ។ តាមរយៈស្មារតីគោលការណ៍នេះ បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទហិង្សាដោយចេតនា ប្រសិនបើអំពើនៃបទល្មើសនេះ បានបំពេញគ្រប់ធាតុផ្សំនៃបទល្មើស។

#### ២.១.២. ធាតុផ្សំនៃបទល្មើស

ចំពោះធាតុផ្សំសំខាន់ៗ ក្នុងបទល្មើសហិង្សាដោយចេតនានេះមានបីគឺ ៖ (**ក**) ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់ (**ខ**) ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ និង (**គ**) ធាតុផ្សំអត្តនោម័ត ឬធាតុចិត្តសាស្ត្រ។

##### ក. ធាតុផ្សំនីត្យានុកូល

ចំពោះបទល្មើសហិង្សាដោយចេតនានេះ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ចំណាត់ថ្នាក់ថាជាប្រភេទនៃបទមជ្ឈិម[63] និងបទហិង្សាមានស្ថានទម្ងន់ទោស[64] និងទោសបន្ថែម។ អំពើហិង្សាដោយចេតនា ដែលប្រព្រឹត្តិដោយចេតនាលើជនរងគ្រោះ ដែលបង្កឱ្យមាន របួសស្នាម ឬគ្មានរបួសស្នាម ឬធ្វើឱ្យខូចសុខភាព ជាដើម។

[62] មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[63] មាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[64] មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

រីឯការប្រើប្រាស់អំពើហិង្សា ដែលបណ្តាលឱ្យបាត់បង់ជីវិតដោយគ្មានចេតនាសម្លាប់ទៅលើជនរងគ្រោះ ឬការប្រើប្រាស់នូវអាវុធ ឬគ្មានអាវុធ ការគំរាមកំហែង នឹងប្រើប្រាស់អាវុធ ដោយមានការគិតទុកជាមុនក្នុងការបង្កឱ្យមានរបួសទៅលើជនរងគ្រោះ ដោយមានការចូលរួមដោយចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត ដែលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ជាបទល្មើសហិង្សាមានស្ថានទម្ងន់ទោស[65]។

**ខ. ធាតុផ្សំសត្យានុម័ត**

ការសិក្សាទៅលើធាតុផ្សំសត្យានុម័ត ឬហៅម្យ៉ាងទៀតថាជាធាតុសម្ភារៈនៃបទល្មើសនេះ ត្រូវត្រួតពិនិត្យទៅលើបញ្ហាពីរគឺ ៖

**អំពើ ៖** អំពើត្រូវតែជាអំពើវិជ្ជមាន។ ក្រមព្រហ្មទណ្ឌបានប្រើពាក្យថា ប្រព្រឹត្តហិង្សាដែលពាក្យនេះមានន័យទូលំទូលាយជាងពាក្យ វាយតប់ និងអំពើផ្សេងទៀតដែលបង្កឱ្យអ្នកដទៃរបួសផ្លូវកាយ ផ្លូវចិត្ត សេដ្ឋកិច្ច និងផ្លូវភេទ។ ពាក្យថា វាយតប់ គឺសំដៅទៅលើអំពើដែលនាំឱ្យមានទំនាក់ទំនងរូបរាងកាយរវាង ចារី និងជនរងគ្រោះ។ ចំណែកឯការប្រព្រឹត្តហិង្សាវិញ អាចមានវិធីច្រើនយ៉ាងដើម្បីបង្កឱ្យអ្នកដទៃមានរបួស ដូចជា ការប្រើដំបង ដុំថ្ម ឬអាចបញ្ជាសត្វចិញ្ចឹមឱ្យខាំ ជាដើម។

ឥឡូវយើងពិនិត្យអំពីធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈនៃបទល្មើសហិង្សាមានដោយចេតនា និងលក្ខខណ្ឌសំខាន់ៗនៃធាតុសត្យានុម័ត ឬធាតុសម្ភារៈដូចតទៅ ៖

**អំពើនៃរូបរាង ៖** អាចស្តែងឡើងជាសកម្ម ពីសំណាក់ជនល្មើសទៅលើរូបវន្តបុគ្គលណាម្នាក់ជាជនរងគ្រោះដែលអំពើនោះគ្រាន់តែចង់បង្កឱ្យមានរបួសស្នាម ឬការសងសឹករបស់ជនល្មើសទៅលើជនរងគ្រោះដែលជាហេតុនាំឱ្យកើតមានអំពើហិង្សានេះកើតឡើង។

អំពើសកម្មដែលគឺជាអំពើមួយដែលស្តែងឡើង ពីសកម្មភាពផ្ទាល់របស់ជនល្មើសមកលើជនរងគ្រោះដោយមានការគ្រោងទុក ឬដោយមានការរៀបចំគម្រោង ធ្វើការពួនស្ទាក់ដើម្បីបង្កហិង្សាទៅលើជនរងគ្រោះ។ បើទោះបីជាជនល្មើសប្រព្រឹត្តបទល្មើសដោយមានប្រើ អាវុធក្តី ឬគ្មានប្រើអាវុធក្តី គឺស្តែងចេញតាមរូបភាព និងតាមគ្រប់មធ្យោបាយដែលជនល្មើសបានប្រព្រឹត្តទៅលើជនរងគ្រោះ។

អំពើនឹងសកម្មភាពភាគច្រើនស្តែងឡើងដូចជា៖

- សកម្មភាព ទះមួយកំប្លៀង ដាល់មួយដៃ ធាក់មួយជើង ឬអុកមួយកែង ជាដើម។

- ជនល្មើសបានវាយជនរងគ្រោះ ដោយមានការចូលរួមផ្ទាល់ពីមនុស្សច្រើននាក់ក្នុងឋានៈ ជាចារី សហ-ចារី អ្នកសមគំនិត ឬអ្នកផ្តើមគំនិត ដោយប្រើប្រាស់អាវុធ ឬដោយមិនប្រើអាវុធ ឬដោយការគំរៀមគំហែង

[65] មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

នឹងប្រើអាវុធ។

- ជនល្មើសបានយាយី ឬបៀតបៀនលើរូបរាងកាយ ផ្លូវចិត្ត ឬផ្លូវភេទរបស់ជនរងគ្រោះ។

- ជនល្មើសបានឱ្យជនរងគ្រោះ ផឹក ឬលេប ឬបញ្ចូលទៅក្នុងខ្លួនជនរងគ្រោះតាមគ្រប់មធ្យោបាយដោយចេតនានូវសារជាតិពុលដែលបណ្តាលឲ្យខូចសុខភាព។

- ជនល្មើសបានលក់ ឬធ្វើអនុប្បទាន ឬឱ្យចំណី ឬភេសជ្ជៈ ដោយបានដឹងថា ចំណី ឬភេសជ្ជនោះមានសារជាតិពុលនាំឱ្យខូចសុខភាព។

- ជនល្មើសបានដាក់បញ្ចូលនូវសារជាតិពុលទៅក្នុងទឹក សម្រាប់ហូបជាសាធារណៈដោយនាំឱ្យខូចសុខភាព។

ជាងនេះទៅទៀត ការប្រើប្រាស់ ហិង្សាដោយចេតនា អាចសន្និដ្ឋានបានថា ការជះកាហ្វេក្តៅ ឬទឹកក្តៅទៅលើអ្នកដទៃគឺជាបទហិង្សាដោយចេតនា។

ចំណែកឯពាក្យថា "អាវុធ" នៅទីនេះចង់សំដៅទៅលើអ្វីទៅ ? យោងតាមក្រមព្រហ្មទណ្ឌ គឺមានចែងនូវពាក្យថា "អាវុធ" និងវត្ថុដែលត្រូវបានចាត់ទុកដូច ដូចខាងក្រោម ៖

"អាវុធ" គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើអោយមានរបួស ឬដើម្បីគំរាមគំហែង។ ត្រូវចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចជា៖

១. វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឱ្យរបួស ឬគំរាមកំហែង។

២. វត្ថុមានទិសដៅសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង[66]។

ចំពោះវត្ថុដែលអាចចាត់ទុកជាអាវុធមានដូចជា វត្ថុរឹង វត្ថុរាវ ឬឧស្ម័នជាដើម។ រីឯការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមគំហែងត្រូវចាត់ទុកដូចបានប្រើប្រាស់អាវុធដែរ។ ដូចទៅនឹងករណីដែលជនឈ្មោះ ក បានយកកាំភ្លើងមកបាញ់បញ្ឆិតត្រចៀករបស់អ្នកដទៃ គឺគប្បីចាត់ទុកថាជាអំពើហិង្សាដោយចេតនាពីព្រោះអំពើហិង្សាបែបនេះបានបង្កនូវព្យសនកម្មផ្លូវចិត្តដល់ជនរងគ្រោះ។

**គ. ធាតុផ្សំអត្តនោម័ត**

ធាតុផ្សំអត្តនោម័ត នៅក្នុងបទហិង្សាដោយចេតនា សំដៅទៅលើបំណងក្នុងការប្រព្រឹត្តអំពើ។ ដូចនេះ ទោះបីជាចារីមិនមានបំណងក្នុងការប្រព្រឹត្តអំពើ។ ជនល្មើសមានចេតនា ធ្វើឱ្យជនរងគ្រោះរងនូវការឈឺចាប់ លើរូបរាងកាយ ឬខូចសុខភាព ផ្លូវចិត្ត សេដ្ឋកិច្ច និងផ្លូវភេទ បានន័យថា ជនល្មើសមានចេតនាធ្វើឱ្យជនរងគ្រោះឈឺចាប់លើរូបរាងកាយ ទោះលទ្ធផល មានរបួស ឬគ្មានរបួសក្តី។ ដូចនេះ ទោះបីជាចារីមិនមានបំណងនឹងធ្វើឱ្យ

[66] មាត្រា ៨១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

មានរបួសធ្ងន់ធ្ងរដល់ជនរងគ្រោះក្តី ចារីក៏ត្រូវតែមានទោសដែរ ប្រសិនបើខ្លួនមានចេតនាក្នុងការធ្វើអំពើ។ ជួនកាលជនល្មើសមានបំណងធ្វើឱ្យមានព្យសនកម្មតិចតួចចទៅដល់ជនរងគ្រោះ តែលទ្ធផលដែលទទួលបាន គឺខុសពីចិត្តរបស់ខ្លួន បានសេចក្តីថា ព្យសនកម្មដែលទទួលរង គឺពិការភាពរបស់ជនរងគ្រោះទៅវិញ ឬមរណ-ភាពនៃជនរងគ្រោះទៅវិញ។ ក្នុងករណីបែបនេះ ជនល្មើសត្រូវជាប់ចោទពី បទហិង្សាមានស្ថានទម្ងន់ទោសវិញ។ អាចនិយាយបានថា ជនល្មើសត្រូវចោទប្រកាន់ទៅតាមព្យសនកម្មជាក់ស្តែងដែលកើតឡើងពីអំពើរបស់ខ្លួន ដូចគ្នាផងដែរ ការភាន់ច្រឡំទៅលើជនរងគ្រោះមិនអាចលុបបំបាត់ធាតុផ្សំអត្តនោម័តនៃបទល្មើសបានឡើយ។

### ២.១.៣. បទល្មើសហិង្សា និងការទប់ស្កាត់

បទល្មើសហិង្សា គឺបណ្តាលឱ្យមានផលប៉ះពាល់ជាច្រើនដល់លើបូរណភាពរូបកាយ ផ្លូវចិត្ត សេដ្ឋកិច្ច និង ការឈ្លានពានខាងផ្លូវភេទដែលប្រព្រឹត្តដោយ សហព័ទ្ធ ឬអនីតិសង្វាសជន ឬអំពើហិង្សាក្នុងគ្រួសារ ឬ ប្រព្រឹត្តដោយនីតិបុគ្គល ឬរូបវន្តបុគ្គលណាម្នាក់។

### ក. លក្ខណៈនៃការទប់ស្កាត់អំពើហិង្សា

ចំពោះការទប់ស្កាត់អំពើហិង្សានេះមានគោលបំណង បញ្ចៀសអំពើហិង្សា ការពារជនរងគ្រោះ និង ពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះទើបក្រសួងស្ថាប័នពាក់ព័ន្ធនានា និងរាជរដ្ឋាភិបាលបានបង្កើតឱ្យមានយន្តការនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សា និងការពារដល់ជនរងគ្រោះ ជាពិសេសទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អំពើហិង្សាទាមទារឱ្យមានការទប់ស្កាត់ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ហើយតម្រូវឱ្យចាត់វិធានការសមស្របបំផុត ដើម្បីការពារជនរងគ្រោះ ឬជនអាចនឹងរងគ្រោះ។ អំពើហិង្សាអាចធ្វើឱ្យមានព្យសនកម្មទៅលើរូបវន្តបុគ្គលណាម្នាក់ ដែលបណ្តាលមកពីអំពើរបស់ជនល្មើសដោយប៉ះពាល់ទៅលើ ៖

១. អំពើហិង្សាផ្លូវកាយ និងការប៉ះពាល់ដល់ជីវិត

២ . អំពើហិង្សាប៉ះពាល់ដល់ ផ្លូវចិត្ត

៣. អំពើហិង្សាផ្នែកសេដ្ឋកិច្ច

៤. ការឈ្លានពានខាងផ្លូវភេទ

- **ចំណុចទី១. អំពើហិង្សាផ្លូវកាយ និងការប៉ះពាល់ដល់ជីវិត**

អំពើទាំងឡាយណាដែលធ្វើឱ្យមានការប៉ះពាល់ដល់រូបរាងកាយ ទោះជាមានស្នាម ឬគ្មានស្នាមរបួស ដូចជាការវាយដំ ឬប្រើអាវុធជាដើម។ ការប៉ះពាល់ជីវិតបុគ្គលត្រូវបានហាមឃាត់បើទោះបីអំពើនោះស្តែងឡើង

តាមរូបភាពណាមួយក៏ដោយ ច្បាប់មិនអនុញ្ញាតដាច់ខាត ឱ្យមានការប៉ះពាល់សិទ្ធិរស់រានមានជីវិត[67]។ អំពើដែលប៉ះពាល់ជីវិតមនុស្សមានដូចជា ៖

- បទឃាតកម្ម គឺជាអំពើដែលធ្វើឱ្យបាត់បង់ជីវិតមនុស្ស ឬអំពើផ្តាច់យកជីវិតមនុស្សដោយចេតនាទោះបីធ្វើឡើងដោយប្រើអាវុធ ឬគ្មានអាវុធក្តីស្តែងឡើងដោយគ្រប់មធ្យោបាយ ឬដោយការគិតទុកជាមុន។
- បទមនុស្សឃាតដោយអចេតនា គឺជាអំពើដែលបណ្តាលឱ្យស្លាប់អ្នកដទៃដោយ

១. ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬ ការខ្ជីខ្ជា។

២. ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ[68]។

ការធ្វេសប្រហែស គឺជាការភ្លេចភ្លាំង ខ្វះភាពម៉ត់ចត់ ការម៉ាក់ងាយដោយជនល្មើស។ ការមិនប្រុងប្រយ័ត្ន សំដៅដល់អំពើទាំងឡាយណាដែល បណ្តាលមកពីការមិនប្រុងប្រៀបស្មារតី ដោយការរវើរវាយជាដើម។ រីឯការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ គឺជាការមិនប្រតិបត្តិតាមបទបញ្ជាទាំងឡាយដែលមានចែងក្នុងបទប្បញ្ញត្តិផ្ទៃក្នុងរបស់ស្ថាប័ន ឬសហគ្រាសមួយ ឬគឺជាការមិនប្រតិបត្តិតាមអ្វីដែលច្បាប់បានតម្រូវឱ្យធ្វើ។

- អំពើហិង្សា ជាអំពើដែលប្រព្រឹត្តទៅលើអ្នកដទៃដោយចេតនាទុច្ចរិត ឬមធ្យោបាយគ្រប់ប្រភេទបណ្តាលឱ្យរងរបួស ឬគ្មានរបួស ខូចសុខភាព ឬបណ្តាលឱ្យជនរងគ្រោះស្លាប់ដោយគ្មានអចេតនាសម្លាប់។

ការប៉ះពាល់ដល់បូរណភាពរូបកាយត្រូវបានគោរពដាច់ខាត ព្រោះច្បាប់មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាម្នាក់ឡើយ។ សកម្មភាពដែលបង្កឱ្យមានការប៉ះពាល់ដល់រូបកាយមាន ៖ ការប្រើអាវុធ ឬគ្មានអាវុធ មានរបួស ឬគ្មានរបួស។

- ការធ្វើទារុណកម្ម និងអំពើឃោរឃៅ មានន័យថាអំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយក្តី ឬផ្លូវចិត្តក្តីដែលត្រូវបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ក្នុងគោលបំណងណាមួយ។ ចំណែកឯអំពើឃោរឃៅ គឺជាអំពើដែលជនល្មើសប្រព្រឹត្តយ៉ាងកាចសាហាវព្រៃផ្សៃដូចជា ការចាប់ចងស្លាបសេកដកក្រចក យកកាំបិត ឬឡាមឆូតបង្ហូរឈាមជាដើម ដែលអំពើទាំងនោះនាំឱ្យមានការឈឺចាប់ខ្លាំង និងមានរយៈពេលយូរ។

> **ចំណុចទី២. អំពើហិង្សាប៉ះពាល់ដល់ផ្លូវចិត្ត**

ជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យមានការប៉ះពាល់ផ្លូវចិត្ត ការធ្វើទុកបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍បញ្ញាស្មារតីដល់រូបវន្តបុគ្គលណាម្នាក់ ដូចជាការជេប្រមាថ គំរាមកំហែង បិទសិទ្ធិ

[67] មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

[68] មាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

សេរីភាពជាដើម ការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្ត ដែលប្រព្រឹត្តហួសពីសីលធម៌ និងច្បាប់កំណត់។

➢ **ចំណុចទី៣. អំពើហិង្សាប៉ះពាល់ខាងផ្លូវភេទ**

ត្រង់ចំណុចនេះ គឺចង់សំដៅទៅលើសកម្មភាពទាំងឡាយណាធ្វើឱ្យប៉ះពាល់ដល់ផ្លូវភេទតាមរយៈការរំលោភបំពានផ្លូវភេទ ការធ្វើអាស្រូវ អាសអាភាស ការបៀតបៀនកេរខ្មាស់ ដូចជាបង្ខំរួមភេទជាមួយប្រពន្ធ ការរំលោភសេពសន្ថវៈ ការបង្ហាញរូបភាពអាសអាភាស ។ល។

ការឈ្លានពានលើផ្លូវភេទអាចមានអំពើដូចជា ៖

- ការរំលោភសេពសន្ថវៈ មានន័យថាគ្រប់អំពើដែលបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬផ្ទុយគ្នាក៏ដោយដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយឆ្មក់ឱកាស[69] ។

- ការប្រទូសកេរខ្មាស់ គឺគ្រប់អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រចិត្តផងនោះ ឬបង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬទៅលើតតីយជនក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស [70]។

- ការរុកកួនខាងផ្លូវភេទ គឺជាអំពើរបស់បុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ ធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ[71] ។

➢ **ចំណុចទី ៤. អំពើហិង្សាប៉ះពាល់ដល់សេដ្ឋកិច្ច**

ជាសកម្មភាពបំផ្លិច បំផ្លាញទ្រព្យសម្បត្តិ បិទសិទ្ធិក្នុងការស្វែងរកប្រាក់ចំណូល និងការចូលរួមចាត់ចែងទ្រព្យសម្បត្តិ ឬការមិនឱ្យទៅធ្វើការរកប្រាក់ចំណូល ជាដើម។

**ខ. វិធានការទប់ស្កាត់**

ដើម្បីទប់ស្កាត់ អំពើហិង្សាដូចដែលមាននៅក្នុងចំណុចខាងលើ ដែលកំពុងតែកើត ឬជឿជាក់ថានឹងកើតឡើងអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ដោយ ៖

- ឃាត់ទុកអាវុធ ឬវត្ថុជាក់ស្តែងដែលជនមុខសញ្ញាបានប្រើ ឬអាចប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសហិង្សា។
- បង្វែរយកចេញជនមុខសញ្ញា ពីកន្លែងកើតហេតុ ឬបង្វែរជនរងគ្រោះបើមានការស្នើសុំពីជនរងគ្រោះ។ ក្នុងករណីពិសេសអាចបង្វែរចេញបានដោយគ្មានការស្នើសុំប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ។

[69] មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[70] មាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[71] មាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

- ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្ន ដែលអាចធានាសុវត្ថិភាព និងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់។
- ពន្យល់អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឱ្យបញ្ឈប់អំពើហិង្សា និងធ្វើការណែនាំអំពីសិទ្ធិរបស់ខ្លួនក្នុងការទប់ស្កាត់អំពើហិង្សា។

**គ. ការការពារជនរងគ្រោះ**

ដើម្បីការពារសន្តិសុខជនរងគ្រោះអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការហាមឃាត់ដូចខាងក្រោម ៖

- ហាមប្រើអំពើហិង្សាលើគ្រួសារខ្លួនឯងផ្ទាល់ និងដោយប្រព្រឹត្តលើអ្នកផ្សេង។
- ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិជនរងគ្រោះ ឬរបស់ញាតិសាលោហិតរបស់ជនរងគ្រោះ ឬអ្នកដទៃផ្សេងទៀត។
- ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅទីលំនៅរួម កន្លែងស្នាក់នៅ កន្លែងធ្វើការរបស់ជនរងគ្រោះកាលបើគ្មានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច និងជនរងគ្រោះ។ ជនមុខសញ្ញា គឺជាអ្នកដែលបានប្រព្រឹត្តកំពុងនឹងត្រៀមប្រព្រឹត្តអំពើហិង្សា ។
- ចាត់វិធានការស្របច្បាប់ផ្សេងទៀត ដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសមាជិកក្នុងក្រុមគ្រួសារ ឬជនដែលពាក់ព័ន្ធ។

**គ.១. ករណីមានបទល្មើសជាក់ស្តែង**

បើមានសំណើសុំធ្វើអន្តរាគមន៍ និងមានបទល្មើសជាក់ស្តែង[72] ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមកើតឡើង ហើយមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌មានសិទ្ធិចូលទៅដល់ទីកន្លែងកើតហេតុតាមការស្នើសុំពីអ្នកកាន់កាប់ ទៅព្រះរាជអាជ្ញា ឬទៅនគរបាលយុត្តិធម៌។

- ការចុះទៅកន្លែងកើតហេតុ ៖ មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកន្លែងកើតហេតុ ដើម្បីពិនិត្យបទល្មើសក្រោយពីរាយការណ៍ភ្លាមទៅព្រះរាជអាជ្ញា។ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅណាឆ្ងាយពីកន្លែងបទល្មើស រហូតចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។

- ការឃាត់ខ្លួន ៖ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គល ដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស និងបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ ( ក្នុងករណីដែលបុគ្គលនោះប្រកែកមិនព្រមផ្តល់ព័ត៌មាន ) នៅពេលមានការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

[72] មាត្រា ៨៥ មាត្រា ៨៦ និងមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- ការឆែកឆេរ ៖ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន[73] ដោយទទួលនូវការអនុញ្ញាតពីព្រះរាជអាជ្ញា (ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់)។

- ការចាប់យកវត្ថុតាង ៖ មន្ត្រីនគរបាលយុត្តិធម៌អាចចាប់យកវត្ថុតាងបាន[74] ដោយត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ។ ក្រោយពីបានបង្ហាញវត្ថុចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុចាប់យក។

- ការស្តាប់ចម្លើយ ៖ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបាន[75]។

- ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ[76]។

- ការបញ្ជូនកំណត់ហេតុ វត្ថុតាង និងបុគ្គលដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា[77]។

- ការស្តាប់ការសន្ទនា ៖ មានតែចៅក្រមស៊ើបសួរប៉ុណ្ណោះដែលមានសិទ្ធិក្នុងការស្តាប់ ឬថតសម្លេងសន្ទនាតាមទូរស័ព្ទ ចាប់ និងថតការឆ្លងឆ្លើយដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ឬសារតាមទូរសារ ឬសារតាមអ៊ីនធឺណែត[78]។

**គ.២. ករណីបទល្មើសមិនជាក់ស្តែង**

ការស៊ើបអង្កេតបឋមអាចដំណើរការបានដោយការផ្តួចផ្តើមរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬតាមការសុំរបស់ព្រះរាជអាជ្ញា ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ។ ការស៊ើបអង្កេតបឋមដំណើរការ នៅក្នុងករណីបទល្មើសមិនជាក់ស្តែង ឬក្នុងករណីដែលថិរវេលា នៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងបានកន្លងផុត[79]។ ក្នុងករណីនៃការស៊ើបអង្កេតបឋមមានភាពប្រហាក់ប្រហែលជាមួយនឹងការស៊ើបអង្កេតករណីជាក់ស្តែងដែរ ដោយគ្រាន់តែបទប្បញ្ញត្តិយោងមានភាពខុសគ្នា[80]។ ចំណុចខុសគ្នាខ្លាំងគឺ ៖

- សិទ្ធិអំណាចក្នុងការឆែកឆេរ[81] គឺត្រូវតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីអ្នកកាន់កាប់ទីកន្លែងយ៉ាងច្បាស់។

---

[73] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[74] មាត្រា ៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[75] មាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[76] មាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[77] មាត្រា ១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[78] មាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[79] មាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[80] មាត្រា ១១១ ដល់មាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[81] មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- ដីការអនុញ្ញាតឱ្យឆែកឆេរ ពីប្រធានសាលាដំបូង តាមការសុំរបស់ព្រះរាជអាជ្ញា ប្រសិនបើអ្នកកាន់កាប់អវត្តមាន ឬបដិសេធការឆែកឆេរ។ ការឆែកឆេរត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ ហើយមិនអាចផ្ដើមមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ ឡើយ។

## កថាខណ្ឌទី២៖ ការផ្តន្ទាទោសចំពោះបទល្មើសហិង្សាដោយចេតនា

### ២.២. ករណីបទល្មើសគ្មានស្ថានទម្ងន់ទោស

កាលបើអំពើហិង្សាបានប្រព្រឹត្តដោយស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

#### ២.២.១. លក្ខខណ្ឌ

ការចាត់ទុកអំពើដែលប្រព្រឹត្តជាបទល្មើសហិង្សាដោយចេតនា ដូចមានក្នុងករណីដែល ៖

- ករណីវាយតប់ ឬធាក់ ឬមធ្យោបាយនានាដែលបណ្ដាលឱ្យជនរងគ្រោះមានរបួសស្នាម ឬគ្មានរបួសស្នាម
- ការចាត់ទុកការប្រើសារជាតិពុល
- ការចាត់ទុកការផ្ដល់អាហារដែលមានសារជាតិពុល
- ការចាត់ទុកការបញ្ចូលសារជាតិពុលក្នុងទឹកសម្រាប់បរិភោគ

#### ក. ករណីគ្មានស្ថានទម្ងន់ទោស

បទល្មើសហិង្សាដោយមានចេតនាលើអ្នកដទៃតាមគ្រប់មធ្យោបាយក្រោមរូបភាពការវាយដោយដៃ ទាត់ធាក់ ឬការជះទឹកដែលក្ដៅលើ ឬប្រើសត្វឆ្កែឱ្យខាំទៅលើជនរងគ្រោះឱ្យមានរបួសមិនធ្ងន់ធ្ងរខ្លាំង[82] ច្បាប់គប្បីចាត់ទុកអំពើទាំងនេះជាបទល្មើសហិង្សាដោយចេតនា។

#### ខ. ការចាត់ទុកការប្រើសារជាតិពុលដូចជាអំពើហិង្សាដោយចេតនា

ជនដែលឱ្យអ្នកដទៃ ផឹក លេប ឬបញ្ចូលទៅក្នុងខ្លួនអ្នកដទៃ តាមមធ្យោបាយណាមួយក៏ដោយ ដោយចេតនានូវសារជាតិពុល ដែលបណ្ដាលឱ្យខូចសុខភាព ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា[83] ។

អំពើហិង្សាមួយដែលជនល្មើសមានចេតនា ឱ្យជនរងគ្រោះ ផឹក លេប ឬ បញ្ចូលតាមគ្រប់មធ្យោបាយនូវសារជាតិពុលដែលខ្លួនដឹងជាមុនថា សារជាតិនោះធ្វើឱ្យប៉ះពាល់ ដល់សុខភាពជនរងគ្រោះត្រូវចាត់ទុកជាបទល្មើសហិង្សាដោយចេតនាផងដែរ ។ ករណីដូចជា បុរសម្នាក់ឈ្មោះ ក និងលោក ខ ជាអ្នកជិតខាង តែងតែឈ្លោះប្រកែកគ្នាបញ្ហារឿងព្រំដី។ ពេលដែលលោក ខ មិននៅផ្ទះលោក ក បានយកថ្នាំកសិកម្មដែលសល់បន្តិចបន្តួចពីការបាញ់សម្លាប់សត្វល្អិតពីដីស្រែរបស់ខ្លួនទៅ ចាក់គ្រប់ពាងទឹករបស់លោក ខ ដែលលោក ខ ប្រើសម្រាប់បរិភោគប្រចាំថ្ងៃ ធ្វើឱ្យគ្រួសារលោក ខ ពុលក្អួតត្រូវបញ្ជូនទៅមន្ទីពេទ្យ។ ក្នុងករណីនេះក៏ត្រូវចាត់ទុកដូចហិង្សា

[82] មាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[83] មាត្រា ២២៥ នៃក្រមប្រហ្មទណ្ឌ ឆ្នាំ២០០៩

ដោយចេតនាផងដែរ ព្រោះបណ្តាលឱ្យខូចសុខភាព។

**គ. ការចាត់ទុកការផ្តល់អាហារដែលមានសារជាតិពុល ដូចជាអំពើហិង្សាដោយចេតនា**

អំពើ លក់ ធ្វើអនុប្បទាន ឬឱ្យចំណី ឬ ភេសជ្ជៈ ដោយដឹងថាចំណី ឬ ភេសជ្ជៈនោះមានសារជាតិពុលនាំឱ្យខូចសុខភាពនោះត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា[84]។ អត្ថន័យនៅត្រង់ចំណុចនេះចង់សំដៅដល់ចេតនាក្នុងការ លក់ ឬធ្វើអនុប្បទាន ឬឱ្យចំណី ឬភេសជ្ជៈដោយដឹងមុនថា ចំណី ឬភេសជ្ជៈនោះមានសារជាតិពុលបណ្តាលឱ្យខូចសុខភាពជនរងគ្រោះ។ ជាក់ស្តែង ផលិតផលក្លែងក្លាយ ឬផលិតផលដែលហួសកាលបរិច្ឆេទ កាលបើជនម្នាក់ធ្វើ ការលក់ ឬធ្វើអនុប្បទានទៅ ឱ្យជនណាម្នាក់ ឬក្រុមណាមួយ ឬឱ្យចំណី ឬភេសជ្ជៈដែលខ្លួនបានដឹងថាវាមានសារជាតិពុល ឬហួសកាលបរិច្ឆេទកំណត់របស់ក្រសួងដែលបណ្តាលឱ្យអ្នកដទៃខូចសុខភាពត្រូវទទួលទោសដូចជាអំពើហិង្សាដោយចេតនាផងដែរ។

**ឃ. ការចាត់ទុកការបញ្ចូលសារជាតិពុលក្នុងទឹកសម្រាប់បរិភោគដូចជាអំពើហិង្សាដោយចេតនា**

អំពើប្រព្រឹត្តដោយចេតនា ដោយដាក់បញ្ចូលនូវសារជាតិពុលនាំឱ្យខូចសុខភាព ទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា។ ការចាក់ចូលសារជាតិពុលទៅក្នុង អណ្តូងទឹក ប្រឡាយ ស្ទឹង បឹង ឬព្រែក ឬប្រភពទឹកសម្រាប់សាធារណជនប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ដែលនាំឱ្យខូចសុខភាពត្រូវចាត់ទុកដូចជាហិង្សាដោយចេតនាដែរ ។ ជាក់ស្តែងដូចក្នុងករណីដែល បន្ទាប់ពីបានបាញ់ថ្នាំកសិកម្មនៅក្នុងស្រែរបស់ខ្លួនរួចលោក ក បានយកឧបករណ៍បាញ់ថ្នាំ និងថ្នាំកសិកម្មដែលសេសសល់នោះ ទៅចាក់លាងសម្អាតក្នុងបឹងទាំងដែលគាត់បានដឹងថាទង្វើរបស់គាត់នឹងធ្វើឱ្យអ្នកដែលប្រប្រាស់ទឹកបឹង នៅក្នុងភូមិនោះពុល។ អ្នកភូមិដែលប្រើប្រាស់ទឹកបឹងសម្រាប់ហូបជាប្រចាំបាន ពុល ចុក ក្អួត ត្រូវបញ្ជូនទៅមន្ទីរពេទ្យ។ ទង្វើរបស់លោក ក គឺត្រូវបានចាត់ទុកជាបទល្មើសហិង្សាដោយចេតនា។

**ខ. ហិង្សាស្រាល**

អំពើប្រព្រឹត្តហិង្សាទៅលើអ្នកដទៃ ដែលមិននាំឱ្យមានរបួសទេនោះត្រូវចាត់ទុកថាជាបទហិង្សាស្រាលដែលជាប្រភេទនៃបទលហុ។

អំពើហិង្សាដែលគ្មានរបួសស្នាម ឬ ការឈឺចាប់ធ្ងន់ធ្ងរទៅលើជនរងគ្រោះដូចជា ទះមួយកំភ្លៀង ធាក់មួយជើង ឬវាយមួយដៃជាដើម។

**បញ្ជាក់ ៖** ហិង្សាស្រាល ទោសដែលត្រូវអនុវត្តគឺជាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

[84] មាត្រា ២២៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ២.២.២. ទោសដែលត្រូវអនុវត្តចំពោះបទល្មើសហិង្សាដោយចេតនា

ទោសដែលត្រូវអនុវត្តចំពោះបទល្មើសហិង្សាដោយចេតនា មានដូចជា មូលទោស និងទោសបន្ថែម។ ចំពោះមូលទោសនៃបទហិង្សាដោយចេតនាដែលមានចែងនៅក្នុងមាត្រា ២១៧ មាត្រា ២២៥ មាត្រា ២២៦ និង មាត្រា ២២៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បានកំណត់អតិបរមានៃទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

## ២.៣. ករណីបទល្មើសមានស្ថានទម្ងន់ទោស

អំពើហិង្សា គឺជាអំពើដែលបង្កើតឱ្យមានផលវិបាកធ្ងន់ធ្ងរលើរូបរាងកាយ ផ្លូវចិត្ត ផ្លូវកាយ សេដ្ឋកិច្ច និង ផ្លូវភេទដល់ជនរងគ្រោះ ក្រុមគ្រួសារ និងសង្គមជាតិ។ កាលបើអំពើហិង្សាប្រព្រឹត្តដូចលក្ខខណ្ឌខាងក្រោមនេះ ត្រូវស្ថិតក្នុងបទល្មើសហិង្សាមានស្ថានទម្ងន់ទោស។

### ២.៣.១. លក្ខខណ្ឌ

ការចាត់ទុកអំពើដែលប្រព្រឹត្តជាបទល្មើសហិង្សាមានស្ថានទម្ងន់ទោស ដូចមានក្នុងករណីខាងក្រោម ៖

#### ក. ហិង្សាដែលចាត់ទុកជាបទល្មើសមានស្ថានទម្ងន់ទោស

- **ចំណុចទី១. ដោយមានការគិតទុកជាមុន**

ក្នុងករណីដែលជនណាម្នាក់បានប្រព្រឹត្តអំពើហិង្សាទៅលើជនរងគ្រោះ ដោយមានការរៀបចំទុកជាមុន ឬមានការពួនស្ទាក់ ដូច្នេះហិង្សាបែបនេះត្រូវបានកំណត់យ៉ាងច្បាស់ថា "ហិង្សាមានស្ថានទម្ងន់ទោសដោយការគិតទុកជាមុន" [85]។

តើអ្វីទៅជាការគិតទុកជាមុន ហើយអ្វីដែលជាការពួនស្ទាក់ ? ការគិតទុកជាមុន គឺជាគម្រោងការដែលរៀបចំទុកជាមុន គិតទុកជាមុន បង្កើតឡើងដើម្បីធ្វើការបៀតបៀនទៅលើរូបវន្តបុគ្គលដែលជាជនរងគ្រោះ ដោយធ្វើឱ្យបាត់បង់ជីវិត ឬមានរបួសស្នាម។

រីឯការពួនស្ទាក់ គឺជាអំពើឃ្លាំចាំមើលជនរងគ្រោះនៅទីកន្លែងណាមួយក្នុងរយៈពេលណាមួយរយៈ ដើម្បីប្រព្រឹត្តិបទល្មើសបៀតបៀនទៅលើរូបវន្តបុគ្គលដែលជាជនរងគ្រោះនោះ[86]។ ដូចក្នុងករណីដែលបុរសឈ្មោះ ក និងបុរសឈ្មោះ ខ ជាអ្នកប្រមឹក ដែលតែងតែផឹកស្រាជជែកគ្នាលេងជាមួយគ្នាជារៀងរាល់ថ្ងៃ។ ថ្ងៃមួយពួកគេទាំងពីរនាក់បានផឹកស្រវឹង រួចឈ្លោះប្រកែកគ្នាយ៉ាងខ្លាំងរហូតឈានដល់បង្កជាជម្លោះដាក់គ្នាតែមានអ្នកឃាត់។ បន្ទាប់មកទៀតបុរស ក បានចេញពីកន្លែងផឹកស្រាមុនបុរស ខ ស្រាប់តែបន្តិចក្រោយមកបុរស ខ ក៏បានគិតលុយ

---

[85] មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[86] វាក្យសព្ទច្បាប់ សាលាក្រាដូ

រួចរៀបចំទៅផ្ទះ គ្រាន់តែរៀបចំឡើងជិះម៉ូតូ ក៏ត្រូវបុរស ក វាយមួយដំបងបណ្តាលឱ្យបែកក្បាល។ ចេតនារបស់បុរស ក គឺចង់បង្កអំពើហិង្សាទៅ លើជនរងគ្រោះដោយមានការរៀបចំ និងការគិតទុកជាមុន។ រាល់អំពើដែលប្រព្រឹត្តបែបនេះគេហៅថា ហិង្សាដោយមានការគិតទុកជាមុន។ ចំពោះការគិតទុកជាមុនគឺត្រូវទទួលស្ថានទម្ងន់ទោស តាមបញ្ញត្តិ មាត្រា ២១៨ ចំណុចទី ១ នៃក្រមព្រហ្មទណ្ឌ។

➢ **ចំណុចទី២. ដោយប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ**

អាវុធក្នុងន័យនេះ គឺជាឧបករណ៍ដែលជនល្មើសយកទៅបង្កហិង្សាទៅលើជនរងគ្រោះ។ អាវុធអាចជាវត្ថុ រឹង រាវ និង ឧស្ម័ន មានដូចជា (កាំភ្លើង កាំបិត ដំបង កំណាត់ឈើ ទឹក អាស៊ីត ថ្នាំពុល ថ្នាំកសិកម្ម ថ្នាំមុសហ្គាស) ឬការប្រើសត្វឱ្យខាំ ជាដើម។ ចំពោះបទហិង្សាដោយមានប្រើអាវុធ គឺជនល្មើសបានយកអាវុធមកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសហិង្សា និងបង្ករបួសស្នាម ឬធ្វើឱ្យខូចសុខភាពដល់ជនរងគ្រោះ។ ជាក់ស្តែងដូចជាករណីដែលជនល្មើសបានយកដុំថ្មគប់ ចំក្បាលរបស់ជនរងគ្រោះ។

រីឯករណីគំរាមកំហែងនឹងប្រើអាវុធ ៖ ចំពោះករណីនេះ គឺខុសអំពីហិង្សាដោយប្រើប្រាស់អាវុធ ដែលអាវុធពុំមែនជាមូលហេតុចម្បងនៃការប្រើអំពើហិង្សាដូចករណីមុនទេ អាវុធគ្រាន់តែជា វត្ថុបន្ទាប់បន្សំសម្រាប់ប្រព្រឹត្តិអំពើហិង្សាតែប៉ុណ្ណោះ។ ទោះបីអំពើហិង្សានោះ គេឃើញមានវត្តមានអាវុធក៏ដោយ ប៉ុន្តែអាវុធមិនមែនជាកម្មវត្ថុដែលជនល្មើសយកទៅប្រព្រឹត្តក្នុងបទល្មើសនោះទេ។ ដូចជាករណីដែល ជនល្មើសបានប្រើប្រាស់កាំភ្លើងដើម្បីគំរាមគំហែងជនរងគ្រោះ ដើម្បីឱ្យជនល្មើស ប្រើហិង្សាតាមចិត្តរបស់ខ្លួនដោយគ្មានការតដៃពីសំណាក់ជនរងគ្រោះ។

**បញ្ជាក់ ៖** ករណីនេះពុំទាន់គិតអំពីទោសដែលកាន់កាប់អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវខុសច្បាប់នោះទេ[87]។

➢ **ចំណុចទី៣. ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត**

ចំពោះចំណុចនេះ គឺចង់សំដៅដល់ការប្រើអំពើហិង្សាមួយដោយមានជនល្មើសច្រើននាក់ដែលបង្ករបួសស្នាម ឬគ្មានរបួសស្នាម ឬធ្វើឱ្យខូចសុខភាព ទៅលើរូបវន្តបុគ្គលជាជនរងគ្រោះតែម្នាក់ ឬច្រើននាក់[88]។ ដោយ

ការប្រព្រឹត្តិហិង្សានេះមានការចូលរួមពីជនល្មើសជាច្រើន ដូចជា ចារី សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត។

[87] មាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និង គ្រាប់រំសេវ
[88] មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

- **ចារី ៖** ត្រូវចាត់ទុកជាចារីចំពោះបុគ្គលដែលប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬនៅក្នុងករណីដែលច្បាប់ចែងទុកចំពោះបទមជ្ឈិម[89]។ ចារីនៃបទល្មើស គឺជាជនដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ ឬជនដែលបានប៉ុនប៉ងប្រព្រឹត្តិដោយផ្ទាល់ ។

- **សហចារី** ៖ ត្រូវចាត់តុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ព្រមព្រៀងប្រព្រឹត្តិបទល្មើសរួមគ្នាដោយផ្ទាល់ ឬក៏ប៉ុនប៉ងប្រព្រឹត្តបទល្មើស ឧក្រិដ្ឋ ឬមជ្ឈិមតាមច្បាប់ចែងទុក[90]។ សហចារីនៃបទល្មើស គឺជាជនដែលបានចូលរួមប្រព្រឹត្តដោយផ្ទាល់ជាមួយចារី ហើយស្ថិតក្នុងកាលៈទេសៈហ្នឹងទីកន្លែងតែមួយជាមួយនឹងចារី។

- **អ្នកផ្តើមគំនិត ៖** ត្រូវចាត់ទុកជាអ្នកផ្តើមគំនិត ក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈឹម ចំពោះបុគ្គលណាដែល ៖ ជម្រុញឱ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមនោះតាមការណែនាំ ឬការបញ្ជា ។ ការបង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់ អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន[91]។

- **អ្នកសមគំនិត ៖** ត្រូវចាត់ទុកជាអ្នកសមគំនិត ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬ ការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន[92] ។ ជាក់ស្តែងដូចក្នុងករណីដែល ជនល្មើសបីនាក់ព្រួតគ្នាវាយទៅលើជនរងគ្រោះ។

### ខ. ស្ថានទម្ងន់ទោសទាក់ទង នឹងជនរងគ្រោះ

កាលបើអំពើហិង្សានេះត្រូវបានប្រព្រឹត្តិទៅលើជនរងគ្រោះជា ៖

១. បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ។

២. នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង។

៣. បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជម្ងឺ ឬ ពិការភាពកាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង[93]។

---

[89] មាត្រា ២៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[90] មាត្រា ២៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[91] មាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[92] មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[93] មាត្រា ២១៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

➢ **ចំណុចទី១. បុគ្គលដែលទន់ខ្សោយពិសេសមូលហេតុអាយុនៃបុគ្គល**

ត្រង់ចំណុចនេះ បុគ្គលដែលទន់ខ្សោយពិសេសដោយមូលហេតុនៃអាយុរបស់បុគ្គលនោះ មានន័យថា ជនល្មើសបានប្រើអំពើហិង្សាដោយចេតនាទៅលើបុគ្គល ដែលជាជនរងគ្រោះមានលក្ខណៈទន់ខ្សោយនៃអាយុរបស់ជននោះ។ បុគ្គលដែលទន់ខ្សោយនៃអាយុអាចជាបុគ្គលដែលមានអាយុតិចជាងជនល្មើសគឺ កុមារ ឬ បុគ្គលដែលមានអាយុច្រើនជាងជនល្មើសគឺ ចាស់ជរា។ ចំពោះការប្រើអំពើហិង្សាដោយចេតនាទៅលើបុគ្គលប្រភេទនេះគឺត្រូវទទួលស្ថានទម្ងន់ទោសនៃបទហិង្សា ដោយហេតុថា បុគ្គលប្រភេទនេះគឺ គ្មានកម្លាំងតតាំងនឹងជនល្មើសនោះទេ។ ដូចក្នុងករណី យុវជនម្នាក់ជាអ្នកញៀនថ្នាំ បានទៅសុំលុយជីដូនដែលចាស់ជរាអាយុ ៧០ ឆ្នាំ របស់ខ្លួនទៅទិញគ្រឿងញៀនប្រើប្រាស់ទៀត តែជីដូនមិនឱ្យ ក៏បានប្រើអំពើហិង្សាវាយទៅលើជីដូនបណ្តាលឱ្យរងរបួស។ ករណីនេះជនល្មើសត្រូវទទួលស្ថានទម្ងន់ទោសតាមច្បាប់ បើទោះបីជននោះស្ថិតក្នុងការប្រើប្រាស់គ្រឿងញៀនក៏ដោយ។ ម្យ៉ាងវិញទៀតបើសិនជាបុរសម្នាក់ស្រវឹងស្រារួច ប្រើអំពើហិង្សាទៅលើកុមារក៏ទទួលទទួលស្ថានទម្ងន់ទោសផងដែរ។

➢ **ចំណុចទី២. ករណីនារីមានមានគភ៌**

ករណីអំពើហិង្សាទៅលើនារី មានគភ៌កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹងគឺការប្រើអំពើហិង្សាដោយចេតនាទៅលើនារីមានគភ៌ ដូច្នេះការប្រព្រឹត្តិអំពើហិង្សាទៅលើបុគ្គលនេះគឺត្រូវទទួលស្ថានទម្ងន់ទោស។ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹងថា នារីនោះមានគភ៌ហើយនៅតែប្រព្រឹត្តអំពើហិង្សាទៅលើនារីម្នាក់នោះទៀត។ ដូចក្នុងករណីដែលជនល្មើសបានវាយទៅលើនារីម្នាក់ដែលមានផ្ទៃពោះ ៧ខែ បណ្តាលឱ្យរងរបួស។

➢ **ចំណុចទី៣. មូលហេតុនៃជម្ងឺ ឬពិការភាព**

បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជម្ងឺ ឬ ពិការភាព ចំណុចទី១ខាងលើ និយាយពីការទន់ខ្សោយនៃអាយុរបស់ជនរងគ្រោះតែ នៅក្នុងចំណុចទី ៣ នេះវិញ គឺចង់សំដៅដល់ការអន់ខ្សោយ ដោយសារមូលហេតុនៃជម្ងឺ ឬ ពិការភាពនៃជនរងគ្រោះកាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។ ចំពោះការប្រើអំពើហិង្សាទៅលើបុគ្គលប្រភេទនេះ ក៏ត្រូវទទួលស្ថានទម្ងន់ទោសផងដែរ។

- **មូលហេតុនៃជម្ងឺ ៖** កាលបើអំពើនោះប្រព្រឹត្តទៅលើបុគ្គលដែលមានជម្ងឺ រ៉ាំរ៉ៃ រញ៉ីរញ៉ៃ ឈឺដើបពុំរួចពីកន្លែងសម្រាក មិនអាចកាន់ ឬ ហូបចំណីដោយខ្លួនឯងបាន ឬ ក៏បុគ្គលដែលមានជម្ងឺខ្សោយពីកំណើតក៏អាចជាមូលហេតុនៃការទន់ខ្សោយនៃជម្ងឺផងដែរ។

- **ចំពោះពិការភាពវិញ** គឺបុគ្គលនោះពិការ គុតដៃ គុតជើង ពិការភ្នែកទាំងសងខាង ស្វិតដៃ ស្វិតជើង ឬ ពិការពីកំណើត ដែលធ្វើឱ្យមានការថមថយក្នុងការតតាំងនឹងជនល្មើស។ ការប្រព្រឹត្តទៅលើបុគ្គលនេះត្រូវទទួល

ស្ថានទម្ងន់ទោសតាមច្បាប់កំណត់។ ដូចក្នុងករណីដែលជនល្មើសបានវាយទៅលើនារីពិការដៃទាំងសងខាងឱ្យរងរបួស។

**គ. ស្ថានទម្ងន់ទោសដោយសារគោលដៅ**

នៅក្នុងអំពើហិង្សាដោយចេតនាដោយមានគោលដៅ គឺជនល្មើសមានចេតនាប្រើអំពើហិង្សាទៅលើបុគ្គលមួយចំនួនដូចបានរៀបរាប់ខាងលើដើម្បី គំរាមកំហែងជននោះក្នុងការធ្វើបណ្ដឹងបរិហារ ឬ សុំឱ្យធ្វើការជួសជុលព្យសនកម្ម ដោយសារអំពើរបស់ខ្លួនបានប្រព្រឹត្តផ្ទុយនិងច្បាប់។

១. ជនរងគ្រោះ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះ កុំឱ្យប្ដឹងបរិហារពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលព្យសនកម្ម។

២. សាក្សី ដើម្បីរារាំងកុំឱ្យផ្ដល់ភស្តុតាង នៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្ដឹងផ្សេងទៀត។

៣. ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឱ្យជួសជុលព្យសនកម្ម។

៤. សាក្សី ដោយមូលហេតុសាក្សីនេះ បានផ្ដល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរសវនាការ ឬនៅក្នុងនីតិវិធីនៃបណ្ដឹងផ្សេងទៀត[94]។

- **ចំណុចទី១. ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីមិនទាន់ប្ដឹងបរិហារ**

ការប្រើអំពើហិង្សាទៅលើ ជនរងគ្រោះ ឬ ដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីរារាំងជននេះ កុំឱ្យប្ដឹងបរិហារ ឬសុំឱ្យធ្វើការជួសជុលព្យសនកម្ម។ ការប្រើអំពើហិង្សា ដោយចេតនារបស់ជនល្មើសទៅលើជនរងគ្រោះ ឬ ដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីធ្វើការគំរាមកំហែងជននោះ កុំឱ្យធ្វើការប្ដឹងបរិហារពីបទល្មើសរបស់ខ្លួន ឬសុំទាមទារឱ្យជួសជុលព្យសនកម្ម។ មានន័យថាអំឡុងពេលប្រព្រឹត្តបទល្មើសហិង្សានេះ គឺជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋ-ប្បវេណីពុំទាន់បានធ្វើការប្ដឹងបរិហារពីបទល្មើស ឬសុំទាមទារឱ្យជនល្មើសជួសជុលព្យសនកម្មទៅដល់មន្ត្រីនគរបាល ឬស្ថាប័នតុលាការ មានសមត្ថកិច្ចនៅឡើយទេ។ ដូច្នេះជនល្មើសក៏បានប្រើអំពើហិង្សាទៅលើបុគ្គលទាំងនេះដើម្បីគំរាមកំហែងកុំឱ្យធ្វើការប្ដឹងបរិហារ ឬសុំទាមទារព្យសនកម្មទៅអាជ្ញាធរ ឬតុលាការមានសមត្ថកិច្ចដើម្បីបិទបាំងនូវអំពើរបស់ខ្លួន។ ដោយហេតុថាអំពើហិង្សាស្រាលមួយបានកើតឡើង ដោយជនរងគ្រោះបាននិយាយទៅកាន់ជនល្មើសថាខ្លួននឹងទៅប្រាប់ម្ដាយ ឱ្យដាក់ពាក្យបណ្ដឹងនៅសាលាឃុំដើម្បីធ្វើការទាមទារព្យសនកម្មពីជនល្មើស។ ពេលនោះជនល្មើសថា គ្រាន់តែទះមួយកំភ្លៀងប្ដឹងដែរ ដោយខឹងនិងសម្ដីជនរងគ្រោះ

[94] មាត្រា២២០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

រកទៅប្តឹងក៏បានវាយជនរងគ្រោះបន្ថែមដើម្បីគំរាមកំហែងកុំអោយធ្វើការប្តឹងទៅសមត្ថកិច្ច ឬស្ថាប័នមានសមត្ថកិច្ច។ ចំពោះការប្រើប្រាស់ទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីដោយមានចេតនាគំរាមកំហែង ឬរាំងជនរងគ្រោះ កុំឱ្យប្តឹងបរិហារ ឬសុំទាមទារជួសជុលព្យសនកម្ម គឺត្រូវទទួលស្ថានទម្ងន់ទោស តាមមាត្រា ២២០ នៃក្រមព្រហ្មទណ្ឌ។

- **ចំណុចទី២. សាក្សីមិនទាន់ផ្តល់ភស្តុតាង ឬសក្ខីកម្ម**

ករណីសាក្សីមិនទាន់ផ្តល់ភស្តុតាង ឬសក្ខីកម្ម នៅត្រង់ចំណុចទី២នេះ គឺការប្រើអំពើហិង្សាទៅលើសាក្សីដែលបានដឹង ឬឃើញហេតុការណ៍ នៃការប្រព្រឹត្តបទល្មើស ដូច្នេះជនល្មើសក៏មានចេតនាប្រើអំពើហិង្សាទៅលើបុគ្គលនេះកុំឱ្យធ្វើជាសាក្សី ក្នុងការផ្តល់ភស្តុតាង ទៅឱ្យសមត្ថកិច្ច ឬស្ថាប័នតុលាការមានសមត្ថកិច្ច ដើម្បីបញ្ចៀសស្វែងរកយុត្តិធម៌ពិតប្រាកដ ។ ការប្រព្រឹត្តអំពើហិង្សាទៅលើសាក្សីដែលពុំទាន់បានផ្តល់ ភស្តុតាង ឬសក្ខីកម្ម នេះដោយសារជនល្មើសមានចេតនាគំរាមកំហែងកុំឱ្យសាក្សីទៅផ្តល់ភស្តុតាង ឬជនល្មើសខឹងនិងសាក្សីនោះដឹងរឿងដែលខ្លួនបានប្រព្រឹត្តមិនចង់ឱ្យអ្នកណាដឹង ក៏ទៅប្រើអំពើហិង្សាលើសាក្សី។

- **ចំណុចទី៣. ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីប្តឹងបរិហាររួច**

ចំណុចទី៣ ករណីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងបរិហារ រួច ឬ សុំឱ្យទាមទារព្យសនកម្ម នៅក្នុងចំណុចទី៣ នេះគឺការប្រើអំពើហិង្សាទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីពីព្រោះជននេះបានប្តឹងបរិហារពីបទល្មើស ឬសុំឱ្យមានការជួសជុលព្យសនកម្ម មានន័យថា ជននេះបានប្តឹងរួចហើយទៅសមត្ថកិច្ច ឬស្ថាប័នតុលាការមានសមត្ថកិច្ច។ ដោយគ្រាន់តែជនល្មើសបានដឹងថា ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងបរិហារអំពីបទល្មើសដែលជាអំពើរបស់ខ្លួនរួចហើយទៅសមត្ថកិច្ច ក៏និយាយថាគ្រាន់តែរឿងប៉ុណ្ណឹងអត់សម្រួលគ្នា ចាំបាច់ប្តឹងទៅសមត្ថកិច្ច ? ធ្វើឱ្យជនល្មើសកាន់តែខឹងកាន់តែខ្លាំងក៏ទៅវាយជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីនោះបង្កឱ្យមានរបួសបន្ថែមទៀត។ នេះគឺជា ការប្រើអំពើហិង្សាទៅលើជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានប្តឹងរួចហើយ គឺត្រូវទទួលស្ថានទម្ងន់ទោស តាមមាត្រា ២២០ នៃក្រមព្រហ្មទណ្ឌ។

- **ចំណុចទី៤. សាក្សីបានផ្តល់ភស្តុតាងរួចហើយ**

ចំណុចទី ៤ ករណីសាក្សីបានផ្តល់ភស្តុតាងរួចហើយ ការប្រើអំពើហិង្សាទៅលើសាក្សីដែលបានផ្តល់ភស្តុតាងរួចហើយនៅមុខស្ថាប័នមានសមត្ថកិច្ចណាមួយដូចជាក្នុងដំណាក់កាល ស៊ើបអង្កេត ឬនៅក្នុងដំណាក់កាលនៃការស៊ើបសួរ ឬ ដំណាក់កាលនៃការជំនុំជម្រះ ឬ ដំណាក់កាលនៃនីតិវិធីនៃបណ្តឹងផ្សេងទៀត ។ ដោយជនល្មើសខឹងនិងសាក្សីដែលបានផ្តល់ភស្តុតាងដែលបញ្ជាក់ពីសកម្មភាពរបស់ខ្លួនបានប្រព្រឹត្តដោយពុំចង់ឱ្យអ្នកណាដឹង ដោយមានគំនុំនិងសាក្សីក៏បានប្រើហិង្សាទៅលើសាក្សីនោះតែម្តង។

**ឃ. ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស**

កាលបើអំពើហិង្សានេះត្រូវបានប្រព្រឹត្តដោយ អ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន[95]។

នៅក្នុងចំណុចនេះអ្នករាជការសាធារណៈ គឺជាជនល្មើសដែលមានចេតនាប្រព្រឹត្តអំពើហិង្សាដោយចេតនាទៅលើជនរងគ្រោះជារូបវន្តបុគ្គលណាម្នាក់ដោយប្រព្រឹត្តក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន។

រាល់ការប្រើអំពើហិង្សាដោយចេតនាពីអ្នករាជការសាធារណៈនៅពេលដែលបំពេញមុខងាររបស់ខ្លួន គឺត្រូវទទួលស្ថានទម្ងន់ទោសតាមក្រមព្រហ្មទណ្ឌ។ មានន័យថាអ្នករាជការសាធារណៈ ណាម្នាក់បានប្រើអំពើហិង្សានៅពេលដែលចុះអនុវត្តច្បាប់ ឬបង្ក្រាបបទល្មើស តាមសមត្ថកិច្ចដែលបានកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ឬក៏ក្នុងពេលដែលបំពេញមុខងាររបស់ខ្លួនដោយធ្វើការសហការណ៍គ្នាជាមួយ មន្ត្រីរាជការសាធារណៈដទៃទៀតហើយបានប្រព្រឹត្តអំពើហិង្សាទៅបុគ្គលណាម្នាក់។

**ខ. អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន**

- **អំពើហិង្សាក្នុងគ្រួសារ**

អំពើហិង្សាក្នុងក្រុមគ្រួសារក៏ត្រូវចាត់ទុកជាបទល្មើសហិង្សាផងដែរ ដែលជាអំពើប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន ដែលអាចកើតមាន និងអាចកើតមានទៅលើ ៖

១. ប្តី ឬ ប្រពន្ធ

២. កូនក្នុងបន្ទុក

៣. ជនទាំងឡាយរស់នៅក្នុងបន្ទុកគ្រួសារ ឬជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះតែមួយ។

- **ចំណុចទី ១ ៖ អំពើហិង្សាដែលអាចកើតមានចំពោះប្តី ឬប្រពន្ធ**

ការប្រើអំពើហិង្សាចំពោះប្តី ឬប្រពន្ធក្នុងឋានៈជាសហព័ទ្ធ ឬអនីតិសង្វាសជនដែលបានរួមរស់ជាមួយគ្នាក្នុងដំបូលផ្ទះតែមួយ[96]។ ពាក្យថា សហព័ទ្ធ សំដៅទៅលើ ប្តី ឬ ប្រពន្ធ ទាំងប្តី ទាំងប្រពន្ធ ដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ ចំណែកឯអនីតិសង្វាសជនវិញ គឺសំដៅដល់ជនដែលរស់នៅជាមួយគ្នាដូចប្តីប្រពន្ធតែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ជាមួយគ្នា។

- **ចំណុចទី ២. កូនក្នុងបន្ទុក អាចជាកូនមានខាន់ស្លា ឬកូនឥតខាន់ស្លា ឬកូនស្មុំ**

[95] មាត្រា ២២១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[96] វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត

- **កូនមានខាន់ស្លា** ៖ លុះត្រាតែកូននោះកើតចេញពី ឪពុក ម្ដាយដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាលុះត្រាតែម្ដាយនៃកូននោះមានគភ៌ក្នុងរយៈពេលដែលឪពុក ម្ដាយនៅជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា បានន័យថាកូនដែលកើត ១៨០ថ្ងៃ យ៉ាងតិចក្រោយថ្ងៃអាពាហ៍ពិពាហ៍ ឬ ក្នុងរយៈពេល៣០០ថ្ងៃគិតចាប់ពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍[97] ។

- **កូនឥតខាន់ស្លា** ៖ គឺជាកូនដែលកើតចេញពីឪពុកម្ដាយដែលគ្មានចំណងអាពាហ៍ពិពាហ៍[98] ។ រីឯកូនស្មុំ គឺជាកូនដែលសុំគេមកចិញ្ចឹមដោយស្របច្បាប់ ក្រោមរូបភាព (១) កូនស្មុំពេញលេញ និង (២)កូនស្មុំធម្មតា ។

១. **កូនស្មុំពេញលេញ** គឺជាកូនស្មុំកូនសុំកូនរបស់អ្នកដទៃយកមកចិញ្ចឹមដោយស្របច្បាប់ និងធ្វើឡើងដោយផ្លូវតុលាការដោយទាមទារឱ្យផ្ដាច់ទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្តរវាងឪពុកម្ដាយបង្កើត និងញាតិសណ្ដានរបស់កូនសុំនោះទាំងស្រុងដើម្បីបង្កើតឱ្យមាននូវទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្ត រវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំនោះវិញ ។

២. **កូនសុំធម្មតា** គឺជាការបង្កើតទំនាក់ទំនងញាតិរវាងកូនអ្នកដទៃ និងឪពុកម្ដាយចិញ្ចឹមដែលបានសុំកូនអ្នកដទៃមកចិញ្ចឹមនោះ យកមកចិញ្ចឹមបីបាច់ថែរក្សាដូចជាកូនរបស់ខ្លួនឯង បង្កើតតាមផ្លូវតុលាការ តែមិនបានផ្ដាច់ទំនាក់ទំនងញាតិរវាងឪពុកម្ដាយបង្កើតនៃកូនសុំនោះទេ ពោលគឺទំនាក់ទំនងរវាងឪពុកម្ដាយបង្កើតនៅតែមានអត្ថិភាពនាំឱ្យពួកគេមានសិទ្ធិទាមទារ និងករណីផ្គត់ផ្គង់អាហារកាតព្វកិច្ចគ្នាទៅវិញទៅមក ។

- **ចំណុចទី ៣. ជនទាំងឡាយរស់នៅក្នុងបន្ទុកគ្រួសារ មានន័យថាអ្នកដែលរស់នៅជាមួយគ្នាក្នុងផ្ទះតែមួយដូចជា ៖ ឪពុកម្ដាយ ជីដូនជីតា ជាដើម**

កាលបើអំពើហិង្សានេះ បានប្រព្រឹត្តដោយសហព័ទ្ធ ឬ ដោយអនីតិសង្វាសជនរបស់ជនរងគ្រោះ [99] អំពីកម្រិតអំពីទោសនៃបទល្មើសខាងលើត្រូវយល់ពាក្យសហព័ទ្ធ និងអនីតិសង្វាសជន ក្នុងករណីដែលភាគីណាមួយបំពាបំពានដោយប្រើប្រាស់អំពើហិង្សា ទៅលើភាគីម្ខាងទៀតនោះភាគីបង្កនឹងត្រូវទទួលស្ថានទម្ងន់ទោសតាម ក្រមព្រហ្មទណ្ឌ។

អំពើហិង្សាដែលប្រព្រឹត្តដោយ សហព័ទ្ធ ឬអនីតិសង្វាសជនជាករណីទទួលបានស្ថានទម្ងន់ទោសក្នុងគោលបំណងធ្វើការអប់រំ និងលុបបំបាត់អំពើហិង្សាក្នុងគ្រួសារដែលបង្កឱ្យមានផលប៉ះពាល់ ដល់សេដ្ឋកិច្ចគ្រួសារ សង្គមជាតិ និងធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ជាពិសេសប៉ះពាល់សតិអារម្មណ៍ ព្រមទាំងអនាគតកុមារទៀតផង។

---

[97] មាត្រា ៨២ ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

[98] មាត្រា ៩០នៃច្បាប់ស្ដីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

[99] មាត្រា ២២២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

#### ២.៣.២. ទោសដែលត្រូវអនុវត្តចំពោះបទល្មើសហិង្សាស្ថានមានទម្ងន់ទោស

បទល្មើសហិង្សាដោយចេតនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន )រៀល ។

### ២.៤. ករណីបទល្មើសជាប្រភេទទោសនៃបទឧក្រិដ្ឋ

នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារត្រូវរងនូវការផ្តន្ទាទោសដូចខាងក្រោម៖

- ទោសដាក់ពន្ធនាគារអស់មួយជីវិត ។
- ទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ឆ្នាំ។

#### ២.៤.១. លក្ខខណ្ឌ

ត្រូវចាត់ទុកជាការប្រព្រឹត្តបទល្មើសហិង្សាស្ថិតក្នុងចំណាត់ថ្នាក់នៃបទឧក្រិដ្ឋ ករណីដែលចារីប្រព្រឹត្តបទល្មើសដូចករណីខាងក្រោមនេះ ៖

**ក. ករណីការប្រើអំពើហិង្សាដោយកាត់អវយវៈ ឬពិការភាពជាជនរងគ្រោះ**

ការប្រើអំពើហិង្សាដោយចេតនាទៅលើជនរងគ្រោះដោយកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះត្រូវទទួលស្ថានទម្ងន់ទោស[100]។

អវយវៈ មានន័យថា អង្គ រូបអង្គ រូបរាង សរពាង្គកាយ រាងកាយ ខ្លួនប្រាណ ចំណែក ប៉ែក ឬ ចំណែកតូចធំនៃរូបកាយ[101] ។ ជនល្មើសបានប្រព្រឹត្តអំពើហិង្សាដោយចេតនាដោយប្រើប្រាស់ឧបករណ៍ណាមួយ ដើម្បីធ្វើការកាត់អវយវៈរបស់ជនរងគ្រោះ ដែលបង្កឱ្យមានការឈឺចាប់ និងដាច់ផ្នែកណាមួយទាំងស្រុងនៃរូបរាងកាយ។

ត្រូវបានប្បញ្ញត្តិជាស្ថានទម្ងន់ទោសទៅលើការកាត់អវយវៈរបស់ជនរងគ្រោះ ព្រោះវាបានប៉ះពាល់ទៅដល់ សិទ្ធិបុគ្គលភាព ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី និងរដ្ឋធម្មនុញ្ញ សិទ្ធិបូរណភាពនៃរូបរាងកាយ មនុស្សម្នាក់ៗមានសិទ្ធិទៅលើបូរណភាពរូបរាងកាយរបស់ខ្លួនផ្ទាល់ សិទ្ធិលើអាយុជីវិតដែលតម្រូវឱ្យមានការគោរពពីអ្នកដទៃ។ ការប៉ះពាល់ ឬការបង្កឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយនិងបើកឱ្យជនរងគ្រោះដែលបណ្តាលមកពីអំពើព្យសនកម្មលើរូបកាយ ទាមទារនូវសំណងជួសជុលការអន្តរាយ។ ដូច្នេះ ចារីនៃបទល្មើសត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌផងខាងរដ្ឋប្បវេណីផង។

រីឯការប្រើអំពើហិង្សានាំឱ្យពិការភាពនៃជនរងគ្រោះ ៖ គឺជាការប្រើអំពើហិង្សាដោយចេតនា ទៅលើជនរងគ្រោះដោយធ្វើឱ្យពិការភាពជាអចិន្ត្រៃយ៍។ អ្វីទៅដែលចាត់ទុកថា ពិការភាពជាអចិន្ត្រៃយ៍ ? បើសិនជាអំពើហិង្សាមួយបណ្តាលឱ្យជនរងគ្រោះ ដាច់ម្រាមដៃ ឬម្រាមជើងណាមួយចាត់ទុជាពិការអចិន្ត្រៃយ៍នោះទេ គឺទាល់តែជន

[100] មាត្រា ២២៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[101] វចនានុក្រម សម្តេចសង្ឃរាជ **ជួន ណាត**

រងគ្រោះនោះ ពិការកាយសម្បទា ដាច់ដៃ ដាច់ជើង ស្វិតដៃ ស្វិតជើង ថ្លង់ស្តាប់លែងបាន ឬធ្វើឱ្យជនរងគ្រោះនោះ ច្រៀងរាំខុសប្រក្រតី ទើបអាចចាត់ទុកថាជាពិការអចិន្ត្រៃយ៍។ ក្នុងករណីដែលជនល្មើសបង្កហិង្សាបណ្តាលឱ្យជនរងគ្រោះពិការភាពត្រូវទទួលស្ថានទម្ងន់ទោសផងដែរ។

**កំណត់សម្គាល់ ៖** ចំពោះករណីដែល ពុំទទួលស្ថានទម្ងន់ទោស លើការកាត់អវយវៈដោយការព្យាបាលជម្ងឺដោយមានការយល់ព្រមពីជនរងគ្រោះ ការរក្សាសន្តិសុខសាធារណៈជាដើម។

**ខ. ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ**

ការប្រើអំពើហិង្សាដោយចេតនាទៅលើជនរងគ្រោះបណ្តាលឱ្យជននោះ បាត់បង់ជីវិតដោយគ្មានចេតនាសម្លាប់ នោះជនល្មើសត្រូវទទួលស្ថានទម្ងន់ទោសតាមច្បាប់កំណត់[102]។ ជនល្មើសគ្មានចេតនាសម្លាប់ ឬផ្តាច់យកជីវិត របស់ជនរងគ្រោះឡើយ ដោយគ្រាន់តែចង់បង្ករបួសស្នាម ឬវាយឱ្យជនរងគ្រោះសន្លប់ រួចក៏បញ្ឈប់អំពើរបស់ខ្លួនទៅវិញ ។ ដូចក្នុងករណីអំពើហិង្សាមួយបានកើតឡើង នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ រវាងសិស្សសាលា ពីរនាក់ ដោយសារការខឹង និងប្រកាន់គ្នាទៅវិញទៅមករឿងហៅមិនគោរព( ឈ្លើយ )។ ជនល្មើសមានអាយុច្រើនជាង ជនរងគ្រោះហើយជនរងគ្រោះមិនគោរព ឬគួរសមដោយតែងតែហៅជនល្មើស អា ធ្វើឱ្យជនល្មើសទ្រាំពុំបានថាអាក្មេងឈ្លើយ ក៏បបួលគ្នាវាយមួយស្មើទៅ។ ដោយ ជនល្មើសបានខឹងនិងជនរងគ្រោះក៏វាយជនរងគ្រោះមួយដៃដួលសន្លប់លើដី នៅពេលដែលជនរងគ្រោះដួលសន្លប់ទៅលើដីគឺ នៅមានដង្ហើមជាធម្មតា។ ពេលឃើញជនរងគ្រោះដួលសន្លប់បែបនេះ ជនល្មើសក៏បញ្ឈប់សកម្មភាពរបស់ខ្លួនទៅលើជនងរងគ្រោះដោយខ្លួនគ្រាន់តែមានចេតនាប្រើអំពើហិង្សាគំរាមជនរងគ្រោះថ្ងៃក្រោយឈប់ហៅមិនគួរសមបែបនេះទៀត។ ប៉ុន្តែពេលដែលបញ្ជូនជនរងគ្រោះទៅមន្ទីពេទ្យស្រាប់តែជនរងគ្រោះបានបាត់បង់ជីវិត។ ក្នុងករណីនេះវាពុំមែនជាករណីឃាតកម្មឡើយ បើទោះបីជា ជនរងគ្រោះបានស្លាប់បាត់បង់ជីវិតក៏ដោយ ព្រោះជនល្មើសគ្មានចេតនាក្នុងការសម្លាប់ជនរងគ្រោះទេ។

**កំណត់សម្គាល់ ៖** ចំពោះករណីនេះបើយើងសិក្សា ពុំអាចជាមូលហេតុនៃការប្រព្រឹត្តិ បទឃាតកម្ម តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌទេ។ អំពើឃាតកម្ម គឺជនល្មើសមានចេតនាសម្លាប់ជនរងគ្រោះតែម្តង ចំណែកឯហិង្សាស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ គឺជនល្មើសគ្មានចេតនាសម្លាប់ជនរងគ្រោះដូចករណីឃាតកម្មឡើយ។

**២.៤.២. ទោសដែលត្រូវអនុវត្តចំពោះករណីបទល្មើសជាប្រភេទនៃបទឧក្រិដ្ឋ**

អំពើហិង្សាដោយចេតនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ( ប្រាំ ) ឆ្នាំ ទៅ ១០ ( ដប់ ) ឆ្នាំ កាលបើអំពើនេះនាំឱ្យ

[102] មាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

មានការកាត់អវយវៈ ឬ ឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ និងបទល្មើសហិង្សាស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ ត្រូវដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ តែប៉ុណ្ណោះ ។

### ២.៥. ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល

នីតិបុគ្គល អាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)[103] ដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួនដើម្បីប្រយោជន៍របស់នីតិបុគ្គលនោះ។ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២២៦ (ការចាត់ទុកការផ្តល់អាហារដែលមានសារជាតិពុលដូចជាអំពើហិង្សាដោយចេតនា) និងមាត្រា ២២៧ (ការចាត់ទុកការបញ្ចូលសារជាតិពុលក្នុងទឹកសម្រាប់បរិភោគ ដូចជាអំពើហិង្សាដោយចេតនា) នៃក្រមនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ ៖

១. ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និង ការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២. ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣. ការហាមឃាត់ចំពោះការធ្វើសកម្មភាពណាមួយ ឬ ច្រើនតាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤. ការបណ្តេញចេញពី លទ្ធកម្មសាធារណៈតាមបែបបទកំណត់ដោយមាត្រា ១៧៣ ( ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ) នៃក្រមព្រហ្មទណ្ឌ ។

៥. ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ ( ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ ) នៃក្រមព្រហ្មទណ្ឌ ។

៦. ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ ( ការបិទគ្រឹះស្ថាន ) ។

៧. ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ ( ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមព្រហ្មទណ្ឌ ។

[103] មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

៨. ការរឹបអូស ឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅ សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ ( ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស ) និង មាត្រា ១៧៩ ( ការរឹបអូស និង សិទ្ធិ តតីយជន ) នៃក្រមព្រហ្មទណ្ឌ ។

៩. ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ ( ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស ) និងមាត្រា១៧៩ ( ការរឹបអូស និង សិទ្ធតតិយជន ) នៃក្រមព្រហ្មទណ្ឌ ។

១០. ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ ( ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស ) និង មាត្រា ១៧៩ ( ការរឹបអូស និង សិទ្ធិតតិយជន ) នៃក្រមព្រហ្មទណ្ឌ ។

១១. ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ ( ការបិទផ្សាយសេចក្ដីសម្រេច ) នៃក្រមព្រហ្មទណ្ឌ ។

១២. ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសាពត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ ( ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍នៃក្រមព្រហ្មទណ្ឌ ។

## ២.៦. ទោសបន្ថែម ប្រភេទ និងរយៈពេលនៃបទល្មើសហិង្សាដោយចេតនា

បទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស ៖

១. ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ ( ប្រាំ ) ឆ្នាំ យ៉ាងច្រើន ។

២. ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជិវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈរបស់ខ្លួន ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ ( ប្រាំ ) ឆ្នាំ យ៉ាងច្រើន ។

៣. ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយ់ពេល ១០ ( ដប់ ) ឆ្នាំ យ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយ់ពេល ៥ ( ប្រាំ ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤. ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ ( ប្រាំ ) ឆ្នាំ យ៉ាងច្រើន ។

៥. ការរឹបអូស ឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦. ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ ( ប្រាំ ) ឆ្នាំ យ៉ាងច្រើន ។

៧. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ ( ពីរ ) ខែ យ៉ាងច្រើន ។

៨. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសាពត៌មាន ។

៩. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ ( ប្រាំបី ) ថ្ងៃយ៉ាងច្រើន ។

# ជំពូកទី ៣

# ករណីសិក្សាទាក់ទងទៅនឹងប្រធានបទ

# ជំពូកទី៣

# ករណីសិក្សាទាក់ទងទៅនឹងប្រធានបទ

## កថាខណ្ឌទី១ ៖ ករណីស្ថិតក្នុងបទល្មើសហិង្សាក្នុងគ្រួសារ

### ករណីសិក្សាទី១

លោកស្រី **ស.ស.ម.** អាយុ ៣៧ ឆ្នាំ ស្នាក់នៅភូមិព្រៃករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល មុខរបរកម្មករសំណង់ ជាស្ត្រីមេម៉ាយមានកូន ០៣ នាក់ និងបានរួមរស់ជាអនីតិសង្វាសជនជាមួយប្តីក្រោយ (ជនសង្ស័យ) បានកូន ០១ នាក់ និងកំពុងមានផ្ទៃពោះ ០៦ខែ ទៀត។ ដោយគាត់បានរស់នៅជាមួយគ្នារយៈពេល ០៦ ឆ្នាំមកហើយ។

នៅថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៩ និង ៣០នាទីយប់ ជនសង្ស័យបានផឹកស្រាស្រវឹងហើយឈ្លោះប្រកែកគ្នាយ៉ាងខ្លាំងជាមួយជនរងគ្រោះ បន្ទាប់មកជនសង្ស័យក៏បាន ទាត់មួយជើងត្រូវចំ "ពោះ" របស់ជនរងគ្រោះបណ្ដាលឱ្យដួលអុកគូទហ្នឹងកន្លែង។ រហូតដល់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ ២០២០ វេលា ម៉ោង ១០ ព្រឹក ដោយស្ត្រីរងគ្រោះមានអាការៈខុសប្រក្រតី ក្តៅខ្លួនខ្លាំង រងាស្រៀវស្រាញក៏បានជិះម៉ូតូឌុបទៅជួបបងប្អូនដើម្បីទៅសម្រាកព្យាបាលនៅមន្ទីពេទ្យរុស្សី។ ដោយសារប្តីវាយមានរបួសស្នាម ជាំ ត្រកៀក ជាំដៃស្តាំ និងជាំភ្នែក នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ០១ និង ១៥ នាទីយប់ដោយអាការៈធ្ងន់ធ្ងរ កូនស្លាប់ក្នុងពោះ រលាកសួតធ្ងន់ធ្ងរ និងមានជម្ងឺអេដស៍ផងនោះបណ្តាលឱ្យស្ត្រីជាជនរងគ្រោះបាត់បង់ជីវិតទៅ។

បន្ទាប់ពីបានធ្វើបុណ្យចប់សព្វគ្រប់រួចរាល់បងប្អូន និងកូនៗរបស់ស្ត្រីរងគ្រោះបានដាក់ពាក្យបណ្តឹងមកកាន់នគរបាលប៉ុស្តិ៍កំពង់សំណាញ់ ដើម្បីធ្វើការឃាត់ខ្លួនជនសង្ស័យ ចាត់ការតាមនីតិវិធីច្បាប់។

**កំណែលំហាត់អនុវត្ត**

អំពើហិង្សាក្នុងគ្រួសារ គឺជាការរំលោភបំពានដោយមនុស្សម្នាក់ប្រឆាំងក្នុងការកំណត់ក្នុងគ្រួសារដូចជានៅក្នុងអាពាហ៍ពិពាហ៍ ឬដែលមានលក្ខណៈប្រមាថ មាក់ងាយ ការរំលោភបំពានការគំរាមកំហែងលើផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្នែកសេដ្ឋកិច្ចដល់មនុស្សណាម្នាក់ ឬច្រើននាក់ ដើម្បីត្រួតត្រាទៅលើមនុស្សផ្សេងៗទៀតដែលកំពុងរស់នៅក្នុងក្រុមគ្រួសារនោះ។

កាលពីថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ ២០២០ ជនសង្ស័យបានផឹកស្រាស្រវឹងឈ្លោះប្រកែកជាមួយជនរងគ្រោះបណ្តាលឱ្យកើតមានអំពើហិង្សា ប្តីវាយប្រពន្ធជាជនរងគ្រោះត្រូវចំ "ពោះ" ដែលកំពុងមានផ្ទៃពោះរយៈពេល ០៦ ខែដួលអុកគូទ និងរងរបួសជាំ ត្រកៀក ដៃស្តាំ និងជាំភ្នែក។

នៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០២០ ដោយសារមានអាការៈមិនប្រក្រតី ក្តៅខ្លួនខ្លាំង រងាស្រៀវស្រាញក៏បានធ្វើដំណើរជិះម៉ូតូឌុបទៅផ្ទះបងប្អូន រួចបន្តទៅព្យាបាលនៅមន្ទីពេទ្យ រុស្សី ។ រហូតដល់ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ

២០២០ វេលាម៉ោង ០១ និង ១៥ នាទីយប់ ដោយអាការៈធ្ងន់ធ្ងរ កូនស្លាប់ក្នុងផ្ទៃ រួមផ្សំជម្ងឺលោកសួតធ្ងន់ធ្ងរ និងជម្ងឺអេដស៏ផងនោះបណ្តាលឱ្យជនរងគ្រោះបានបាត់បង់អាយុជីវិត។

សំណួរសួរថា ៖ តើក្នុងករណីដែលបណ្តាលឱ្យជនរងគ្រោះស្លាប់នេះវាជា បទល្មើសឃាតកម្ម ឬបទល្មើសហិង្សាស្ថានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ ?

មុននឹងកំណត់លទ្ធភាពតាមផ្លូវច្បាប់ ដែលប្រឆាំងនឹងបទល្មើសយើងត្រូវកំណត់អំពើរបស់ជនល្មើសថាអំពើល្មើសនោះត្រូវនឹងលក្ខខណ្ឌអ្វីខ្លះដែលច្បាប់ព្រហ្មទណ្ឌបានកំណត់ថាជាបទល្មើសឃាតកម្ម និងបទល្មើសហិង្សាមានស្ថានទម្ងន់ទោស។

**១. ធាតុផ្សំនៃបទល្មើស**

យោងតាមស្មារតីនៃក្រមព្រហ្មទណ្ឌបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌបើសិនអំពើនោះបានបំពេញគ្រប់ធាតុផ្សំនៃបទល្មើស។

**ក .ធាតុនីត្យានុកូល ឬធាតុច្បាប់**

ធាតុនីត្យានុកូលលុះត្រាតែមានច្បាប់ចែងកំណត់ទុកជាមុនថាអំពើជាបទល្មើស និងទោសដែលត្រូវអនុវត្តបានចែងជាធរមាន ទើបអំពើនោះត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌ។

- មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ បទឃាតកម្ម គឺជាអំពើសម្លាប់មនុស្សដោយចេតនាដោយប្រើអាវុធ ឬមិនប្រើអាវុធត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។
- បទហិង្សាដោយចេតនាមាត្រា ២២៤ ស្ថានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ នៃក្រមព្រហ្មទណ្ឌ ត្រូវចាត់ទុកការប្រព្រឹត្តដោយចេតនាទុច្ចរិតបង្កឱ្យអ្នកដទៃរងរបួសស្នាម ឬគ្មានរបួស ឬខូចសុខភាព ឬបាត់បង់អាយុជីវិតដោយគ្មានចេតនាសម្លាប់ ដោយប្រើអាវុធ ឬគ្មានអាវុធ គំរាមនឹងប្រើអាវុធដោយមានចេតនាគិតទុកជាមុន ដោយចូលរួមប្រព្រឹត្តដោយមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និង អ្នកសមគំនិត ។

**ខ . ធាតុផ្សំសត្យានុម័ត**

សំដៅទៅលើអំពើរបស់ជនល្មើសបានប្រព្រឹត្តបទល្មើសស្តែងចេញមកខាងក្រៅតាមរយៈ អំពើបង្កគ្រោះថ្នាក់ដល់សង្គម បច្ច័យគ្រោះថ្នាក់ដល់សង្គម ( ការអន្តរាយ ) ដោយមានទំនាក់ទំនងហេតុនិងផលរវាងអំពើ នឹងបច្ច័យដែលកើតចេញពីអំពើនោះ។

- អំពើនៅក្នុងបទឃាតកម្ម ស្តែងឡើងដោយអំពើសម្លាប់ជីវិតមនុស្ស ឬអំពើផ្តាច់យកជីវិតមនុស្ស សម្ភារៈនៃការសម្លាប់អាចស្តែងឡើងដោយតាមគ្រប់មធ្យោបាយដោយ ការបំពុល ដោយប្រើអាវុធ ឬ គ្មានអាវុធដោយប្រើខ្សែរឹត ក ឬឆក់និងចរន្តអគ្គិសនីជាដើម ។ល។

- អំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ស្តែងឡើងជាអំពើសកម្មដែលអំពើនោះគ្រាន់តែចង់បង្ក ឱ្យមានស្នាមរបួស ឬគ្មានរបួស ឬខូចសុខភាព ឬបង្កឱ្យបាត់បង់អាយុជីវិតដោយគ្មានចេតនាសម្លាប់ជា សកម្មភាពប្រើអាវុធ ឬមិនប្រើអាវុធ ការកាប់ ចាក់ ដាល់មួយដៃ ធាក់មួយជើង ឱ្យជនរងគ្រោះផឹក ឬលេប ឬបញ្ចូលទៅក្នុងខ្លួនតាមគ្រប់មធ្យោបាយដោយចេតនានូវសារជាតិពុល ឬការលក់ ឬការធ្វើ អនុប្បទាន ជាដើម។

**គ. ធាតុផ្សំអត្តនោម័ត**

គឺជា កិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះការបង្កឱ្យមានគ្រោះថ្នាក់ដែលអំពើនោះមានបី គឺកំហុសដោយ ចេតនា ឬអចេតនា គំនិតផ្តួចផ្តើម និងគោលដៅនៃការប្រព្រឹត្តបទល្មើស។

- ធាតុផ្សំអត្តនោម័តនៃបទឃាតកម្ម សំដៅដល់ចេតនាសម្លាប់របស់ចារីទៅលើជនរងគ្រោះ ចេតនា សម្លាប់នេះគឺជាធាតុសំខាន់សម្រាប់ធ្វើការបែងចែកបទឃាតកម្ម និងបទល្មើសដទៃទៀត។ ជាទូទៅ ចេតនាសម្លាប់មនុស្សគឺ មិនត្រឹមតែទាញចេញពីឆន្ទៈរបស់ជនល្មើសក្នុងការប្រព្រឹត្តប៉ុណ្ណោះទេ គឺគេត្រូវ គិតពីសតិយល់ដឹងរបស់ជនល្មើសក្នុងការចង់ទទួលបាននូវលទ្ធផលនៃអំពើរបស់ខ្លួនផងដែរ។
- ធាតុផ្សំអត្តនោម័តនៃបទហិង្សាមានស្ថានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ គឺជនល្មើស មានចេតនាធ្វើឱ្យជនរងគ្រោះឈឺចាប់លើរូបរាងកាយ ឬខូចសុខភាព មានន័យថា ជនល្មើសពុំមាន ចេតនាសម្លាប់ជនរងគ្រោះនោះទេ។

តាមស្ថានភាពដូចដែលបានរៀបរាប់នៅក្នុងអង្គហេតុខាងលើ កាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០២០ គឺជាការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ ដែលអំពើហិង្សានោះប៉ះពាល់ដល់ផ្លូវកាយ ផ្លូវចិត្ត។ មានន័យថា មូល ហេតុនៃការស្រវឹងស្រាហើយប្រើអំពើហិង្សា មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ដែលអំពើនោះ ធ្វើឱ្យជនរងគ្រោះមានការឈឺចាប់ ដោយសារការទាត់ចំ "ពោះ" ដែលកំពុងមានផ្ទៃពោះរយៈពេល ០៦ ខែ ថែម ទាំងមានស្នាមជាំត្រកៀក ជាំដៃស្តាំ និងជាំភ្នែក និងឈានដល់អាការៈធ្ងន់ធ្ងររហូតដល់ស្លាប់ បើទោះបីជនរង គ្រោះមានជម្ងឺ ប្រចាំកាយក៏ដោយនោះ។ ដូច្នេះតាមសម្មតិកម្មខាងលើបានបំពេញគ្រប់ធាតុផ្សំនៃបទល្មើសដែល អាចធ្វើឱ្យជនល្មើសត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។

ដូច្នេះយើងអាចនិយាយបានថា ជនល្មើសដែលជាប្តីត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាធរមាន។

**២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះអំពើខាងលើ**

មាត្រា ១៩៩ បទឃាតកម្ម នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬ មិនប្រើអាវុធដោយគ្មានស្ថានទម្ងន់ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (បទឃាតកម្ម

គិតទុកជាមុន) ដល់មាត្រា ២០៥ ( បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ) គឺជាបទឃាតកម្ម។ ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ។

បើសិក្សាទៅលើនិយមន័យនៃបទឃាតកម្ម និងធាតុផ្សំបទល្មើសយើងសង្កេតឃើញថា អំពើរបស់ជនល្មើសខាងលើពុំមែនជា បទឃាតកម្មនោះទេ ព្រោះបើយើងសិក្សាទៅលើធាតុផ្សំអត្តនោម័តជនល្មើសពុំមែនមានចេតនាសម្លាប់ជនរងគ្រោះនោះទេ ដោយគ្រាន់តែមានចេតនា បង្ករបួសស្នាម គំរាមកំហែងជនរងគ្រោះតែប៉ុណ្ណោះ ចំពោះការចង់ផ្តាច់យកជីវិតពុំមានឡើយ បើទោះបីជនរងគ្រោះនោះបានបាត់បង់ជីវិតក៏ដោយ។ ដូច្នេះអំពើដែលជនបានប្រព្រឹត្តពុំមែនជាឃាតកម្មនោះទេ។

ប៉ុន្តែបើយើងបកមកមើលមាត្រា ២១៧ ហិង្សាដោយចេតនា ដល់មាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌហិង្សាមានស្ថានទម្ងន់ទោសយើងអាចមើលឃើញថាវាចូលក្នុងករណីជាច្រើន នៅក្នុងចំណុចហិង្សាមានស្ថានទម្ងន់ទោស ដែលមានចែងក្នុងមាត្រាខាងក្រោម ៖

- មាត្រា ២១៩ ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ កថាខណ្ឌទី ២ អំពើហិង្សាប្រព្រឹត្តទៅលើនារីមានគភ៌កាលដែលគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។ កថាខណ្ឌទី៣ បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជម្ងឺ ឬ ពិការភាពកាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង។
- មាត្រា ២២២ អំពើហិង្សាដោយចេតនាប្រព្រឹត្តដោយសហាព័ទ្ធ ឬ អនីតិសង្វាសជន។
- និងមាត្រា ២២៤ ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ។

**សេចក្តីសន្និដ្ឋាន**

យោងតាមការបកស្រាយខាងលើ យើងឃើញថាអំពើរបស់ជនល្មើសគឺមិនមែនជាបទឧក្រិដ្ឋនោះទេ តែវាជាបទហិង្សាមានស្ថានទម្ងន់ទោសស្ថិតក្នុងមាត្រា ២២៤ ស្ថានទម្ងន់ដោយសារមរណភាពជនរងគ្រោះ ដោយយើងអាចសន្នត់បានថា បើទោះបីជាអំពើដែលបានប្រព្រឹត្តចូលក្នុងមាត្រា ២១៩ កថាខណ្ឌទី២ កថាខណ្ឌទី ៣ និងមាត្រា ២២២ អំពើហិង្សាប្រព្រឹត្តដោយសហាព័ទ្ធ ឬ អនីតិសង្វាសជនក៏ដោយ ក៏គប្បីត្រូវបានចោទប្រកាន់ពីបទហិង្សាមានស្ថានទម្ងន់ដោយសារមរណភាពជនរងគ្រោះ តាមមាត្រា ២២៤នៃក្រមព្រហ្មទណ្ឌជាធរមាន ។

## កថាខណ្ឌទី២ ៖ ករណីស្ថិតក្នុងបទល្មើសហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស

### ករណីសិក្សាទី ២

ការដាក់ថ្នាំងងុយដេកក្នុងចំណីអាហារដោយចុងភៅ ក្នុងថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង០១ រំលងអាធ្រាតស្ថិតនៅ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ជនរងគ្រោះឈ្មោះ **ហ.ល** ភេទប្រុស

អាយុ ៣០ឆ្នាំ មុខរបរ បុគ្គលិកក្រុមហ៊ុន ស្នាក់នៅ ភូមិចម្រើនផល សង្កាត់បឹងទំពុនទី ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-ជនសង្ស័យទី ១ ឈ្មោះ **ស.ច.ន** ភេទប្រុស អាយុ ២៦ឆ្នាំ មុខរបរ ចុងភៅ (ប្រចាំផ្ទះជនរងគ្រោះផ្ទាល់) និងរស់នៅជាមួយជនរងគ្រោះ។

-ជនសង្ស័យទី ២ ឈ្មោះ **ត.ស.ណ** អាយុ ២៥ ឆ្នាំ ជាប្រពន្ធរបស់ជនរងគ្រោះ។

**អង្គហេតុ ៖**

នៅពេលដែលជនរងគ្រោះត្រឡប់មកពីធ្វើការវិញ ពេលហូបបាយហើយតែងតែងងុយដេក និងពេលខ្លះគេងលក់ទាំងមិនដឹងខ្លួននៅលើតុបាយ ហើយចេះតែមានអាការៈឈឺក្រពះ ទើបនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០២០ គាត់បានទៅគ្លីនិកឯកជនមួយកន្លែងដើម្បីធ្វើការពិនិត្យសុខភាពរបស់គាត់។ ពេទ្យបានធ្វើការសុងក្រពះរបស់គាត់ក៏ឃើញថាគាត់មានជម្ងឺរលាកក្រពះធ្ងន់ធ្ងរ ដោយសារការប្រើប្រាស់ថ្នាំងងុយដេកច្រើនហួសកម្រិត ប៉ុន្តែបុរសនោះបានប្រកែកថាខ្លួនមិនបានប្រើប្រាស់ថ្នាំ ងងុយដេកនោះទេ គឺមានតែគាត់គេងលក់ទាំងមិនដឹងខ្លួនពេលដែលកំពុងហូបបាយក៏មាន។ ដោយការសង្ស័យជនរងគ្រោះបានធ្វើការស៊ើបអង្កេត ក៏បានដឹងថា ចុងភៅ (ជនសង្ស័យ) ដែលធ្វើការក្នុងផ្ទះរបស់ខ្លួនបានដាក់ថ្នាំងងុយដេក ចូលទៅក្នុងបាយ និងម្ហូបដែលខ្លួនបរិភោគ ។

ទើបនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០១ រំលងអាធ្រាត ជនរងគ្រោះបានចាប់ជនសង្ស័យប្រគល់ទៅឱ្យសមត្ថកិច្ច។ នៅមុខសមត្ថកិច្ចជនសង្ស័យបានសារភាពថា ខ្លួនពិតជាបានដាក់ថ្នាំងងុយដេកនេះចូលទៅក្នុង ចំណីអាហារ អស់រយៈពេល ០២ ខែមកហើយ គឺចាប់ពីខែ ០៦ មកម្ល៉េះ។ ដែលមេខ្លោងគឺជា ប្រពន្ធរបស់ជនរងគ្រោះដែលបានយកថ្នាំងងុយដេកឱ្យជនសង្ស័យ (ចុងភៅ) រយៈពេល ០៣ ថ្ងៃម្តង ដើម្បីដាក់ក្នុងបាយសម្លរបស់ប្តីឱ្យគេងលក់ មូលហេតុដោយសារចង់រួមភេទជាមួយចុងភៅនោះ។

**កំណែលំហាត់អនុវត្ត**

ការប្រើថ្នាំងងុយដេក ដែលបណ្តាលឱ្យជនរងគ្រោះខូចសុខភាពយ៉ាងធ្ងន់ធ្ងរត្រូវចាត់ដូចជាការប្រើអំពើហិង្សាដោយចេតនា។

នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ជនរងគ្រោះបានទៅពិនិត្យសុខភាពដោយទទួលបានលទ្ធផលគឺមានជម្ងឺរលាកក្រពះធ្ងន់ធ្ងរដោយការប្រើថ្នាំងងុយដេកហួសកម្រិត តែគាត់មិនដែលប្រើប្រាស់ថ្នាំងងុយដេកពីមុនមកទេ។ ដោយការសង្ស័យគាត់បានស៊ើបអង្កេត បានដឹងថាចុងភៅរបស់គាត់បានដាក់ថ្នាំងងុយដេកនោះចូលទៅក្នុងម្ហូប អាហាររបស់គាត់។

ទើបនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០១ រំលងអាធ្រាត ជនរងគ្រោះបាន់ចាប់បញ្ជូនជនសង្ស័យ (ចុងភៅ) ទៅសមត្ថកិច្ច។ នៅមុខសមត្ថកិច្ចជនសង្ស័យបាន សារភាពថាខ្លួនពិតជាបានដាក់ថ្នាំងងុយ

ដេកនោះចូលក្នុង ម្ហូបអាហារពិតប្រាកដមែន និងមានរយៈពេល ០២ ខែមកហើយ។ ដោយមេខ្លោងគឺ ជាប្រពន្ធរបស់ជនរងគ្រោះ តែងតែយកថ្នាំងងុយដេកមកឱ្យខ្លួនដាក់ក្នុង ម្ហូបអាហាររបស់ប្តីរៀងរាល់ ០៣ ថ្ងៃម្តងដើម្បីឱ្យប្តីរបស់ខ្លួនគេងលក់មូលហេតុគឺ ចង់រួមភេទជាមួយខ្លួន(ចុងភៅ)។

តើអំពើនៃការប្រើប្រាស់ថ្នាំងងុយដេកបណ្តាលឱ្យជនរងគ្រោះរងរបួសនេះ តើវាអាចចាត់ទុកជាហិង្សាស្ថានទម្ងន់ទោសដែរឬទេ ?

មុននិងអាចកំណត់បានថា អំពើខាងលើអាចទុកថាជាបទហិង្សាដោយចេតនា ឬហិង្សាមានស្ថានទម្ងន់ទោសយើងត្រូវពិនិត្យទៅលើអំពើនោះថាវាមានព្យសនកម្ម ដល់ជនរងគ្រោះកម្រិតណា ហើយតើច្បាប់បានកំណត់ថាអំពើនោះជាត្រូវទទួលស្ថានទម្ងន់ទោសដែរឬទេ ? ហើយតើក្នុងករណីនេះជនសង្ស័យត្រូវទទួលទោសយ៉ាងដូចម្តេច?

**១. វិចារណាគតិយុត្ត**

- យោងតាមមាត្រា ២១៧ អំពើហិង្សាប្រព្រឹត្តដោយចេតនាទៅលើអ្នកដទៃ បណ្តាលឱ្យ រងរបួស ឬ គ្មានរបួស រងការឈឺចាប់ ឬ ខូចសុខភាពត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

- ចំពោះមាត្រា ២២៥ ការចាត់ទុកការប្រើសារជាតិពុលដូចជាអំពើហិង្សាដោយចេតនា អំពើដែលឱ្យអ្នកដទៃផឹកលេប ឬបញ្ចូលទៅក្នុងខ្លួនអ្នកដទៃ តាមមធ្យោបាយណាក៏ដោយ ដោយចេតនានូវសារជាតិពុលដែលបណ្តាលឱ្យខូចសុខភាព ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

- និងមាត្រា ២១៨ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស អំពើដោយចេតនាកាលបើអំពើនោះបានប្រព្រឹត្ត ៖

១–ដោយមានការគិតទុកជាមុន ។

២–ដោយប្រើអាវុធ ឬគំរាមកំហែងនឹងប្រើអាវុធ ។

៣–ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និង ជាអ្នកសមគំនិត ។

ត្រូវផ្តន្ទាទោសដាក់ពន្ធាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លានលាន) រៀល ។

អង្គហេតុខាងលើ យើងមើលឃើញថាការដាក់ថ្នាំងងុយដេក មានរយៈពេល០២ខែមកហើយ បណ្តាលឱ្យជនរងគ្រោះរលាកក្រពះធ្ងន់ធ្ងរ អំពើនេះត្រូវចាត់ទុកជាការប្រើអំពើហិង្សាតាមមាត្រា ២២៥ ដែលអំពើរបស់ជនសង្ស័យមានចេតនាផ្តល់នូវសារជាតិពុលបណ្តាលឱ្យខូចសុខភាព ។ ដោយហេតុថាការប្រើប្រាស់ថ្នាំងងុយដេកដាក់ក្នុងចំណីអាហារនេះគឺ ជនល្មើសគ្រាន់តែចង់ឱ្យជនរងគ្រោះគេងលក់រួចដើម្បីប្រព្រឹត្តអំពើផិតតែប៉ុណ្ណោះ។

ប៉ុន្តែបើយើងសិក្សាទៅលើអង្គហេតុជាក់ស្តែងយើងសង្កេតឃើញថា អំពើដែលប្រព្រឹត្តខាងលើចូលទៅក្នុងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដែលមានចែងក្នុងមាត្រា ២១៨ ដោយសារយើងមើលឃើញថា អំពើនៃការប្រព្រឹត្តនេះ បានចូលរួមដោយមនុស្សច្រើននាក់ក្នុងឋានៈជា ចារី សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត។ ដោយប្រពន្ធរបស់ជនរងគ្រោះ (ជនសង្ស័យទី២) ជាអ្នកផ្តើមគំនិត បានឱ្យថ្នាំងងុយគេងរៀងរាល់ ០៣ ថ្ងៃម្តងទៅឱ្យ ចុងភៅ (ជនសង្ស័យទី១) ជាចារី ដើម្បីដាក់ក្នុង ម្ហូបអាហាររបស់ជនរងគ្រោះ។

**២. ការទទួសខុសត្រូវតាមច្បាប់**

ដូច្នេះករណីនេះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមមាត្រា ២១៨ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងការទទួលខុសត្រូវតាមច្បាប់ឯកពន្ធភាព ឆ្នាំ២០០៦ មាត្រា ៧ ចានចែងថា ៖

ត្រូវចាត់ទុកថា ផិត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រំលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។ ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទផិត ៖

- បុរសណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុន មិនទាន់រំលាយហើយទៅរួមសេវនកិច្ចជាមួយស្ត្រីផ្សេងទៀត ។
- ស្ត្រីណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រំលាយ ហើយទៅរួមសេវនកិច្ចជាមួយបុរសដទៃទៀត ។

**សេចក្តីសន្និដ្ឋាន**

យោងតាមការបកស្រាយខាងលើ យើងសង្កេតឃើញថា បើសិនជាក្នុងករណី ពុំមានការចូលរួមប្រព្រឹត្តពីប្រពន្ធជនរងគ្រោះនោះទេ គឺជាហិង្សាដោយចេតនា ដែលបណ្តាលឱ្យខូចសុខភាពជនរងគ្រោះតាមមាត្រា ២២៥ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែតាមអង្គហេតុជាក់ស្តែងគឺ ត្រូវចូលក្នុងមាត្រា ២១៨ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស។ ដូច្នេះអំពើដែលផ្តល់នូវសារជាតិពុលទាំងឡាយណាដោយគ្រាន់តែបង្កឱ្យខូចសុខភាព ពុំមែនជាហិង្សាមានស្ថានទម្ងន់ទោសទេ តែបើសិនអំពើនោះប្រព្រឹត្តដោយការគិតទុកជាមុន ដោយប្រើអាវុធ ឬ គំរាមនិងប្រើអាវុធ មានមនុស្សច្រើននាក់ចូលរួមប្រព្រឹត្តក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិត ត្រូវទទួលស្ថានទម្ងន់ទោស។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីយើងខ្ញុំបានធ្វើការសិក្សាទៅលើប្រធានបទខាងលើរួចមក យើងខ្ញុំសង្កេតឃើញថាបទល្មើសហិង្សាដោយចេតនា ជាប្រភេទនៃបទល្មើសមជ្ឈិមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។ ដោយការបង្កអំពើហិង្សាដោយចេតនានេះវាបានធ្វើឱ្យប៉ះពាល់ដល់ រូបរាងកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្នែកសេដ្ឋកិច្ចដល់ជនរងគ្រោះជាដើម ។

យោងតាមក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ មាត្រា២១៧ បានកំណត់ពី បទហិង្សាដោយចេតនា គឺសំដៅទៅលើចេតនាទុច្ចរិតទាំងឡាយណាដែលបង្កឱ្យអ្នកដទៃ រងរបួស ឬ គ្មានរបួស ខូចសុខភាព រងការឈឺចាប់ ទាំងផ្លូវកាយ និងផ្លូវចិត្ត ខូចខាតទ្រព្យសម្បត្តិ ឬបណ្តាលឱ្យមានមរណភាពនៃជនរងគ្រោះដោយជនល្មើសគ្មានចេតនាសម្លាប់។ អំពើហិង្សាស្តែងឡើងតាមរយៈ ការប្រើអាវុធ ឬមិនប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ការគិតទុកជាមុន ការកាត់អវៈយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ទាក់ទងនឹងជនរងគ្រោះដោយសារគោលដៅ ឬដោយការគិតទុកជាមុនផងដែរ។ ចំពោះសកម្មភាពនៃការប្រព្រឹត្តិវាអាចកើតឡើងដោយសារគំនុំ ការសងសឹង ឬក៏ភាពខ្វះការអប់រំ ឆេវឆាវ របស់ជនល្មើស ដោយទះកំភ្លៀង ដាល់មួយដៃ កាប់ចាក់ បាញ់បោះ ឱ្យជនរងគ្រោះ ផឹក ឬ លេប ឬ បញ្ចូលនូវសារធាតុពុលទៅក្នុងខ្លួនតាមគ្រប់មធ្យោបាយ ធ្វើឱ្យមានការឈឺចាប់ រងរបួស ឬ គ្មានរបួស និង ខូចសុខភាពជាដើម ។

ដូច្នេះប្រធានបទនេះផ្តោតទៅលើ អំពើហិង្សាដោយចេតនា និងការទទួលទោសតាមច្បាប់ព្រហ្មទណ្ឌដែលបានកំណត់ថា អំពើណាខ្លះចាត់ទុកជាការប្រើហិង្សាដោយចេតនា ឬហិង្សាមានស្ថានទម្ងន់ទោស និងទោសបន្ថែមជាដើម ។ ចំពោះការបែងចែកបទល្មើសហិង្សាដោយចេតនានេះនៅក្នុងក្រមព្រហ្មទណ្ឌ គឺមានទាំងគុណសម្បត្តិ និងគុណវិបត្ត ។ ចំពោះគុណសម្បត្តិ គឺបានផ្តល់អត្ថប្រយោជន៍ដែលជាគោលបំណងនៃការបែងចែកនេះដោយ គោរពតាមគោលការណ៍នៃរដ្ឋធម្មនុញ្ញ មាត្រា ៣២ បានធានានូវសិទ្ធិរស់រានមានជីវិត សេរីភាពមានសន្តិភាពផ្ទាល់ខ្លួន និងហាមឃាត់មិនឱ្យមានទោសប្រហារជីវិត និងការរ៉ាប់រងដោយច្បាប់មិនឱ្យមានការរំលោភបំពានទៅលើរូបរាងកាយបុគ្គលណាមួយឡើយ។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬ ព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬ ជនជាប់ពន្ធនាគារមិនឱ្យធ្វើឡើយ ។ ការប្បញ្ញត្តិបែបនេះដើម្បីបង្ការការប្រព្រឹត្តបទល្មើសដែលជាផលវិបាកយ៉ាងធ្ងន់ធ្ងរទៅលើសន្តិសុខសង្គម ។

គុណវិបត្ត បើទោះបីជាការកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌក៏ដោយ តែបទល្មើសហិង្សានេះនៅតែបន្តកើតមាន ដែលវាជាអំពើផ្ទុយ និងគតិច្បាប់កំណត់ថាជាបទល្មើស ដោយវាបានជះឥទ្ធិពលអាក្រក់សង្គមជាតិ ជាពិសេសសណ្តាប់ធ្នាប់សាធារណៈ សន្តិភាព និងសន្តិសុខរបស់ប្រជាពលរដ្ឋ ។

បន្ទាប់ពីបានធ្វើការសន្និដ្ឋានរួចមកយើងខ្ញុំ មាននមតិយោបល់ខ្លះដើម្បីចូលរួមទៅ និងចំណុចខ្វះខាត ឬឆកល្វែងនៃបទល្មើសនេះ ដែលបានលើកឡើងដោយធ្វើជាអនុសាសន៍ក្នុងទំព័របន្ទាប់នេះ ។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការបកស្រាយអំពីបទល្មើសហិង្សាដោយចេតនា យើងខ្ញុំបានសង្កេតឃើញមានចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានដែលវាជាបញ្ហាយ៉ាងសំខាន់ ដោយសារតែបទល្មើសមួយនេះ ប៉ះពាល់ដល់សិទ្ធិរស់រានមានជីវិត ការប៉ះពាល់ដល់ជីវិតមនុស្ស និងការប៉ះពាល់បូរណភាពបុគ្គល និងសិទ្ធិលើរូបរាងកាយដែលវាបានប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយ និងសន្តិសុខក្នុងសង្គមជាតិ។ ចំពោះការខ្វះខាត គឺជាគុណវិបត្តិមួយដែលយើងត្រូវដោះស្រាយឱ្យមានប្រសិទ្ធិភាព និងយកចិត្តទុកដាក់ជាទីបំផុត។ ដោយភាពអវិជ្ជមាននេះវាបានបង្កភាពរាំងស្ទះ ដល់សុខដុមរមនាសង្គម និងសន្តិភាពដែលរដ្ឋាភិបាលកំពុងថែរក្សានេះ។

ដើម្បីឱ្យការប្រព្រឹត្តអំពើហិង្សានេះថយចុះ ក្រសួង ឬស្ថាប័នពាក់ព័ន្ធនានាត្រូវធ្វើការអប់រំណែនាំ និងផ្សព្វផ្សាយកម្មវិធីនានា ដែលទាក់ទងនិងវិស័យច្បាប់ តាមរយៈទូរទស្សន៍ ឬ សោតទស្សន៍ ជាពិសេសតាមបណ្ដាញសង្គម ហ្វេសប៊ុក និងតាមបណ្ដាញផ្សេងៗទៀត ដែលអាចធ្វើទៅបានដោយបង្កើតកម្មវិធីវីដេអូអប់រំខ្លីៗ បង្កើតពាក្យស្លោក ទាក់ទងនឹងផលប៉ះពាល់នៃការប្រព្រឹត្តអំពើហិង្សាដោយចេតនាដែលមានកំណត់ក្នុងច្បាប់ជាធរមាន ឬបទបង្ហាញស្ដីពី បទល្មើស តាមទីសាធារណៈឱ្យបានច្រើន។

មន្ត្រីនគរបាលយុត្តិធម៌ចុះធ្វើការអប់រំណែនាំស្ដីអំពី បញ្ហាដែលទាក់ទង និងបទល្មើសហិង្សាក្នុងសហគមន៍ ឬចុះទៅបង្រៀន អំពីផលប៉ះពាល់ដែលកើតចេញពីការប្រព្រឹត្តបទល្មើស និងពន្យល់ពីទោសទណ្ឌដែលច្បាប់បានកំណត់។

បើកវគ្គបណ្ដុះបណ្ដាលទៅដល់មន្ត្រីនគរបាលតាមមូលដ្ឋាន ឱ្យយល់ដឹងអំពីប្រភេទនៃបទល្មើស និងតួនាទីនៃការបង្ការបទល្មើសក្នុងសហគមន៍ តាមផែនការណ៍នយោបាយ ។

ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ ចំពោះការបង្កើតយន្តការ ឬ វិធីសាស្ត្រណាមួយដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមតាមគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ដើម្បីបញ្ចៀសការប្រព្រឹត្តបទល្មើសដែលជះផលអាក្រក់ទៅក្នុងសហគមន៍ និងក្រុមគ្រួសារ ។

បើកវគ្គអប់រំផ្លូវចិត្ត ដល់ប្រជាពលរដ្ឋដើម្បីអប់រំសតិសម្បជញ្ញៈ គ្រប់គ្រងកំហឹង និងពន្យល់អប់រំពីសិទ្ធិរបស់បុគ្គលម្នាក់ ករណីមានការប្រើប្រាស់អំពើហិង្សាត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការដោះស្រាយ និងការពារជនរងគ្រោះ។

# ឯកសារយោង

- **លិខិតបទដ្ឋានគតិយុត្តជាតិ**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមនីតិវិធិព្រហ្មទណ្ឌ ឆ្នាំ២០១៣
- ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
- ច្បាប់ស្តីពីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

- **លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ**

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨

- **សៀវភៅមេរៀន**

- សៀវភៅនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយ លោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ឆ្នាំ២០១០
- សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរៀងដោយ លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០០៧
- សៀវភៅនីតិព្រហ្មទណ្ឌពិសេស រៀបរៀងដោយ លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១៤
- សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១៤
- សៀវភៅនីតិព្រហ្មទណ្ឌពិសេស រៀបរៀងដោយ លោកសាស្ត្រាចារ្យ **កៅ សីហា** ឆ្នាំ២០១៤

- **វចនានុក្រម និងសន្ទានុក្រម**

- វចនានុក្រម សម្តេចព្រហ្មសង្ឃរាជ **ជួន ណាត**
- សន្ទានុក្រមច្បាប់ រដ្ឋប្បវេណី ឆ្នាំ២០០៧
- សន្ទានុក្រមច្បាប់សាលាគ្រាដូ

# ឧបសម្ព័ន្ធ















# ព្រះរាជក្រម

នស/រកម/១០០៥/០៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ លើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការទប់ស្កាត់អំពើហិង្សា

# ក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.—**

ច្បាប់នេះ មានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គម នៅព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មានទិសដៅបង្កើតយន្តការនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន ។

## ជំពូកទី ២

## វិសាលភាពនៃការអនុវត្ត

**មាត្រា ២.—**

អំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើ :

១-ប្តី ឬ ប្រពន្ធ

២-កូនក្នុងបន្ទុក

៣-ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ ។

**មាត្រា ៣.—**

អំពើហិង្សាក្នុងគ្រួសារ ទាមទារឱ្យមានការទប់ស្កាត់ទាន់ពេលវេលា និង ប្រកបដោយប្រសិទ្ធភាព ហើយតម្រូវឱ្យចាត់វិធានការសមស្របបំផុតដើម្បីការពារជនរងគ្រោះ ឬ ជនអាចនឹងរងគ្រោះ ។

អំពើហិង្សា រួមមាន :

-ការប៉ះពាល់ដល់ជីវិត

ឝ

-ការប៉ះពាល់ដល់បូរណភាពរូបកាយ

-ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ

-ការឈ្លានពានខាងផ្លូវភេទ ។

**មាត្រា ៤.—**

អំពើប៉ះពាល់ដល់ជីវិត រួមមាន :

-មនុស្សឃាតដោយគិតទុកជាមុន

-មនុស្សឃាតដោយចេតនា

-មនុស្សឃាតដោយអចេតនា បណ្ដាលមកពីអំពើចេតនាផ្សេងទៀតនៃជនល្មើស

-មនុស្សឃាតដោយអចេតនា ។

**មាត្រា ៥.—**

អំពើប៉ះពាល់ដល់បូរណភាពរូបកាយ រួមមាន :

-ការបំពារបំពានលើរូបកាយដោយប្រើអាវុធ ឬ ឥតអាវុធមានរបួស ឬ គ្មានរបួស

-ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ ។

**មាត្រា ៦.—**

អំពើទារុណកម្ម ឬ អំពើឃោរឃៅ រួមមាន :

-ការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ

-ការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្ត និងលើរូបកាយដែលប្រព្រឹត្តហួសពីសីលធម៌ និងច្បាប់កំណត់ ។

**មាត្រា ៧.—**

អំពើឈ្លានពានខាងផ្លូវភេទ រួមមាន :

-ការប្រើហិង្សាសេពសន្ថវៈ

-ការបៀតបៀនកេរ្តិ៍ខ្មាស

-ការធ្វើអាស្រូវកាស ។

**មាត្រា ៨.–**

ត្រូវទប់ស្កាត់ផងដែរ ចំពោះអំពើគំរាមកំហែងក្នុងគោលបំណងធ្វើឱ្យជនរងគ្រោះភ័យខ្លាច តក់ស្លុត និងអំពើប៉ះពាល់ដល់បុគ្គលភាព និងទ្រព្យសម្បត្តិនៃជនដែលរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារតែមួយ ។

មិនរាប់បញ្ចូលថាជាការប្រើហិង្សា ឬ សកម្មភាពហិង្សាក្នុងគ្រួសារទេ រាល់ការប្រៀនប្រដៅដោយផ្តល់ដំបូន្មាន ឬ ធ្វើការដាស់តឿនក្រើនរំលឹក ឬ ចាត់វិធានការនានាសមស្របដើម្បីឱ្យសហព័ទ្ធ ឬ កូន ឬ អ្នកនៅក្នុងបន្ទុកដើរក្នុងផ្លូវល្អតាមលក្ខណៈរស់នៅថ្លៃថ្នូរ និងទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ ប្រសិនបើការប្រៀនប្រដៅនិងការអប់រំនោះធ្វើឡើងប្រកបដោយព្រហ្មវិហារធម៌និងស្របទៅតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## សមត្ថកិច្ច និងនីតិវិធី

**មាត្រា ៩.–**

អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត មានកាតព្វកិច្ចធ្វើអន្តរាគមន៍ជាបន្ទាន់ ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬ ប្រមុងនឹងកើតឡើង ដើម្បីទប់ស្កាត់ និងការពារជនរងគ្រោះ ។

ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច ។

**មាត្រា ១០.-**

ក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ មន្ត្រីនៃក្រសួងកិច្ចការនារីបម្រើការងារលើវិស័យដែលបញ្ញត្តិដោយច្បាប់នេះ ត្រូវបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ១១.-**

ក្នុងករណីអវត្តមាននៃមន្ត្រីដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌រួចហើយនោះ មន្ត្រីសមត្ថកិច្ចដទៃទៀតរួមមាន មន្ត្រីនគរបាល ភ្នាក់ងារនគរបាល កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋាន ឃុំ សង្កាត់ មន្ត្រីរបស់ក្រសួងកិច្ចការនារី រួមទាំងមេភូមិដែលបានធ្វើអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះត្រូវបានទទួលអំណាចពីច្បាប់នេះ ដើម្បីធ្វើកំណត់ហេតុជូនទៅតុលាការ ។ កំណត់ហេតុនេះ មានតម្លៃស្មើគ្នាឲ្យចកំណត់ហេតុដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ដែរ ។

**មាត្រា ១២.-**

ក្នុងការអនុវត្តភារកិច្ច អាជ្ញាធរមានសមត្ថកិច្ចដូចបានចែងក្នុងមាត្រា ៩ មាត្រា ១០ និងមាត្រា ១១ ខាងលើនេះ ត្រូវគោរពតាមនីតិវិធីដែលបានកំណត់ក្នុងបញ្ញត្តិនៃច្បាប់នេះ និងនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៤
## វិធានការទប់ស្កាត់ និងការការពារជនរងគ្រោះ

**មាត្រា ១៣.-**

ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើត ឬ ជឿជាក់ថានឹងកើតឡើង អាជ្ញា-

បើមានការស្នើសុំពីជនរងគ្រោះ ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ ។

-ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្នដែលអាចធានាសុវត្ថិភាព និងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់

-ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឱ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សាដែលមានចែងនៅក្នុងមាត្រា ២០ និងមាត្រា ២៦ នៃច្បាប់នេះ ។

ជនមុខសញ្ញាក្នុងច្បាប់នេះ គឺសំដៅដល់អ្នកដែលបានប្រព្រឹត្ត កំពុងប្រព្រឹត្តនិងត្រៀមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ។

**មាត្រា ១៥.-**

ដើម្បីការពារសន្តិសុខជនរងគ្រោះ អាជ្ញាធរមានសមត្ថកិច្ចអាចចេញសេចក្តីសម្រេចរដ្ឋបាលស្របតាមមាត្រា ៤៣ មាត្រា ៤៨ និងមាត្រា ៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងចាត់វិធានការបណ្តោះអាសន្នស្របច្បាប់ដែលមានជាអាទិ៍ :

-ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬ ដោយអ្នកផ្សេង

-ហាមបំផ្លាញទ្រព្យសម្បត្តិ ឬ ណែនាំកុំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬ របស់ជនរងគ្រោះ ឬ របស់ញាតិសាលោហិតរបស់ជនរងគ្រោះ

-ហាមជនមុខសញ្ញាចូលទៅជិត ឬ ចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬ កន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច

-ចាត់វិធានការស្របច្បាប់ផ្សេងទៀត ដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសមាជិកក្នុងគ្រួសារ ឬជនដែលពាក់ព័ន្ធ ។

**មាត្រា ១៥.-**

បើមានសំណើសុំធ្វើអន្តរាគមន៍ និងមានបទល្មើសជាក់ស្តែងកើតឡើងហើយ អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចូលទៅក្នុងទីកន្លែងកើតហេតុ ទោះជាពុំមានដីកាតុលាការអនុញ្ញាតឱ្យចូលក៏ដោយ ក្នុងករណីទាំងឡាយណាដែលមន្ត្រី និងភ្នាក់ងារមានសមត្ថកិច្ច យល់ដោយសមហេតុផលថាមានអំពើហិង្សាក្នុងគ្រួសារបានកើតឡើងក្នុងអំឡុងពេល ៤៨ម៉ោងកន្លងផុត ឬនឹងអាចកើតឡើងក្នុងអំឡុងពេល ២៤ម៉ោងខាងមុខ ។

ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច ។

**មាត្រា ១៦.-**

ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្ត ក្រុង ដើម្បីសុំឱ្យចេញដីកាការពារ ។

ចៅក្រមដែលទទួលបាត់ការ ត្រូវចេញដីកាការពារដោយមានវត្តមាន ឬ ពុំចាំបាច់មានវត្តមានជនមុខសញ្ញា ។

**មាត្រា ១៧.-**

ក្នុងការចូលរួមអនុវត្តនីតិវិធីព្រហ្មទណ្ឌជាធរមាន អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីផ្សះផ្សា ឬ សម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬ មជ្ឈិមធ្ងន់ធ្ងរបានទេ ។

**មាត្រា ១៨.-**

អាជ្ញាធរមានសមត្ថកិច្ច អាចឃាត់ខ្លួនជនមុខសញ្ញាដែលកំពុងប្រព្រឹត្តអំពើហិង្សាជាក់ស្តែង ឬ ជនមុខសញ្ញាណាដែលកំពុងតែរំលោភលើដីកាការពាររបស់តុលាការដូចមានចែងក្នុងមាត្រា ២៤ និងមាត្រា ២៥ នៃច្បាប់នេះ ដោយពុំចាំបាច់មានដីកាតុលាការ ។ ប៉ុន្តែក្រៅពីករណីទាំងពីរនេះ ការឃាត់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ចដែលពុំមានដីកាពីតុលាការ ត្រូវហាមឃាត់ ។

ឝ

៤/៤

ក្នុងករណីអនុវត្តតាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ ខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុច្បាស់លាស់ កសាងសំណុំរឿង និងបញ្ជូនជនមុខសញ្ញាដែលត្រូវឃាត់ខ្លួនទៅតុលាការជាបន្ទាន់ ក្នុងអំឡុងពេលអតិបរិមាដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីចាត់វិធានការបន្ថែមឱ្យស្របច្បាប់ ។

**មាត្រា ១៩.-**

អំពើហិង្សាក្នុងគ្រួសារណាដែលមានចរិតជាបទល្មើសព្រហ្មទណ្ឌមានលក្ខណៈជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមធ្ងន់ធ្ងរ ត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញា ទោះអំពើហិង្សានេះបានកន្លងផុតហើយក៏ដោយ ។

បណ្តឹងអាជ្ញា ត្រូវធ្វើឡើងតាមបែបបទដែលមានចែងក្នុងច្បាប់នេះ និងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៥
## សិទ្ធិអំណាចតុលាការ

**មាត្រា ២០.-**

ដីកាការពារមានអនុភាពបង្គាប់បញ្ជាលើជនមុខសញ្ញា លើអាជ្ញាធរមានសមត្ថកិច្ច និងលើជនដែលពាក់ព័ន្ធនឹងរឿងក្តីនេះ ។ ដីកាការពារនេះ ជាវិធានការផ្នែករដ្ឋប្បវេណី ។

ដីកាការពារមានកម្មវត្ថុចង្អុលបង្ហាញអំពីស្ថានភាព សកម្មភាព ឬអាកប្បកិរិយាទាំងអស់ជាការបង្គាប់ឱ្យធ្វើក្តី ឬ បញ្ជាហាមឃាត់មិនធ្វើក្តី ដែលទាក់ទិនទៅនឹងតម្រូវការការពារជនរងគ្រោះ ឬ បុគ្គលណាដែលទទួលការគំរាមកំហែងពីអំពើហិង្សាក្នុងគ្រួសារ ។

ដីកាការពារមាន ៖

១-ឥទ្ធិពលសម្រាប់មួយរយៈ

២-ឥទ្ធិពលបណ្តោះអាសន្នស្របតាមបញ្ញត្តិនៃមាត្រា ២៣ នៃច្បាប់នេះ ។

ទៅក្រុមមានសមត្ថកិច្ចមានសិទ្ធិចេញដីកាការពារជាថ្មី ស្របតាមស្ថានភាពជាក់ស្តែង ឬ បទបញ្ជាណាមួយក្នុងលក្ខណៈសមស្រប ។

**មាត្រា ២១.-**

មានតែតុលាការខេត្ត ក្រុងទេ ដែលមានសមត្ថកិច្ចចេញដីកាការពារជាប្រយោជន៍ដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារលើគ្រប់ករណីទាំងអស់ ទោះជាអំពើហិង្សាក្នុងគ្រួសារនោះកើតឡើងផ្ទួនគ្នាជាផ្នែកស៊ីវិលក្តី ជាផ្នែករដ្ឋបាលក្តី ឬ ជាផ្នែកព្រហ្មទណ្ឌក្តី ។

**មាត្រា ២២.-**

ពាក្យបណ្តឹងសុំដីកាការពារពីតុលាការអាចធ្វើឡើងដោយ :

១-ជនរងគ្រោះ ឬ តំណាងជនរងគ្រោះ ឬ អាជ្ញាធរមានសមត្ថកិច្ចនៃលំនៅឋានជនរងគ្រោះ ឬ មន្ត្រីភ្នាក់ងារដែលបំពេញការងារនៅកន្លែងកើតហេតុ ។

២-ជនណាម្នាក់ដែលបានដឹងពីឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើជនរងគ្រោះជាកុមារ ជាជនវិកលចរិត ឬ ជាជនដែលតុលាការយល់ថាគ្មានលទ្ធភាពធ្វើពាក្យបណ្តឹងដោយខ្លួនឯងបាន ។

**មាត្រា ២៣.-**

ដីកាការពារមានពីរដំណាក់កាល :

១-ដំណាក់កាលទី ១ ហៅថាដីកាការពារបណ្តោះអាសន្នដែលមានរយៈពេល ២(ពីរ)ខែ ចេញក្នុងពេលដែលមានអាសន្នពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ ។

២-ដំណាក់កាលទី ២ ហៅថាដីកាការពារមានរយៈពេល ៦(ប្រាំមួយ)ខែ ចេញក្នុងពេលដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់ជំនុំជម្រះ ឬ មុនមានសាលក្រមស្ថាពរ ។

**មាត្រា ២៤.-**

តុលាការអាចចេញដីកាការពារបណ្តោះអាសន្ន នៅពេលទទួលបណ្តឹងការពារ

ដោយមិនចាំបាច់សាកសួរជនមុខសញ្ញា បើសិនវិធានការបណ្តោះអាសន្ននោះមានភាពចាំបាច់សម្រាប់រក្សាការពារសុវត្ថិភាពនិងសុខុមាលភាពរបស់ជនរងគ្រោះ ឬសម្រាប់ជាការរក្សាទុកជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិជនរងគ្រោះមុនមានសាលក្រមស្ថាពរ ។

**មាត្រា ២៥.-**

ក្នុងការចេញដីកាការពារ តុលាការមានសិទ្ធិកំណត់បញ្ជាលើសកម្មភាពជនមុខសញ្ញា ដើម្បីការពារជនរងគ្រោះដូចតទៅ :

-ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬ ដោយអ្នកផ្សេង

-ហាមចូលទៅជិត ឬ ចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬ កន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះនិងអាជ្ញាធរមានសមត្ថកិច្ច ។

-ហាមជនមុខសញ្ញាទាក់ទងជាមួយជនរងគ្រោះតាមផ្លូវណាមួយ

-ហាមបំផ្លាញទ្រព្យ ឬ ចាត់ចែងលក់ទ្រព្យរបស់ជនរងគ្រោះឬញាតិសាលោហិតរបស់ជនរងគ្រោះ

-បំបែកជនមុខសញ្ញាពីលំនៅឋានរួម ឬ បំបែកជនរងគ្រោះ បើមានការស្នើសុំ ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ ។

បើយល់ថាជាការចាំបាច់សម្រាប់ការពារ ឬ រៀបចំសុវត្ថិភាព សុខភាព និងសុខុមាលភាពជនរងគ្រោះ តុលាការអាចបង្គាប់ដោយចាត់វិធានការបន្ថែមទៀតដូចតទៅ :

-បញ្ជាឱ្យភ្នាក់ងារនគរបាល ឬ កងរាជអាវុធហត្ថណាម្នាក់ការពារបេតិកភណ្ឌផ្ទាល់ខ្លួនរបស់ជនរងគ្រោះ

-សម្រេចអំពីការថែរក្សាកូន និងអំពីសិទ្ធិទៅសួរសុខទុក្ខកូន ដោយគិតយ៉ាងខ្ពស់បំផុតពីសិទ្ធិ និងផលប្រយោជន៍នៃកុមារនោះ

-បញ្ឈប់កាតព្វកិច្ចហិរញ្ញវត្ថុនៃជនរងគ្រោះចំពោះជនមុខសញ្ញា

-កំហិតឱ្យជនមុខសញ្ញាផ្តល់ជំនួយហិរញ្ញវត្ថុឱ្យជនរងគ្រោះដោយផ្អែកតាមលទ្ធភាពធនធាននៃជនមុខសញ្ញា ។

**មាត្រា ២៦.-**

ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬ ផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬ បទលហុ ការផ្សះផ្សា ឬ សម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង ។ សមាជិកគ្រួសារអាចជ្រើសរើសវិធីណាមួយដោយស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើជាអ្នកអាជ្ញាកណ្តាលដោះស្រាយបញ្ហា ដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៧.-**

អនុលោមលើខ្លឹមសារនៃមាត្រា ២៥ ខាងលើ តុលាការត្រូវព្យាយាមធ្វើការផ្សះផ្សាភាគីមានវិបត្តិអំពើហិង្សា ក្នុងលក្ខខណ្ឌឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់សមាជិកនៃគ្រួសារនោះ ។ ក្នុងការផ្សះផ្សាសម្រុះសម្រួលគ្នា តុលាការត្រូវចៀសវាងធ្វើសម្ពាធលើគូភាគីដែលមិនព្រមស្រុះស្រួលគ្នា ឬបង្ខិតបង្ខំភាគីណាមួយឱ្យចូលផ្សះផ្សា ឬ បង្ខិតបង្ខំឱ្យចុះកិច្ចព្រមព្រៀងដោយគ្មានការព្រមព្រៀងពីភាគីទាំងពីរឡើយ ។

**មាត្រា ២៨.-**

ក្នុងករណីអំពើហិង្សាពាក់ព័ន្ធដល់កុមារ អាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីទទួលបន្ទុកបម្រើប្រយោជន៍កុមារនិងការពារសុខុមាលភាពកុមារ ធ្វើការតាមដានបញ្ហានេះ ។ ក្នុងករណីធ្ងន់ធ្ងរ អាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងទៅតុលាការ ។

អ្នកទទួលខុសត្រូវណាម្នាក់ដែលតុលាការបានបង្គាប់រួមទាំងព្រះរាជអាជ្ញាផង ត្រូវទទួលបន្ទុកតាមដានអំពីស្ថានភាពនៃកុមារ និងធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនេះជូនទៅតុលាការ ។

តុលាការអាចផ្ដល់អាណត្តិដល់ស្ថាប័នមានសមត្ថកិច្ច ដើម្បីរកជំនួយនិងការគាំទ្រជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារព្រមទាំងការពារសុវត្ថិភាពនិងសុខុមាលភាពជនរងគ្រោះ ពេលតុលាការកំពុងបំពេញនីតិវិធី ។

**មាត្រា ២៩.-**

លើកលែងតែករណីបន្ទាន់ដូចមានចែងក្នុងមាត្រា ២៣ តុលាការត្រូវជូនដំណឹងទៅជនមុខសញ្ញាអំពីការស្នើសុំដីកាការពារមិនឱ្យលើសពី ៥(ប្រាំ)ថ្ងៃ មុននឹងយកបញ្ហានេះមកពិនិត្យ ។ បើជនមុខសញ្ញានេះមិនបង្ហាញខ្លួននៅមុខតុលាការ ដើម្បីបញ្ជាក់អំពីហេតុផល តុលាការអាចពិនិត្យបញ្ហាដោយពុំមានវត្តមានជនមុខសញ្ញា ឬ បើជាការចាំបាច់ អាចចាត់វិធានការតាមនីតិវិធីជាធរមាន ចំពោះជនមុខសញ្ញាដែលមិនអើពើនឹងសេចក្ដីសម្រេចរបស់តុលាការ ។

ក្នុងករណីអវត្តមាន ឬ ការមិនអើពើរបស់ជនមុខសញ្ញាអំពីសេចក្ដីសម្រេចរបស់តុលាការ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវស្នើតុលាការចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣០.-**

បើមានសំណើពីភាគីណាមួយ តុលាការអាចកែប្រែ លុបចេញ ឬ បន្ថែមទម្ងន់នៅក្នុងដីកាការពារក្រោយពីបានជូនដំណឹងទៅភាគីម្ខាងទៀត ៥(ប្រាំ)ថ្ងៃ មុននឹងសម្រេច ។

គូភាគីអាចធ្វើការតវ៉ាឱ្យតុលាការពិនិត្យឡើងវិញលើសេចក្ដីសម្រេចរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ២(ពីរ)ខែ ចាប់ពីថ្ងៃចេញដីកាការពារ ។

**មាត្រា ៣១.-**

ជនរងគ្រោះ និងជនមុខសញ្ញាមានសិទ្ធិទទួលអ្នកការពារតាមផ្លូវច្បាប់ ឬមានសិទ្ធិជ្រើសរើសអ្នកតំណាងដែលខ្លួនទុកចិត្ត នៅគ្រប់ដំណាក់កាលនៃនីតិវិធី ។

**មាត្រា ៣២.-**

ក្រោយពីបានចេញដីកាការពាររួចហើយ ព្រះរាជអាជ្ញា ឬ មន្ត្រីមានសមត្ថកិច្ចដែលច្បាប់ប្រគល់ឱ្យ ត្រូវចាត់គ្រប់វិធានការ ដើម្បីអនុវត្តដីកាការពារតាមនីតិវិធីកំណត់។

## ជំពូកទី ៦
## ការអប់រំ ការផ្សព្វផ្សាយ និងការបណ្ដុះបណ្ដាល

**មាត្រា ៣៣.-**

រដ្ឋ ត្រូវយកចិត្តទុកដាក់ធ្វើការអប់រំ ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋទូទាំងប្រទេសបានយល់ជ្រួតជ្រាបអំពីបញ្ញត្តិនៃច្បាប់នេះ ជាពិសេសអំពីការទទួលខុសត្រូវក្នុងគ្រួសារ ការគោរពសិទ្ធិគ្នាទៅវិញទៅមកដើម្បីលើកស្ទួយតម្លៃគ្រួសារខ្មែរ សីលធម៌ សុជីវធម៌ ការរស់នៅ ការថែរក្សា និងការអប់រំគ្រួសារ របៀបដោះស្រាយទំនាស់ដោយអហិង្សា និងសន្តិវិធីព្រមទាំងណែនាំឱ្យយល់ពីវិធានការទាំងឡាយក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

រដ្ឋជម្រុញភាគីដែលមានវិបត្តិអំពើហិង្សាក្នុងគ្រួសារឱ្យចូលរួមក្នុងវគ្គពិគ្រោះបញ្ហា ដើម្បីរៀនសូត្រស្វែងយល់អំពីវិធីសាស្ត្រនានា ក្នុងការដោះស្រាយទំនាស់ និងអប់រំដោយមិនប្រើប្រាស់អំពើហិង្សា ។

**មាត្រា ៣៤.-**

ក្រសួង ស្ថាប័នទាំងឡាយរបស់រដ្ឋត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន អង្គការនានា និងផ្នែកឯកជន ដើម្បីជម្រុញកម្មវិធីផ្សព្វផ្សាយនិងអប់រំប្រជាពលរដ្ឋអំពីច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

មន្ត្រីពាក់ព័ន្ធទាំងឡាយ និងភ្នាក់ងារអង្គការនានាត្រូវបានទទួលការបណ្ដុះបណ្ដាលអំពីបញ្ហានៃអំពើហិង្សាក្នុងគ្រួសារ និងវិធានការទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ ដើម្បីឱ្យយល់ពីមូលហេតុចម្បងនានាដែលបង្កឱ្យមានការកើតឡើងនូវអំពើហិង្សាក្នុងគ្រួសារ និងបទល្មើសទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យនេះ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.-**

អំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣៦.-**

ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬ បទលហុ ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០៥

នស/រកម.១០០៥.០៣១ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

ហត្ថលេខា

អ៊ឹង កន្ថាផាវី

លេខ ... ន.ល
ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ វិច្ឆិកា ឆ្នាំ២០០៥
[illegible]
[illegible]